ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ការគ្រប់គ្រងប្រាក់

(ឯកសារសម្រាប់គ្រូ)



**បំណិនជីវិតសម្រាប់សិស្សមធ្យមសិក្សាបឋមភូមិ**
**គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា**

USAID
ជំនួយពីពលរដ្ឋអាមេរិក

អង្គការអប់រំពិភពលោក
WORLD EDUCATION

ឧបត្ថម្ភដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ
រៀបចំដោយ អង្គការអប់រំពិភពលោក សហការជាមួយអង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា

**គណៈកម្មការអភិវឌ្ឍសៀវភៅ**
**"ការគ្រប់គ្រងប្រាក់"**

**គណៈកម្មការនិពន្ធ និងរៀបរៀង**

១. លោកស្រី អេលិន ជោច (Eileen St. George)

២. លោក ចាន់ ណារិន

៣. លោក សៅ ប៊ុនធឿន

**គណៈកម្មការកែសម្រួល**

១. លោក ឈុំ វណ្ណធន

២. លោកស្រី មុំ មេត

៣. លោក ប៉ុល សុរិទ្ធ

**គណៈកម្មការពិនិត្យ**

១. លោក ព្រំ វិបុល

២. លោក មាស ជុតិមា

៣. លោក ហួត នរៈ

ឧបត្ថម្ភថវិកាដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិចដើម្បីអភិវឌ្ឍអន្តរជាតិ (USAID)

រៀបចំដោយ អង្គការអប់រំពិភពលោក

សហការជាមួយ ក្រសួងអប់រំ យុវជន និងកីឡា

# មាតិកា

អារម្ភកថា........................................................................................ ០១
ការណែនាំអនុវត្ត................................................................................ ០២
មេរៀនទី ១: តើខ្ញុំប្រើប្រាស់ប្រាក់យ៉ាងដូចម្តេច?................................................. ០៣
មេរៀនទី ២: តើខ្ញុំបានប្រាក់មកដោយរបៀបណា?................................................ ១០
មេរៀនទី ៣: គោលបំណង តម្លៃ និងអាទិភាព ................................................... ១៦
មេរៀនទី ៤: ទម្លាប់នៃការចំណាយប្រាក់ .......................................................... ២២
មេរៀនទី ៥: ការបង្កើតសៀវភៅកត់ត្រាការចំណាយប្រចាំថ្ងៃ.................................... ២៦
មេរៀនទី ៦: ថវិកាផ្ទាល់ខ្លួន ......................................................................... ៣១
មេរៀនទី ៧: ការពិនិត្យថវិកាផ្ទាល់ខ្លួន........... .................................................. ៣៩
មេរៀនទី ៨: ការរៀបចំបញ្ជីគណនេយ្យគោលសម្រាប់ការធ្វើជំនួញ ............................ ៤៣
មេរៀនទី ៩: តារាងលំហូរសាច់ប្រាក់សម្រាប់ការធ្វើជំនួញ ....................................... ៤៩
មេរៀនទី ១០: ការស្វែងយល់ពីការអនុវត្តរៀបចំបញ្ជីគណនេយ្យ ................................ ៥៩
មេរៀនទី ១១: ការកំណត់តម្លៃទំនិញ ............................................................... ៦៣
មេរៀនទី ១២: ការស្វែងយល់ពីបញ្ហាកំណត់តម្លៃ .................................................. ៦៨
មេរៀនទី ១៣: ការធ្វើជំនួញ និង ថវិកាផ្ទាល់ខ្លួន ................................................ ៧១
ខ្លឹមសារសង្ខេបឯកសារណែនាំសម្រាប់គ្រូ ....................................................... ៨០

## អារម្ភកថា

ឯកសារស្តីអំពី ” **ការគ្រប់គ្រងប្រាក់** ” មានបំណងជួយអ្នករៀនឱ្យទទួលបានចំណេះដឹង បំណិន និង បទពិសោធន៍ក្នុងផ្នែកបំណិនជីវិតងាយៗទាក់ទងនឹងការគ្រប់គ្រងប្រាក់។ ប្រាក់មានតួនាទីសំខាន់ក្នុងសង្គម និង ក្នុងផ្ទះរបស់យើង។ ការរៀនពីរបៀបគ្រប់គ្រងប្រាក់តាំងពីនៅវ័យក្មេង ហើយការផ្សារភ្ជាប់ការគ្រប់គ្រងប្រាក់ ទៅនឹងតម្រូវការទៅតាមអាទិភាព និង គោលបំណងដែលនឹងជួយមនុស្សវ័យក្មេងឱ្យចៀសផុតពីរណ្តៅគ្រោះថ្នាក់ ដែលបណ្តាលមកពីភាពខ្វះការយល់ដឹងក្នុងការធ្វើជំនួញ ឬការលក់ដូរ។ យើងសង្ឃឹមថា យុវជនបច្ចុប្បន្នអាចមាន ការគិតដោយមានផែនការ និងមានគោលបំណងក្នុងការគ្រប់គ្រងប្រាក់ដែលគេមានដូចជាៈ ការឱ្យតម្លៃលើការ ធ្វើផែនការ ការរៀបចំថវិកា និងការធ្វើតាមគោលការណ៍សំខាន់ៗដើម្បីធ្វើឱ្យមុខជំនួញនោះក្លាយជាឱកាសក្នុង ការអភិវឌ្ឍ។

## ការណែនាំអនុវត្ត

### ☑ ការរៀបចំរបស់គ្រូមុនការបង្រៀន

គ្រូត្រូវអានកិច្ចតែងការបង្រៀនប្រចាំថ្ងៃជាមុន មុននឹងទៅបង្រៀន ដើម្បីធានាថាសម្ភារៈបង្រៀនដែលត្រូវការ ត្រូវបានផលិត ឬ បានទទួលដែលខ្លួនអាចប្រើវាក្នុងសកម្មភាពបង្រៀន និង រៀនដោយស្ទាត់ជំនាញ និងមានប្រសិទ្ធភាព។

### 🕑 រយៈពេលបង្រៀន

មេរៀននីមួយៗត្រូវបង្រៀនក្នុងរយៈពេល ២ម៉ោងសិក្សា (១០០ នាទី)។

### 📖 សម្ភារៈ

សម្ភារៈដែលត្រូវការ មានសរសេរនៅក្នុងមេរៀននីមួយៗ។ គ្រូគួរពិនិត្យមើលមេរៀន មុននឹងទៅបង្រៀន ដើម្បីធានាថាសម្ភារៈដែលចាំបាច់ទាំងអស់មានសព្វគ្រប់ហើយ។ សៀវភៅសិស្សមានសារៈសំខាន់សម្រាប់សិស្ស។ ខ្លឹមសារនៅក្នុងសៀវភៅសិស្សមានសំណួរពិភាក្សា និង សកម្មភាពដែលទាក់ទងនឹងការបង្រៀន។

### ☼ លទ្ធផលសិក្សារំពឹងទុក

នៅក្នុងមេរៀននីមួយៗមានសរសេរអំពីលទ្ធផលសិក្សារំពឹងទុក។ លទ្ធផលសិក្សាដែលបង្ហាញនៅក្នុងឯកសារនេះគឺដើម្បីជួយគ្រូឱ្យយល់អំពីវត្ថុបំណងសំខាន់ៗសម្រាប់មេរៀននីមួយៗ និងដើម្បីឱ្យគ្រូប្រមើលគិតដល់សកម្មភាពសិក្សាដែលគ្រូត្រូវដឹកនាំក្នុងពេលបង្រៀន។ ប្រសិនបើគ្រូចងចាំលទ្ធផលសិក្សានោះ គ្រូនឹងអាចវាយតម្លៃបានថា មេរៀនដែលខ្លួនបង្រៀនបានសម្រេច ឬមិនសម្រេចវត្ថុបំណង។

## មេរៀនទី ១ : តើខ្ញុំប្រើប្រាស់ប្រាក់យ៉ាងដូចម្តេច?

**រយៈពេលបង្រៀន** ២ ម៉ោង (១០០នាទី)

### ☑ ការរៀបចំរបស់គ្រូមុនពេលបង្រៀន

- ពិនិត្យមេរៀនដោយហ្មត់ចត់
- ពិនិត្យខ្លឹមសារក្នុងសៀវភៅសិស្ស ដើម្បីចង់ដឹងថាពីខ្លឹមសារ
- សរសេរកម្រងសំណួរ និងខ្លឹមសារមេរៀន

### សម្ភារៈ

- ឯកសារណែនាំសម្រាប់គ្រូ
- សៀវភៅសិស្ស
- ដីស
- ផ្ទាំងក្រដាសធំ និងប៊ិចហ្វឺត
- បាល់ទន់ (សម្រាប់បោះពីសិស្សម្នាក់ទៅសិស្សម្នាក់)
- កម្រងសំណួរ និងខ្លឹមសារមេរៀន

### ☼ លទ្ធផលសិក្សារំពឹងទុក

ពេលរៀនមេរៀននេះចប់ សិស្សនឹងអាច :

- កំណត់ការចំណាយប្រាក់នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ
- កំណត់វត្ថុដែលគ្រួសារត្រូវចំណាយប្រាក់ទិញ
- កំណត់វត្ថុដែលគ្រួសារត្រូវសន្សំប្រាក់សម្រាប់ទិញ
- យល់ច្បាស់លាស់ពីប្រភេទនៃការចំណាយផ្សេងៗ
- យល់ច្បាស់លាស់ពីអ្វីដែលជា "**ចំណង់**" និង អ្វីដែលជា "**តម្រូវការ**"។

### លំនាំនៃការបង្រៀន

| សកម្មភាពទី១ : ការចាប់ផ្តើមបង្ហាញគំនិតខ្ញុំ និងប្រាក់ | : **១០ នាទី** |
|---|---|

១. គ្រូសួរទៅសិស្សក្នុងថ្នាក់ទាំងអស់

✋ តើយើងធ្វើអ្វីខ្លះជាមួយនឹងប្រាក់? (➢(ចម្លើយរំពឹងទុក : ចំណាយ សន្សំ ឱ្យគេខ្ចី ខ្ចីគេ)។

២. ឱ្យសិស្សម្នាក់ៗទុកឱកាស ៥ នាទី សរសេរ

- ឈ្មោះវត្ថុ ៣ យ៉ាងដែលខ្លួនគេចង់បានដោយមិនត្រូវការចំណាយប្រាក់ ។
- ឈ្មោះ វត្ថុ ៣ យ៉ាងដែលខ្លួនគេចង់បានដោយត្រូវការចំណាយប្រាក់ ។

៣. គ្រូឱ្យសិស្សប្រាប់ឈ្មោះវត្ថុដែលពួកគេបានសរសេរ ។

៤. គ្រូបង្ហាញគោលបំណងមេរៀនសម្រាប់ថ្ងៃនេះ ។

ថ្ងៃនេះ យើងនិយាយអំពីតួនាទីរបស់ប្រាក់នៅក្នុងជីវភាពរស់នៅរបស់យើង ។ "តើយើងត្រូវការប្រាក់ដើម្បីអ្វី? តើយើងត្រូវចំណាយប្រាក់យ៉ាងដូចម្ដេច និង ហេតុអ្វីបានជាយើងត្រូវសន្សំប្រាក់" ។ នៅពេលខ្លះជុំវិញខ្លួនយើងត្រូវការប្រើប្រាស់ប្រាក់ ប៉ុន្តែកន្លែងខ្លះអ្វីៗជាច្រើនដែលជាទីចាប់អារម្មណ៍ និង គួរឱ្យចូលចិត្តដែលកើតឡើងដោយមិនចាំបាច់ត្រូវការប្រាក់ ។

| សកម្មភាពទី២: ការចំណាយប្រាក់ និងការសន្សំប្រាក់ | : ២០ នាទី |
|---|---|

១. គ្រូចែកសិស្សជាក្រុមតូចដែលមានគ្នា៥-៦នាក់ ។

២. គ្រូពន្យល់

ថ្ងៃនេះយើងនឹងពិភាក្សាគ្នាអំពីការចំណាយប្រាក់ និងការសន្សំប្រាក់ ។ នៅពេលណាយើងនិយាយពី "**ការចំណាយប្រាក់** " នោះយើងនិយាយអំពីផលិតផល និងសេវាកម្មដែលយើងត្រូវចំណាយប្រាក់ ។ នៅពេលយើងនិយាយពី "**ការសន្សំប្រាក់**" នោះយើងនិយាយផ្ដោតជាពិសេសទៅលើប្រាក់ដែលបានពីការ លក់ផលិតផល និងសេវាកម្មដែលយើងចង់រក្សាទុកសម្រាប់តម្រូវការប្រើប្រាស់ពេលអនាគត ។" **ការសន្សំប្រាក់** "នៅពេលនេះមិនសំដៅពីប្រាក់ដែលបានមកពីការតថ្លៃទំនិញ ឬ ការទិញទំនិញបានថោក នោះទេ ។

៣. ត្រូវឱ្យក្រុមតូច សរសេរចម្លើយចំពោះសំណួរខាងក្រោម :

- តើគ្រួសាររបស់អ្នកចំណាយប្រាក់ទៅលើអ្វីខ្លះ?
- តើគ្រួសាររបស់អ្នកសន្សំប្រាក់សម្រាប់ធ្វើអ្វីខ្លះ?( ចូរចងចាំថា យើងកំពុងតែពិភាក្សាគ្នាពី " **ការសន្សំប្រាក់** " សម្រាប់ការចំណាយពេលដែលយើងត្រូវការនៅពេលអនាគត) ។

៤. គ្រូឱ្យក្រុមសិស្សធ្វើបញ្ជីឈ្មោះវត្ថុដែលគ្រួសារទូទៅចំណាយប្រាក់សម្រាប់ទិញ និង បញ្ជីឈ្មោះវត្ថុដែលគ្រួសារសន្សំប្រាក់សម្រាប់ទិញ ។

| សកម្មភាពទី៣ : ចំណាយថេរ | ⏲:១០ នាទី |
|---|---|

១. នៅពេលធ្វើបញ្ជីឈ្មោះវត្ថុទាំងនោះចប់ហើយ គ្រូសួរសិស្សថា :

- តើការចំណាយណាខ្លះដែលគ្រួសាររបស់អ្នកមាន (ក)ចំណាយជារៀងរាល់ខែ (ខ)ដឹងច្បាស់ពីចំនួនប្រាក់ដែលត្រូវចំណាយប្រចាំខែ
  - ចម្លើយរំពឹងទុក : ឈ្នួលផ្ទះ ថ្លៃឈ្នួលបង្រៀន ឬ ថ្លៃសាលា ការធានារ៉ាប់រង បង់ប្រាក់កម្ចី ។ល ។)

២. គ្រូឱ្យសិស្សផ្តល់ចម្លើយ ហើយគ្រូសរសេរចម្លើយទាំងនោះលើក្តារខៀន ។

៣. ក្រោយពីសរសេររួច គ្រូពន្យល់ដូចខាងក្រោម :

- ទាំងនេះ គឺហៅថា "**ចំណាយថេរ**"
- យើងអាចដឹងបានថាការចំណាយនេះវាកើតមានជារៀងរាល់ខែ
- ការចំណាយទាំងនេះងាយស្រួលនឹងធ្វើផែនការថវិកាចំណាយ ពីព្រោះយើងដឹងពីមុខចំណាយ និងចំនួនថវិកាដែលត្រូវចំណាយជារៀងរាល់ខែ ។

| សកម្មភាពទី៤ : ចំណាយប្រែប្រួល | ⏲: ១០ នាទី |
|---|---|

១. គ្រូបន្តការពិភាក្សា

- (ក) តើ ការចំណាយណាខ្លះដែលគ្រួសាររបស់អ្នកដឹងថាត្រូវការរៀងរាល់ខែ (ខ) ការចំណាយណាខ្លះដែលគ្រួសារអ្នកមិនដឹងពិតប្រាកដពីចំនួនទឹកប្រាក់ដែលត្រូវចំណាយក្នុងខែនីមួយៗ?
  ចម្លើយរំពឹងទុក : ក. ម្ហូបអាហារ ការធ្វើដំណើរ ថ្លៃភ្លើង ថ្លៃទឹក និងសម្លៀកបំពាក់ ។
  ខ. ព្យាបាលជំងឺ ចូលរួមបុណ្យផ្សេងៗ. . .

២. ក្រោយពីស្រង់បញ្ជីឈ្មោះមុខចំណាយនេះ ហើយគ្រូពន្យល់ដូចខាងក្រោម :

- យើងអាចដឹងថាការចំណាយទាំងនេះកើតមានជារៀងរាល់ខែ ប៉ុន្តែជា "**ចំណាយប្រែប្រួល**" (ទឹកប្រាក់ចំណាយអាចខុសគ្នា ពីមួយខែទៅមួយខែ) ។
- ពិតមែនតែយើងដឹងថាវាកើតឡើងរាល់ខែ តែយើងមិនអាចព្យាករណ៍ពីការចំណាយពិតប្រាកដដូចចំណាយថេរនោះទេ ។
- តម្លៃប្រែប្រួលបែបនេះ ធ្វើឱ្យមានការលំបាកក្នុងការគ្រោងថវិកាសម្រាប់ការចំណាយ ព្រោះយើងពុំ

ដឹងត្រូវចំណាយប៉ុន្មាន ។

- ក្នុងករណីបែបនេះ យើងគួរគិតថា តើយើងអាចមានប្រាក់ប៉ុន្មាន ដើម្បីកម្រិតការចំណាយរបស់យើងឱ្យស្របតាមថវិកានោះ ។

៣. គ្រូសួរ : តើមានមុខចំណាយណាដែលនៅសេសសល់ក្នុងបញ្ជី ហើយមិនស្របនឹងប្រភេទចំណាយទាំងនោះ ។ ឱ្យសិស្សគូសរង្វង់លើមុខចំណាយនោះ ។

| សកម្មភាពទី៥ : ការចំណាយមិនបានគ្រោងទុក | ⌚: ១០ នាទី |
|---|---|

១. គ្រូពន្យល់សិស្សថានៅពេលណាខ្លះ យើងត្រូវចំណាយប្រាក់ ដោយមិនបានដឹងខ្លួនជាមុន ។

- តើក្នុងបញ្ជីមានប្រភេទ "**ការចំណាយមិនបានគ្រោងទុក**" ដែរឬទេ? ចូរសរសេរឈ្មោះមុខចំណាយទាំងនោះ ។
- ចូរប្រាប់ឈ្មោះមុខចំណាយដែលមិនបានគ្រោងទុកមួយចំនួនទៀត? (ចម្លើយរំពឹងទុក : ការចំណាយបន្ទាន់លើជំងឺ ធ្លាក់ស្រុតដំបូលផ្ទះ គ្រោះថ្នាក់ចរាចរណ៍ (ជួលជុលម៉ូតូ និង ព្យាបាលរបួស ។ល ។)

២. គ្រូពន្យល់

ទាំងអស់នេះគឺជាការចំណាយដែលមិនបានគ្រោងទុក ។ យើងមិនអាចដឹងពីហេតុការណ៍ ហើយយើងក៏មានការលំបាកក្នុងការគ្រោងថវិកាផងដែរ ដូច្នេះយើងត្រូវសន្សំប្រាក់ខ្លះ ដើម្បីទុកចំណាយទៅលើអ្វីដែលកើតឡើងភ្លាមៗដោយមិនបានគ្រោងទុក ។

| សកម្មភាពទី ៦ : ការចំណាយលើវត្ថុប្រណិត | ⌚: ១០ នាទី |
|---|---|

១. គ្រូពន្យល់

មានការចំណាយមួយបែបទៀត ហៅថា "**ការចំណាយលើវត្ថុប្រណិត**" ។ ការចំណាយបែបនេះគឺសំដៅទៅលើវត្ថុដែលយើងចង់បាន ប៉ុន្តែមិនមែនជាវត្ថុដែលត្រូវការចាំបាច់នោះទេ ។

២. **ការពិភាក្សា**

- តើក្នុងបញ្ជីរបស់យើង មានប្រភេទ "**ការចំណាយលើវត្ថុប្រណិត**" អ្វីខ្លះ?
- តើអ្នកអាចរកចំណាយបែបនេះថែមទៀតបានឬទេ?
  - ចម្លើយរំពឹងទុក : សំលៀកបំពាក់ថ្មី ស្ករគ្រាប់ ការ៉េម សកម្មភាពកំសាន្តសប្បាយផ្សេងៗ គ្រឿងអលង្ការ. . . ។

៣. **គ្រូពន្យល់**

សម្រាប់ការចំណាយបែបប្រណិត យើងអាចគ្រោងថវិកាមួយចំនួនរៀងរាល់ខែ។ យើងអាចសន្សំប្រាក់ក្នុងរយៈពេលយូរ។ ការចំណាយលើវត្ថុប្រណិតគួរតែពិចារណាឱ្យបានហ្មត់ចត់ ប៉ុន្តែជាទូទៅយើងច្រើនតែចំណាយដោយមិនបានគិតគូរច្រើន។

| សកម្មភាពទី ៧ : ការសន្សំប្រាក់ | ⏲: ១០ នាទី |
|---|---|

១. គ្រូឱ្យក្រុមសិស្សពិភាក្សាគ្នាហើយឆ្លើយនឹងសំណួរខាងក្រោម :

- នៅក្នុងគ្រួសារ តើគេសន្សំប្រាក់ដើម្បីអ្វី? (គ្រូ និងសិស្សបង្កើតបញ្ជីចម្លើយរួមគ្នា)។
- នៅក្នុងគ្រួសារ តើគេត្រូវធ្វើអ្វីខ្លះ ដើម្បីសន្សំប្រាក់?
  - ➢ចម្លើយរំពឹងទុក : យកចិត្តទុកដាក់ទៅលើចំនួនប្រាក់ដែលត្រូវចំណាយ ការគ្រោងថវិកាចំណាយ កម្រិតនៃការចំណាយដែលប្រែប្រួល កម្រិតនៃការចំណាយលើភាពប្រណិត ។ល។
- ចូរពិនិត្យមើលប្រភេទចំណាយទាំង៤ (ចំណាយថេរ ចំណាយប្រែប្រួល ចំណាយដែលមិនបានគ្រោងទុក ចំណាយលើវត្ថុប្រណិត)?
- តើការចំណាយណាខ្លះ ដែលពិបាកធ្វើចំណាត់ថ្នាក់? ហេតុអ្វី?
  - ➢ ចម្លើយរំពឹងទុក: វត្ថុខ្លះអាចស្ថិតនៅក្នុងចំណាត់ថ្នាក់ចំណាយផ្សេងៗ ព្រោះវាអាស្រ័យទៅតាមស្ថានភាព។

    ឧទាហរណ៍ :

    ១. ស្បែកជើងអាចស្ថិតក្នុងការចំណាយប្រែប្រួលតែវាក៏អាចជាការចំណាយលើវត្ថុប្រណិតផងដែរ ព្រោះប្រសិនបើអ្នកនោះមានស្បែកជើងច្រើនគូរួចហើយតែនៅចង់ទិញស្បែកជើង ដែលថ្លៃហួសពីថវិកាដែលមាន។

    ២. ម៉ូតូអាចស្ថិតក្នុងការចំណាយប្រែប្រួល ព្រោះយើងត្រូវការមធ្យោបាយធ្វើដំណើរ។ ប៉ុន្តែប្រសិនបើយើងទិញម៉ូតូថ្មីហើយទំនើប នោះវាអាចជាការចំណាយលើវត្ថុប្រណិតទៅវិញ។ ម៉ូតូក៏អាចស្ថិតក្នុងការចំណាយថេរផងដែរ បើយើងដឹងចំនួនទឹកប្រាក់ដែលត្រូវបង់ជាទៀងទាត់ប្រចាំខែនោះ។

| សកម្មភាពទី ៨: និយមន័យនៃពាក្យ "ចំណង់" និង"តម្រូវការ" | ⏲: ១០ នាទី |
|---|---|

១. គ្រូលើកឧទាហរណ៍៦ ដើម្បីឱ្យសិស្សបញ្ជាក់ថាវត្ថុនោះវាជា "**ចំណង់**" ឬ ជា "**តម្រូវការ**"។ នៅពេលដែលសិស្សមានយោបល់ខុសៗគ្នា គ្រូដឹកនាំការពិភាក្សាលើអ្វីដែលពួកគេបានគិត ព្រោះថាវាអាចមានចម្លើយច្រើនដែលត្រឹមត្រូវ។

- ម្ហូបអាហារពេលព្រឹក អាហារថ្ងៃត្រង់ ឬអាហារពេលល្ងាច (ចម្លើយ : ជាតម្រូវការ)
- បាល់សម្រាប់លេងពេលសម្រាក (ចម្លើយ : ជាចំណង់)
- ស្បែកជើងសម្រាប់ពាក់ទៅសាលា (ចម្លើយ : ជាតម្រូវការ)
- ស្បែកជើងសម្រាប់ពាក់ទៅចូលរួមពិធីអាពាហ៍ពិពាហ៍ (ចម្លើយ : ជាចំណង់)
- ការទិញនំនៅក្រៅសាលា (ចម្លើយ : ជាចំណង់)
- សៀវភៅសរសេរ និងប៊ិចសម្រាប់រៀន (ចម្លើយ : ជាតម្រូវការ)

២. គ្រូសួរសំណួរទៅក្រុមសិស្ស: តើ "**ចំណង់**" និង "**តម្រូវការ**" ខុសគ្នាដូចម្តេច?

- ចម្លើយរំពឹងទុក :
  - **តម្រូវការ** គឺអ្វីដែលយើងត្រូវការដើម្បីរស់ មានសុខភាពល្អ និង លទ្ធភាពផ្សេងៗដូចជា មានទីកន្លែងរស់នៅ មានអាហារសម្រាប់បរិភោគ សម្លៀកបំពាក់ដែលជួយការពារយើងទប់ទល់នឹងអាកាសធាតុ និង ការងារដើម្បីឱ្យមានចំណូល ។ល។
  - **ចំណង់** គឺអ្វីដែលយើងចង់បាន ប៉ុន្តែពុំមែនអ្វីដែលជាការចាំបាច់ខានមិនបាននោះទេ មានន័យថាយើងអាចរស់បានដោយគ្មានវា។

| សកម្មភាពទី ៩ : ល្បែងបោះបាល់ឆ្លើយសំណួរស្តីពី "ចំណង់" និង" តម្រូវការ" | ⏱: ១០ នាទី |
|---|---|

១-គ្រូពន្យល់ពីរបៀបលេងល្បែងបោះបាល់ឆ្លើយសំណួរ ប្រើបាល់ដែលទន់ ( បាល់ធ្វើពីក្រដាស ឬ កំណាត់សំពត់)

- ខ្ញុំនឹងបោះបាល់ឱ្យអ្នកណាម្នាក់ចាប់
- នៅពេលបោះបាល់ទៅ ខ្ញុំនឹងស្រែកថា "**ចំណង់**" ឬ មួយស្រែកថា "**តម្រូវការ**"
- អ្នកដែលចាប់បាល់បានត្រូវកំណត់រកវត្ថុអ្វីមួយឱ្យត្រូវទៅនឹងពាក្យដែលខ្ញុំបានស្រែកថា "**ចំណង** ឬ **តម្រូវការ**" ពេលឆ្លើយរួចហើយ អ្នកត្រូវបោះបាល់បន្តទៅមនុស្សម្នាក់ផ្សេងទៀតតាមវិធីដូចគ្នា
- អ្នកត្រូវបន្តរកឧទាហរណ៍ដែលស្ថិតក្នុងប្រភេទដដែល លុះត្រាតែខ្ញុំស្រែកប្តូរទៅ ប្រភេទផ្សេង
- អ្នកត្រូវបោះបាល់ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ដែលឈរជារង្វង់ ដោយព្យាយាមធ្វើឱ្យបានគ្រប់គ្នាៗ
- ប្រសិនបើមានការមិនឯកភាពលើឧទាហរណ៍របស់សិស្សណាម្នាក់ គេអាចបោះបាល់ត្រឡប់ទៅសិស្សនោះវិញ។

២- បន្ទាប់ពីផ្តល់ការណែនាំរួចមក គ្រូចាប់ផ្តើមបោះបាល់។

## មេរៀនទី២ ៖ តើខ្ញុំបានប្រាក់មកដោយរបៀបណា?

**រយៈពេលបង្រៀន** ២ ម៉ោង

**ការរៀបចំរបស់គ្រូមុនពេលបង្រៀន ៖**

- ពិនិត្យមេរៀនដោយហ្មត់ចត់
- ពិនិត្យខ្លឹមសារក្នុងសៀវភៅសិស្ស ដើម្បីដឹងពីព័ត៌មាន និង សំណួរ
- សរសេរសំណួរករណីសិក្សានៅលើក្តារខៀន ឬ នៅលើក្រដាសផ្ទាំងធំ
- សរសេរកម្រងសំណួរ និងខ្លឹមសារមេរៀន

**សម្ភារៈ**

- ឯកសារណែនាំសម្រាប់គ្រូ
- សៀវភៅសិស្ស
- សម្ភារៈបង្រៀនដែលបានរៀបចំដូចខាងលើ
- ដីស
- កម្រងសំណួរ និងខ្លឹមសារមេរៀន

**លទ្ធផលសិក្សារំពឹងទុក**

ពេលរៀនមេរៀននេះចប់ សិស្សនឹងអាច ៖

- កំណត់វត្ថុផ្ទាល់ខ្លួនមួយដែលជា "**ចំណង់**" និង "**តម្រូវការ**" ដែលអ្នកចំណាយប្រាក់
- កំណត់វិធីដែលពួកគេអាចរកប្រាក់បាន
- បង្ហាញពីភាពខុសគ្នារវាងទម្លាប់នៃការចំណាយ និងការសន្សំ
- កំណត់វិធីដែលធ្វើឱ្យក្លាយជាអ្នកសន្សំប្រាក់ប្រសើរជាងមុន ។

## លំនាំនៃការបង្រៀន

| សកម្មភាពទី ១ : ចំណង់ និង តម្រូវការរបស់ខ្ញុំ | ⌚: ១៥ នាទី |
|---|---|

១. និយាយ : កាលមេរៀនមុនយើងបានសិក្សាពីវត្ថុដែលជា "**ចំណង់**" និង "**តម្រូវការ**" ។

✋ គ្រូឱ្យសិស្សលើកឧទាហរណ៍ ២ ឬ ៣ មកបញ្ជាក់ ។

២. គ្រូពន្យល់

ជួនកាលវាមានការច្រឡំគ្នា ឬ ច្របូកច្របល់គ្នាមិនដឹងថាមួយណាជាតម្រូវការមួយណាជាចំណង់ ។

៣. គ្រូនិយាយថាពេលខ្លះមុខចំណាយហាក់ដូចជាសេចក្តីត្រូវការ តែវាជាការចំណាយបែបចំណង់ទៅវិញ ។

ឧទាហរណ៍ : ម្ហូបអាហារជាតម្រូវការ

៤. គ្រូឱ្យសិស្ស លើកឧទាហរណ៍ដែលមានលំនាំដូចឧទាហរណ៍ខាងលើ ដែលជាតម្រូវការឱ្យក្លាយទៅជាការចំណាយបែបជាចំណង់វិញ ។

➢ ឧទាហរណ៍ : ម្តាយខ្ញុំបានធ្វើម្ហូបអាហារថ្ងៃត្រង់យ៉ាងឆ្ងាញ់ ប៉ុន្តែខ្ញុំបានចេញក្រៅទៅញុំាការ៉េមជាមួយមិត្តភក្តិ ។

៥. ឱ្យសិស្សផ្តល់ឧទាហរណ៍ពាក្តីពីការចំណាយដែលជាតម្រូវការ ។

✋ បន្ទាប់មកឱ្យសិស្សប្តូរឧទាហរណ៍ទាំងនោះឱ្យទៅជាប្រភេទចំណាយបែបចំណង់វិញ ឬទទួលស្គាល់ថាវាពិតជាប្រភេទតម្រូវការពិតប្រាកដ ។

➢ ឧទាហរណ៍បញ្ជាក់ពីការចំណាយបែបតម្រូវការយ៉ាងពិតប្រាកដ

- ថ្នាំពេទ្យសម្រាប់បងប្រុសខ្ញុំ ដែលមានជំងឺគ្រុនចាញ់
- ថ្លៃឈ្នួលផ្ទះ
- អាហារូបត្ថម្ភប្រចាំថ្ងៃ
- ទឹកផឹក (ទឹកសុទ្ធ ដើម្បីសុវត្ថិភាពដល់សុខភាព)

➢ ឧទាហរណ៍ការចំណាយដែលជាតម្រូវការដែលអាចប្តូរទៅជាចំណង់ :

- អាហារជាតម្រូវការ តែ ការ៉េម សម្រាប់ពេលរសៀលវាចំណង់ ។
- កាត់សក់ជាតម្រូវការ តែការធ្វើម៉ូតសក់គឺជាចំណង់ ។
- សៀវភៅនិងប៊ិចជាតម្រូវការ តែសៀវភៅនិងប៊ិចដែលថ្លៃៗ គឺជាចំណង់ ។

- កាតទូរស័ព្ទជាតម្រូវការសម្រាប់អ្នកធ្វើទំនាក់ទំនងការងារឬអ្នកជំនួញ តែសម្រាប់សិស្សដែលគ្រាន់តែប្រើសម្រាប់ទាក់ទងមិត្តភក្តិ នោះវាជាចំណង់។

៦. **គ្រូពន្យល់**

នៅពេលយើងនិយាយពីតម្រូវការ និងចំណង់នោះ។ បើយើងពុំបានគិតឱ្យល់អិតយើងអាចប្តូរពីអ្វីដែលជាតម្រូវការទៅជាចំណង់ដោយចៃដន្យមិនខាន។

៥. ទុកឱកាសឱ្យសិស្ស១០នាទីធ្វើបញ្ជីផ្ទាល់ខ្លួនអំពីមុខចំណាយបែប"**តម្រូវការ**"ឱ្យបានយ៉ាងតិចបី និងមុខចំណាយបែប "**ចំណង់**" ឱ្យបានយ៉ាងតិច៣ ដោយបញ្ជាក់មូលហេតុសម្រាប់ឧទាហរណ៍នីមួយៗ។

៦. គ្រូឱ្យសិស្សលើកឧទាហរណ៍មួយចំនួន និងពន្យល់ឧទាហរណ៍ទាំងនោះ។

៧. សិស្សអាចសួរសំណួរទៅគ្រូ ប្រសិនបើឧទាហរណ៍ដែលលើកមកមិនច្បាស់។

**សកម្មភាពទី ២: ការចាប់ផ្តើមបង្ហាញគំនិតអំពីខ្លួនខ្ញុំ និង ប្រាក់** ⌚: **១៥ នាទី**

**១.** គ្រូបង្ហាញប្រធានបទ និង គោលបំណងនៃមេរៀន :

នៅក្នុងសង្គម ប្រាក់ជួយឱ្យយើងបានអ្វីៗដែលយើងត្រូវការ។ សមាជិកគ្រួសារជាច្រើននាក់ បានជួយរកប្រាក់ចូលផ្ទះ។ យើងពិភាក្សាគ្នាពីវិធីរកប្រាក់ ឬ ទទួលបានប្រាក់ចំណូល និងទម្លាប់ក្នុងការរក្សាទុកប្រាក់។

២. គ្រូទុកឱកាស ៣ នាទី ឱ្យសិស្សម្នាក់ៗសរសេរចម្លើយ :

- តើអ្នករកប្រាក់ចំណូល ឬ ទទួលប្រាក់ចំណូលដោយវិធីណា?
- ចូរបង្ហាញវិធី ២ យ៉ាង ដែលអ្នកអាចគិតថាអ្នកអាចរកប្រាក់ចំណូលបាន។
- ប្រាប់ឈ្មោះវត្ថុ ៣ ឬ ៥ ប្រភេទ ដែលអ្នកត្រូវចំណាយប្រាក់ទិញ។
- ប្រាប់ឈ្មោះវត្ថុ ៣ ឬ ៥ ប្រភេទ ដែលអ្នកត្រូវសន្សំប្រាក់សម្រាប់ទិញ។

៣. គ្រូឱ្យសិស្សស្ម័គ្រចិត្តផ្តល់ចម្លើយ។

៤. សំណួរនីមួយៗ គ្រូព្យាយាមរកចម្លើយដែលមានការឯកភាពពីរបៀបរកប្រាក់ សម្រាប់ចំណាយ និងប្រាក់សន្សំសម្រាប់ទិញ។

| សកម្មភាពទី ៣ :ករណីសិក្សាស្តីពីទម្លាប់នៃការប្រើប្រាស់ប្រាក់ | ⏲: ២៥ នាទី |
|---|---|

១-គ្រូឱ្យសិស្សអានករណីសិក្សា

គ្រួសារមួយមានកូនស្រីម្នាក់ស្រស់ស្អាត។ សម្រស់របស់នាងទាក់ទាញបុរសៗជាច្រើន។ បុរសបីនាក់បានចូលមកដើម្បីសុំស្តីដណ្តឹងនាង។ ក្រុមគ្រួសារបានជួបជុំពិភាក្សាពីរឿងនេះដើម្បីជួយនាង ក្នុងការធ្វើការសម្រេចចិត្តជ្រើសរើសបុរសម្នាក់ធ្វើជាគូគ្រង។ ពេលពិភាក្សាគ្នាគេទទួលបានព័ត៌មានថា បុរសទាំងបីនាក់សុទ្ធតែជាអ្នកមានទ្រព្យសម្បត្តិ ម្នាក់ៗមានដល់ទៅ ៥ ម៉ឺនដុល្លារស្មើៗគ្នា។ ពួកគាត់បានប្រាក់មកដោយរបៀបខុសៗគ្នា។

- o បុរសទី ១ ជាកូនរស់នៅក្នុងគ្រួសារមធ្យម ហើយជាមនុស្សមានបទពិសោធន៍ក្នុងការលេងល្បែងស៊ីសង។ បុរសនេះពុំមានការងារធ្វើពេញម៉ោង ឬពុំមានប្រាថ្នាចង់ធ្វើការពេញម៉ោងទេ ព្រោះគេនិយាយថាគេអាចមានជីវភាពធូរធារដោយសារការលេងល្បែងស៊ីសង (មានទេពកោលស្យ)។ គេប្រាប់ក្រុមគ្រួសារគេថាល្បែងស៊ីសងគឺជាអាជីពរបស់គេ ហើយគេមានឈ្មោះល្បីថាជាអ្នកជំនាញខាងលេងល្បែងស៊ីសង។
- o បុរសទី ២ ជាកូនក្នុងគ្រួសារក្រីក្រ ប៉ុន្តែគេមានទេពកោសល្យខាងជំនួញ។ គេខិតខំធ្វើការងារ។ គេបានធ្វើការ និង សន្សំប្រាក់ ហើយដាក់ទុនរកស៊ីទៀតផង ឥឡូវនេះគេក្លាយជាអ្នកធ្វើជំនួញដ៏មានជោគជ័យម្នាក់ ដោយបើកហាងលក់ និងជួសជុលកុំព្យូទ័រ។ គាត់ជាមនុស្សដែលប្រឹងប្រែងធ្វើការ ព្រមទាំងជាមនុស្សស្មោះត្រង់ និងមានទស្សនៈវិស័យសម្រាប់អនាគត។
- o បុរសទី ៣ ជាកូនកសិករដែលមានដីធ្លីច្រើន។ គេមានសំណាងដោយបានរកឃើញវត្ថុមានតម្លៃនៅក្នុងស្រែរបស់គេ។ គេបានលក់វត្ថុនោះបានប្រាក់យ៉ាងច្រើន។ គេសន្សំប្រាក់នេះ ព្រោះគេដឹងថាថ្ងៃណាមួយគេនឹងរៀបការហើយមានទ្រព្យសម្បត្តិ។ គាត់ជាអ្នកដែលប្រកាន់វិន័យ ហើយពូកែទុកដាក់ប្រាក់។ គេចាត់ទុកខ្លួនគេថាជាអ្នកមានសំណាង ដោយបានរកឃើញកំណប់លាភ។

២-គ្រូឱ្យសិស្សក្រុមធំពិភាក្សាករណីសិក្សានេះ

- តើបុរសទាំងបីនៅក្នុងរឿននេះសន្សំប្រាក់បានប៉ុន្មាន?
- តើបុរសទាំងបីខុសគ្នាដូចម្តេចខ្លះ?
- តើបុរសទាំងបី ចំណាយប្រាក់របស់គេដូចម្តេច?
- តើបុរសណាមួយមានផែនការសន្សំប្រាក់ល្អជាងគេ? ហេតុអ្វី?
- តើបុរសមួយណា ដែលអ្នកគិតថាមានភាពឈ្លាសវៃក្នុងការប្រើប្រាស់ប្រាក់ជាងគេ? ហេតុអ្វី?
- តើបុរសណាមួយ ដែលអ្នកគិតថានាងគួររៀបការជាមួយ?

៣-គ្រូពន្យល់

ថ្វីត្បិតតែបុរសទាំងអស់មានប្រាក់ចំនួនស្មើគ្នា ប៉ុន្តែម្នាក់ៗបង្ហាញនូវឥរិយាបថក្នុងការប្រើប្រាស់ខុសៗគ្នា។ បុរសទី១ជាអ្នកលេងល្បែងដូចនេះប្រាក់របស់គាត់ដកចេញ និងដាក់ចូលយ៉ាងងាយក្នុងអាជីពរបស់គាត់។ ប្រាក់សន្សំរបស់គាត់ភាគច្រើនទៅលើការលេងល្បែង ហើយប្រាក់នោះអាចនឹងអស់បើគាត់ចាញ់ល្បែង ព្រោះគាត់គ្មានមុខរបរផ្សេងទៀតឡើយ។

បុរសទី២ ជាអ្នកជំនួញ ដែលចាត់ទុកប្រាក់ថាជាទុនចាំបាច់សម្រាប់ការរកស៊ី។ ប្រាក់របស់គាត់ប្រើជាទុន(ដើម្បីចំណាយ) សម្រាប់ធ្វើឱ្យមុខជំនួញរបស់គាត់រីកចំរើន។ នៅពេលដែលប្រាក់សន្សំរបស់គាត់បានយកទៅវិនិយោគហើយបានចំណេញ ពេលនោះប្រាក់ក៏កើនឡើង ជាហេតុធ្វើឱ្យគាត់មានការសម្រេចចិត្តទៅលើមុខជំនួញកាន់តែប្រយ័ត្នប្រយែង។ ជំនួញរបស់គាត់រីកចម្រើនជាបន្តធ្វើឱ្យគាត់មានទ្រព្យធនកាន់តែច្រើន។

បុរសទី ៣ ជាកសិករ។ គាត់ជាអ្នកសន្សំប្រាក់ដ៏ល្អម្នាក់ ប៉ុន្តែប្រាក់សន្សំរបស់គាត់រក្សាទុកធ្វើជាទ្រព្យដែលបង្ហាញឱ្យឃើញថាគាត់ជាអ្នកមានប្រាក់ប៉ុណ្ណោះ ព្រោះគាត់មិនចំណាយប្រាក់នោះទេ។ ប្រាក់របស់គាត់មិនរីកចម្រើនទេព្រោះគាត់មិនបានយកទៅទិញដីពង្រីកមុខរបរនោះទេ ។ ប្រាក់នេះវាគ្រាន់តែបង្ហាញ ថាគាត់ជាអ្នកមានប្រាក់ប៉ុណ្ណោះ។ នេះបញ្ជាក់ថាគាត់ជាមនុស្សម្នាក់មាន "ទម្លាប់សន្សំប្រាក់បានល្អ" ប៉ុន្តែគាត់មិនមែនជាមនុស្សដែលឆ្លាតក្នុងការប្រើប្រាស់ប្រាក់នោះឡើយ។

ដូចនេះយើងអាចនិយាយបានថាបុរសទាំងនេះមានទម្លាប់ចំណាយ និង សន្សំប្រាក់ខុសៗគ្នា។ បុរសម្នាក់ៗសុទ្ធតែសន្សំប្រាក់ ប៉ុន្តែពួកគេជាអ្នកសន្សំប្រាក់ និង ជាអ្នកចំណាយប្រាក់តាមបែបខុសៗគ្នា។

**សកម្មភាពទី ៤ : ទម្លាប់ក្នុងការប្រើប្រាស់ប្រាក់របស់អ្នក** 🕑: **៣៥ នាទី**

១. គ្រូទុកឱកាសឱ្យសិស្ស ២ ឬ ៣ នាទី សរសេរចម្លើយសំណួរខាងក្រោមនៅក្នុង សៀវភៅកត់ត្រា :

- តើទម្លាប់ប្រើប្រាស់ប្រាក់ប្រភេទណាខ្លះដែលអ្នកចង់កែលំអ?
- ចូរពន្យល់ថាហេតុអ្វីបានជាអ្នកចូលចិត្តទម្លាប់បែបនេះ។

២. គ្រូឱ្យក្រុមសិស្សពិភាក្សាពីចម្លើយរបស់ពួកគេ។

| សកម្មភាពទី ៥ : ការពិភាក្សាអំពីការចំណាយប្រាក់ និង ការសន្សំប្រាក់ | ⏲: ១០ នាទី |
|---|---|

**១.** គ្រូសួរសិស្ស

- ចូរសរសេរ "ទម្លាប់ក្នុងការប្រើប្រាស់ប្រាក់" ដែលល្អ ។
- ចូរសរសេរពីលក្ខណសម្បត្តិនៃអ្នកចំណាយប្រាក់ និងអ្នកសន្សំប្រាក់ដែលឈ្លាសវៃ ។
- ចូរសរសេរពីលក្ខណសម្បត្តិនៃអ្នកចំណាយប្រាក់ និងអ្នកសន្សំប្រាក់ដែលមិនឈ្លាសវៃ ។

## មេរៀនទី៣ : គោលបំណង តម្លៃ និងអាទិភាព

🕑 **រយៈពេលបង្រៀន** ២ ម៉ោង

☑ **ការរៀបចំរបស់គ្រូមុនពេលបង្រៀន**

- ពិនិត្យមើលមេរៀនដោយហ្មត់ចត់
- ពិនិត្យមើលខ្លឹមសារក្នុងសៀវភៅសិស្ស ដើម្បីដឹងពីព័ត៌មាន និង សំណួរ
- សរសេរសំណួរនៅក្នុងសកម្មភាពទី៤នៅលើក្រដាសផ្ទាំងធំ
- សរសេរកម្រងសំណួរ និងខ្លឹមសារមេរៀន

📖 **សម្ភារៈ**

- ឯកសារណែនាំសម្រាប់គ្រូ
- សៀវភៅសិស្ស
- សម្ភារៈបង្រៀនដែលបានរៀបចំដូចបានរៀបរាប់ខាងលើ
- វត្ថុដែលអាចព្យួរលើផ្ទាំងក្រដាសបាន
- ដីស
- កម្រងសំណួរ និងខ្លឹមសារមេរៀន

☼ **លទ្ធផលសិក្សារំពឹងទុក**

ពេលរៀនមេរៀននេះចប់ សិស្សនឹងអាច :

- បង្ហាញពីភាពខុសគ្នារវាងគោលបំណងរយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង
- កំណត់គោលបំណងផ្ទាល់ខ្លួន៦យ៉ាង ។

**លំនាំនៃការបង្រៀន**

| សកម្មភាពទី ១: ករណីសិក្សារបស់តារា ដែលធ្វើជាអ្នកបម្រើ | 🕑: **៣០ នាទី** |
|---|---|

១. គ្រូបង្ហាញប្រធានបទ និងគោលបំណងមេរៀន

យើងមានផ្លូវជាច្រើនដែលដឹកនាំយើងឱ្យក្លាយទៅជាអ្វីមួយ និង ធ្វើអ្វីនៅពេលអនាគត ។ ទោះយ៉ាងនេះក្តី ប្រសិនបើយើងគ្រាន់តែបោះជំហានពីមួយថ្ងៃទៅមួយថ្ងៃដោយមិនបានគិតពីអនាគត នោះអនាគតរបស់យើង

ក៏មិនបានរៀបចំបានល្អប្រសើរដែរ ។ យើងត្រូវគិតពីអ្វីមួយដែលយើងចង់ធ្វើ ហើយបង្កើតគោលបំណង និងយុទ្ធវិធីដើម្បីធ្វើឱ្យសម្រេចគោលបំណងនោះ បើពុំនោះទេយើងនឹងក្លាយជាមនុស្សអសកម្មក្នុងជីវិត ។

២. គ្រូអានករណីសិក្សាមួយអំពីការកំណត់គោលបំណងផ្ទាល់ខ្លួន (បុគ្គល) និង ការសម្រេចគោលបំណង ។ ប្រសិនបើសិស្សមានសៀវភៅគេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេ ហើយអានករណីសិក្សានោះ ។

**តារា អ្នកបម្រើតាមភោជនីយដ្ឋាន**

តារាធ្លាប់ជាអ្នកបម្រើនៅក្នុងភោជនីយដ្ឋានខ្មែរមួយ ដែលស្ថិតនៅជិតកន្លែងដែលគេរស់នៅ ។ នេះគឺជាមុខរបរដំបូងរបស់តារានៅពេលរៀនចប់មធ្យមសិក្សា ។ តារារៀនពីរបៀបធ្វើការងារពីប្រធានរបស់គេ និងអ្នករួមការងារ ។ គាត់យកចិត្តទុកដាក់នូវអ្វីដែលធ្វើឱ្យភ្ញៀវពេញចិត្ត និងអ្វីដែលធ្វើឱ្យភ្ញៀវមិនសប្បាយចិត្ត ។ តារាចង់ធ្វើការនៅភោជនីយដ្ឋានមួយដែលល្អជាងនេះ ហើយស្ថិតនៅតំបន់ទេសចរណ៍ ព្រោះបានប្រាក់កម្រៃនិងប្រាក់បន្ថែមច្រើនពីភ្ញៀវ ។ នៅពេលតារាទៅដាក់ពាក្យនៅភោជនីយដ្ឋានមួយ ក្នុងបណ្ដាភោជនីយដ្ឋានជាច្រើន ទើបគេដឹងថាខ្លួនគេនៅពុំទាន់បានទទួលការបណ្ដុះបណ្ដាលគ្រប់គ្រាន់ និងពុំទាន់មានបទពិសោធន៍ក្នុងសេវាទទួលភ្ញៀវ ហើយក៏ពុំទាន់មានជំនាញភាសាអង់គ្លេសតាមដែលគេត្រូវការប្រើនៅទីនោះដែរ ។

៣. គ្រូបញ្ឈប់ការអាន ហើយសួរសិស្សថា ឥឡូវនេះតើជម្រើសរបស់តារាជាអ្វី? (ចម្លើយ :អាស្រ័យទៅលើការយល់ឃើញរបស់សិស្ស)

៤- គ្រូបន្តអានករណីសិក្សា

ថ្ងៃនេះតារាមានការខកចិត្តជាខ្លាំង នៅពេលគេបង្ហាញមុខនៅភោជនីយដ្ឋានថ្មី ។ ភ្ញៀវដែលធ្លាប់មកទីនេះសួរតារាថា ហេតុអ្វីបានជាឯងស្រងូតស្រងាត់ម្ល៉េះ ។ តារាបានប្រាប់ពីរឿងរ៉ាវទាំងអស់ដល់ភ្ញៀវ ។ ភ្ញៀវនោះបានប្រាប់តារាកុំឱ្យអស់សង្ឃឹម ឯងពិតជាម្ចាស់ហាងឱ្យតម្លៃថ្លៃជាមិនខាន ប្រសិន បើឯងខិតខំធ្វើការឱ្យបានល្អនោះ ។ ភ្ញៀវបាននិយាយទៀតថា "ឯងត្រូវទៅ (១) ទទួលការបណ្ដុះបណ្ដាលពីបទពិសោធន៍ក្នុងសេវាទទួលភ្ញៀវ (២) រៀនភាសាអង់គ្លេស"

៥.គ្រូបញ្ឈប់ការអាន ហើយសួរសិស្ស

- តើអ្នកយល់ដូចម្តេចចំពោះស្ថានភាពរបស់តារា? (ចម្លើយ : អាស្រ័យទៅលើការយល់ឃើញរបស់សិស្ស)
- តើជំនាញទាំងនេះ តារាអាចមានលទ្ធភាពរកបានដែរឬទេ? (ចម្លើយ : អាស្រ័យទៅលើការយល់ឃើញរបស់សិស្ស)

៦. គ្រូបន្តអានករណីសិក្សាតទៅទៀត

នៅល្ងាចនោះតារាទៅផ្ទះ ហើយនិយាយជាមួយក្រុមគ្រួសារ ។ គេធ្វើការសម្រេចចិត្តដោយគិតរកវិធី ហើយក៏ចាប់ផ្តើមធ្វើផែនការ ។ គេត្រូវការការគាំទ្រពីក្រុមគ្រួសារដើម្បីជួយធ្វើឱ្យ សម្រេចផែនការរបស់គេ ។ បងប្រុសរបស់គេបាននិយាយថា គាត់មានមិត្តភក្តិម្នាក់ជាអ្នកគ្រប់គ្រងភោជនីយដ្ឋានមួយតែវាមិនល្អដូចជាភោជនីយដ្ឋានដែលឯងបានទៅសម្ភាសនោះទេ ប៉ុន្តែកន្លែងនោះវាទាមទារអ្នកមានជំនាញល្អជាងនៅហាងដែលតារាកំពុងធ្វើបច្ចុប្បន្ន ។ បងរបស់តារាបានទូរស័ព្ទទៅមិត្តគាត់ ។ ប៉ុន្តែមិត្តគាត់និយាយថា នៅពេលនេះគាត់មិនទាន់ត្រូវការបុគ្គលិកថ្មីនៅឡើយទេ តែគាត់ឱ្យតារាត្រូវមកទីនោះ ២ ឬ ៣ ដង ក្នុងមួយសប្តាហ៍ ដើម្បីចូលរៀនក្នុងវគ្គបំប៉ន និងទទួលយកបទពិសោធន៍ការងារ ។ មិត្តរបស់គាត់អាចឱ្យតារាធ្វើការជាមួយបុគ្គលិកដែលមានសមត្ថភាពជាងគេ ដែលអាចឱ្យតារារៀនសូត្រពី របៀបធ្វើការងារពីបុគ្គលិកនោះ ។ តារាបានធ្វើការនៅហាងមិត្តរបស់បងគាត់ ទោះជាមិនបានទទួលប្រាក់ខែក៏ដោយ ។

តារានៅមានបញ្ហាភាសាអង់គ្លេស ។ គេសម្រេចចិត្តសន្សំប្រាក់មួយចំនួន ដោយត្រូវផ្លាស់ប្តូរទម្លាប់នៃការចំណាយ ។ គេត្រូវការប្រាក់១៥០ដុល្លាសម្រាប់បង់ថ្លៃវគ្គសិក្សាភាសាអង់គ្លេសក្នុងរយៈពេល៦ខែ នៅមជ្ឈមណ្ឌលភាសាអង់គ្លេសដែលនៅក្បែរនោះ ។ ដូច្នេះ គេត្រូវបង់២៥ដុល្លារ ក្នុងមួយខែ ។ ចាប់តាំងពីតារាធ្វើការស្ម័គ្រចិត្តនៅហាងថ្មីមួយរយៈមក គេពុំបានចំណាយប្រាក់ទៅលើការកំសាន្តសប្បាយ គេអាចសន្សំប្រាក់បាន ព្រោះតារាគិតថាបើគេមិនចំណាយប្រាក់សម្រាប់អាហារសម្រន់ជារៀងរាល់ថ្ងៃ ជិះកង់ទៅធ្វើការដោយមិនជិះម៉ូតូឌុប ទៅណាមកណាឈប់ទិញខោអាវថ្មី ព្រោះខោអាវថ្មីទាំងនេះមិនមែនជាតម្រូវការពិតប្រាកដ ព្រមទាំងរើផ្ទះទៅនៅជាមួយក្រុមគ្រួសារ ឈប់ជួលបន្ទប់ស្នាក់នៅជាមួយមិត្តភក្តិ នោះគេអាចសន្សំបានគ្រប់គ្រាន់សម្រាប់បង់ថ្លៃរៀនភាសាអង់គ្លេសរយៈពេល៦ខែ ដើម្បីអភិវឌ្ឍជំនាញភាសាអង់គ្លេសរបស់គេបន្ថែមទៀត ។

ប្រាំបីខែក្រោយមក តារាបានទៅដាក់ពាក្យជាថ្មីម្តងទៀតនៅភោជនីយដ្ឋានដែលមិនទទួលខ្លួនឱ្យធ្វើការ ។ ម្តងនេះអ្នកគ្រប់គ្រងមានការស្ងើចសរសើរ ដោយឃើញតារាមានការរីកចម្រើន ។ វគ្គបំប៉នរបស់តារាមិនទាន់ឆ្លើយតបទៅនឹងស្តង់ដារដែលភោជនីយដ្ឋាននោះចង់បាននៅឡើយទេ តែអ្នកគ្រប់គ្រងយល់ឃើញថាតារាជាមនុស្សមានឆន្ទៈចង់ធ្វើការ ។ ដូចនេះ អ្នកគ្រប់គ្រងបានឱ្យតារាធ្វើជា អ្នកយាមឡាន ប៉ុន្តែគាត់បានបញ្ជាក់ប្រាប់តារាថាបុគ្គលិកភាគច្រើនបានចាប់ផ្តើមការងារពីតួនាទីបែបនេះ ។ អ្នកគ្រប់គ្រងនោះនិយាយថា នេះមិនមែនជាតួនាទីដែលតារាចង់បាននោះទេ ប៉ុន្តែនេះជាការងារដែលខ្ញុំអាចផ្តល់ឱ្យបាន ។ តារាក៏យល់ព្រមទទួលការងារនោះ ។

ទោះជាយ៉ាងនេះក៏ដោយ ក៏តារាទទួលបានបទពិសោធន៍ និងចំណេះដឹងមួយចំនួនបន្ថែមទៀត ។ តារាកាន់តែមានភាពកក់ក្តៅជាមួយនឹងភ្ញៀវទេសចរ ហើយបានធ្វើទំនាក់ទំនងជាភាសាអង់គ្លេសទៀតផង ។ តារាខិតខំធ្វើការដោយយកចិត្តទុកដាក់ ។ ក្នុងរយៈពេល៦ខែក្រោយមក តារាត្រូវបានដំឡើងឋានៈជាអ្នករត់តុតាមចំណង់ និងដូចក្តីសង្ឃឹម ។

| សកម្មភាពទី ២ : ការពិភាក្សាលើករណីសិក្សា | ⏲: ៣០ នាទី |
|---|---|

**ការពិភាក្សា :** បន្ទាប់មកគ្រូសួរសិស្ស

- តើតារាមានគោលបំណងដូចម្តេច?(➢ ចម្លើយ : ចង់ធ្វើជាអ្នកបម្រើក្នុងភោជនីយដ្ឋានដែលល្អនៅក្នុងតំបន់ទេសចរណ៍)
- តើតារាមានបញ្ហាអ្វី? (➢ចម្លើយ : តារាមិនបានទទួលការបំប៉ន មិនមានបទពិសោធន៍គ្រប់គ្រាន់ ហើយមិនចេះភាសាអង់គ្លេស)
- តើនរណាជួយតារា? ជួយដោយរបៀបណា? (➢ចម្លើយរំពឹងទុក : ភ្ញៀវនៅក្នុងហាង អ្នកគ្រប់គ្រងហាងដែលតារាបានដាក់ពាក្យ ក្រុមគ្រួសារតារា បងប្រុសតារា មិត្តរបស់បងប្រុសតារា និង បុគ្គលិករបស់គាត់)
- តើតារាដោះស្រាយបញ្ហាដោយរបៀបណា? ( គ្រូបន្តសួររហូតសិស្សបញ្ចេញយោបល់អស់ លើកទឹកចិត្តសិស្ស ឱ្យរកចម្លើយថែមទៀត លើចំណុចដែលមិនទាន់បានលើក ។)

[➢ ចម្លើយរំពឹងទុក :

- o បង្កើតគោលបំណង
- o ធ្វើផែនការ
- o សន្សំប្រាក់
- o សួរព័ត៌មានពីអ្នកដទៃ
- o កាត់បន្ថយការចំណាយប្រាក់
- o មានឆន្ទៈធ្វើការងារស្ម័គ្រចិត្ត
- o មានឆន្ទៈក្នុងការបត់បែនក្នុងតួនាទីការងារដូចដែលគាត់បានយល់ព្រម]

☞ ប្រសិនបើអ្នកជាតារា តើអ្នកគិតដូចម្ដេច? (➢ចម្លើយ : អាស្រ័យទៅលើការយល់ឃើញរបស់សិស្ស)

☞ តើតារាបានបញ្ចប់គោលដៅសម្រាប់ជីវិតរបស់គាត់ហើយឬនៅ? (➢ចម្លើយ :  នៅ។ ឥឡូវគាត់បានសម្រេចគោលដៅនេះ ប៉ុន្តែគាត់នឹងបង្កើតគោលដៅថ្មីមួយទៀតសម្រាប់ ក្ដីស្រមៃថ្មី និង សេចក្ដីប្រាថ្នាចង់បានរបស់គាត់ដែលគាត់មាន ហើយនឹងធ្វើផែនការសម្រាប់គោលដៅទាំងនេះ។

| សកម្មភាពទី ៣: គោលដៅរបស់អ្នក | ◷: ៣០ នាទី |
|---|---|

១. តារាបង្កើតគោលបំណងមួយ ដែលជាសេចក្ដីប្រាថ្នាខ្ពស់ ហើយក៏ជាគោលដៅសម្រាប់អនាគតផងដែរ។ យើងអាចបង្កើតគោលដៅប្រចាំថ្ងៃ គោលដៅសម្រាប់សប្ដាហ៍ក្រោយ ខែក្រោយ និង ឆ្នាំក្រោយ។ គោលដៅទាំងនេះអាចទាក់ទងទៅនឹងមុខរបរ ការសិក្សា ទំនាក់ទំនងសង្គម អភិវឌ្ឍផ្ទាល់ខ្លួន និងផ្នែកផ្សេងៗ។ ឥឡូវនេះ យើងសាកល្បងបង្កើតគោលដៅមួយចំនួនសម្រាប់ខ្លួនយើង។

២. គ្រូឱ្យសិស្សសរសេរគោលដៅមួយចំនួនដែលគេគិតឃើញ :

[➢ ប្រភេទចម្លើយដែលអាចមាន :

- o ប្រឡងជាប់ ឬឡើងថ្នាក់
- o រៀនដេរប៉ាក់  ចាក់ម្ជុលទំពក់ ឬ ត្បាញ
- o រៀនដាំដំណាំឱ្យលូតលាស់ល្អ រហូតដល់បានផល
- o រៀនភាសាអង់គ្លេសឱ្យពូកែដើម្បីសន្ទនាជាមួយអ្នកស្ម័គ្រចិត្តនៅទីរួមខេត្តដែលជាជនបរទេស
- o លក់ដូរបន្តិចបន្តួចនៅផ្សារ
- o ទៅរៀនឱ្យទាន់ម៉ោង នៅសប្ដាហ៍ក្រោយ]

៣. គ្រូទុកពេល១០នាទី ឱ្យសិស្សសរសេរចំណុចដូចតទៅ :

☞ កំណត់គោលដៅរយៈពេលខ្លី (១-៤សប្ដាហ៍) ២ចំណុច

- កំណត់គោលដៅរយៈពេលមធ្យម (២-១១ខែ) ២ចំណុច
- កំណត់គោលដៅរយៈពេលវែង (១ឆ្នាំ ឬលើសពី១ឆ្នាំ) ២ចំណុច

៤. គ្រូឱ្យសិស្សសម្រេចចិត្ត ថាតើគោលដៅណាខ្លះដែលសំខាន់ជាងគេសម្រាប់ពួកគេ ដោយដាក់ពីលេខ១ដល់លេខ៦ (លេខ១ ជាគោលដៅសំខាន់ជាងគេ) ។

| សកម្មភាពទី៤: ការធ្វើផែនការដើម្បីធ្វើឱ្យសម្រេចគោលដៅ | ⏲: ១០ នាទី |
|---|---|

**ការពិភាក្សា**

គ្រូពន្យល់ប្រាប់សិស្សថា នៅមេរៀនក្រោយយើងនឹងពិនិត្យមើលឱ្យបានស៊ីជំរៅទៅលើគោលដៅ២ ជាអាទិភាពដំបូងដែលមាននៅក្នុងតារាង។ សម្រាប់កិច្ចការផ្ទះគ្រូឱ្យសិស្សគិត និង សរសេរចម្លើយសម្រាប់សំណួរដែលមានដូចខាងក្រោមនៅក្នុងសៀវភៅកត់ត្រា (អាចមើលព័ត៌មាននេះនៅក្នុងសៀវភៅ) ។

- តើយើងត្រូវមានការគាំទ្រ ឬ សញ្ញាប័ត្រអ្វីខ្លះ ដើម្បីសម្រេចគោលដៅនេះ?
- តើយើងអាចធ្វើអ្វីខ្លះ ដើម្បីធ្វើឱ្យសម្រេចគោលដៅនេះ?
- តើធនធានអ្វីខ្លះដែលយើងត្រូវការដើម្បីធ្វើឱ្យសម្រេចគោលដៅនេះ?
- តើយើងអាចកំណត់វិធីមួយចំនួនដែលអាចសន្សំប្រាក់ ដើម្បីធ្វើឱ្យសម្រេចគោលដៅនេះបានឬទេ?
- តើយើងត្រូវដើរតាមជំហានអ្វីខ្លះទៀត ដើម្បីធ្វើឱ្យសម្រេចគោលដៅនេះ?
- តើអ្នកណាអាចជួយផ្តល់ព័ត៌មានឱ្យយើង ឬជួយយើងក្នុងការធ្វើផែនការដើម្បីធ្វើឱ្យសម្រេចគោលដៅនេះ?
- តើមានចំណុចអ្វីខ្លះដែលយើងអាចរៀនសូត្រពីតារា ដើម្បីពង្រឹងផែនការនេះ?

| កិច្ចការផ្ទះ |
|---|

- សិស្សត្រូវឆ្លើយសំណួរដែលមាននៅក្នុងសៀវភៅរបស់គេសម្រាប់គោលដៅ២ ដែលជាអាទិភាពដំបូងក្នុងចំណោមគោលដៅទាំង ៦ ដែលគេបានសរសេរ ។

## មេរៀនទី ៤ : ទម្លាប់នៃការចំណាយប្រាក់

**រយៈពេលបង្រៀន** ២ ម៉ោង

### ☑ ការរៀបចំរបស់គ្រូមុនពេលបង្រៀន

- អាន និងពិនិត្យមើលមេរៀនដោយហ្មត់ចត់
- ពិនិត្យមើលខ្លឹមសារក្នុងសៀវភៅសិស្ស ដើម្បីដឹងពីព័ត៌មាន និង សំណួរ
- សរសេរលក្ខណៈនៃការសម្ដែងតួលើក្រដាស សម្រាប់សកម្មភាពទី២
- សរសេរកម្រងសំណួរ និងខ្លឹមសារមេរៀន។

### សម្ភារៈ

- ឯកសារណែនាំសម្រាប់គ្រូ
- សៀវភៅសិស្ស
- សម្ភារៈបង្រៀនដែលបានរៀបចំខាងលើ
- ដីស
- ផ្ទាំងក្រដាសធំដែលរៀបចំ និងរបស់ដែលអាចព្យួរផ្ទាំងក្រដាសបាន
- កម្រងសំណួរ និងខ្លឹមសារមេរៀន។

### ☼ លទ្ធផលសិក្សារំពឹងទុក

ពេលរៀនមេរៀននេះចប់ សិស្សនឹងអាច :

- កត់ត្រាពីតម្រូវការ និង ជំហានក្នុងការធ្វើឱ្យសម្រេចគោលដៅខាងលើ
- បង្ហាញលក្ខណសម្បត្តិនៃទម្លាប់ចំណាយប្រាក់ដែលឈ្លាសវៃ មិនឈ្លាសវៃ (ល្អ និងមិនល្អ) ដល់អ្នកណាម្នាក់ដែលចង់សន្សំប្រាក់។

**លំនាំនៃការបង្រៀន**

| | |
|---|---|
| សកម្មភាពទី ១: ការធ្វើផែនការតាមដានដើម្បីធ្វើឱ្យសម្រេចគោលដៅ | ⏲: ៣០ នាទី |

១. គ្រូលើកឧទាហរណ៍ពីគោលដៅមួយបង្ហាញដល់សិស្ស
- គ្រូឱ្យសិស្សម្នាក់ផ្ដល់ឧទាហរណ៍ពីគោលដៅមួយ
- គ្រូឱ្យសិស្សចូលរួមផ្ដល់ចម្លើយចំពោះ សំណួរខាងក្រោម :
  - o តើយើងត្រូវមានការគាំទ្រ ឬ សញ្ញាប័ត្រអ្វីខ្លះ ដើម្បីសម្រេចគោលដៅនេះ?
  - o តើយើងអាចធ្វើអ្វីខ្លះ ដើម្បីធ្វើឱ្យសម្រេចគោលដៅនេះ?
  - o តើធនធានអ្វីខ្លះដែលយើងត្រូវការដើម្បីសម្រេចគោលដៅនេះ?
  - o តើយើងអាចកំណត់វិធីមួយចំនួនដែលអាចសន្សំប្រាក់ ដើម្បីធ្វើឱ្យសម្រេចគោលដៅនេះបានឬទេ?
  - o តើយើងត្រូវដើរតាមជំហានអ្វីខ្លះទៀត ដើម្បីធ្វើឱ្យសម្រេចគោលដៅនេះ?
  - o តើអ្នកណាអាចជួយផ្ដល់ព័ត៌មានឱ្យយើង ឬជួយយើងក្នុងការធ្វើផែនការដើម្បីធ្វើឱ្យសម្រេចគោលដៅនេះ?
  - o តើមានចំណុចអ្វីខ្លះដែលយើងអាចរៀនសូត្រពីតារា ដើម្បីពង្រឹងផែនការនេះ?

២. គ្រូឱ្យសិស្សផ្ដល់ឧទាហរណ៍១ ដើម្បីធ្វើការពិភាក្សារួមគ្នា ។

៣. គ្រូឱ្យសិស្សធ្វើការជាដៃគូ ឬ ជាក្រុមតូចដែលមានគ្នា ៤ នាក់ ដើម្បីធ្វើការកែលំអចម្លើយសម្រាប់កិច្ចការរបស់គេ ។

៤. គ្រូប្រាប់សិស្សថាពួកគេអាចធ្វើកិច្ចការនេះនៅផ្ទះ ព្រោះលំហាត់នេះត្រូវពិនិត្យនៅសប្ដាហ៍ក្រោយ ។

| | |
|---|---|
| សកម្មភាពទី ២ : ការសម្ដែងតួពីទម្លាប់នៃការចំណាយប្រាក់ | ⏲: ៥០ នាទី |

១. គ្រូបង្ហាញពីប្រធានបទស្ដីពីការចំណាយប្រាក់ដែលនឹងត្រូវលើកមកពិភាក្សានៅថ្ងៃនេះ ។

យើងបានពិភាក្សាពីមុនមកហើយអំពីលក្ខណៈសម្គាល់របស់អ្នកចំណាយប្រាក់ និងអ្នកសន្សំប្រាក់ ។ យើងក៏បានពិភាក្សាផងដែរពីវត្ថុដែលជាចំណង់ និងតម្រូវការចាំបាច់ ព្រមទាំងគោលដៅមួយចំនួន ។ នៅថ្ងៃនេះ យើងនឹងចាប់ផ្ដើមពិភាក្សាពីមូលហេតុដែលប្រធានបទទាំងនេះមានទំនាក់ទំនងគ្នា ។

២. គ្រូបែងចែកសិស្សជា៤ក្រុម ហើយឱ្យសិស្សរៀបចំការសម្ដែងតួ ទៅតាមតម្រូវការដូចខាងក្រោម :

- គ្រូចែកក្រដាស ឱ្យក្រុមនីមួយៗដើម្បីកំណត់តួអង្គ និងស្ថានភាពសាច់រឿងទូទៅដែលក្រុមត្រូវសម្តែង។ ប្រសិនបើសិស្សមានសៀវភៅគេអាចមើលខ្លឹមសារទាំងនេះ នៅក្នុងសៀវភៅរបស់គេ។

**ការសម្តែងតួទី១ :** នៅពេលដើរតាមផ្លូវ វណ្ណៈរើសបានក្រដាសប្រាក់ ៥ ម៉ឺនរៀលមួយសន្លឹក។ គាត់សប្បាយចិត្តណាស់ ព្រោះគាត់កំពុងតែព្យាយាមសន្សំប្រាក់ដើម្បីទិញនាឡិកាដៃមួយ។ នៅពេលវណ្ណៈនិយាយប្រាប់សុផលពីសំណាងរបស់គាត់ ដែលរើសបានប្រាក់នេះ ធ្វើឱ្យមិត្តគាត់សើច។

**ការសម្តែងតួទី ២ :** ឆ្នាំនេះសីហាបានអានសៀវភៅច្រើន ។ គាត់គិតរកទិញវ៉ែនតាសម្រាប់ មើលអក្សរ ដើម្បីកុំឱ្យភ្នែកគាត់ឡើយហត់។ គាត់ឃើញហាងមួយមានលក់វ៉ែនតាដែលមានតម្លៃថោកជាងហាងដទៃ។ គាត់នៅឆ្ងល់អំពីគុណភាពរបស់វា តែគាត់គិតថាបើគាត់ទិញវាក្នុងតម្លៃថោកនោះ គាត់នឹងអាចសល់ប្រាក់ខ្លះ ដើម្បីទៅជួបមិត្តភក្តិនៅហាងកាហ្វេ។

**ការសម្តែងតួទី៣ :** រៀងរាល់ថ្ងៃ ពេលចេញពីសាលាមិត្តភក្តិសុធាតែងឃាត់សុធាមិនឱ្យទៅលេងបៀ។ សុធាបានសន្សំប្រាក់ដែលចំណេញពីការលក់នំប៉័ង និង កម្រៃដែលបានមកពីការធ្វើការងារផ្ទះឱ្យម្តាយមីង។ ប្រាក់ដែលគេសន្សំមិនទាន់បានគ្រប់ចំនួន សម្រាប់ទិញកង់ថ្មីដែលគេចង់បានឆាប់នេះឡើយ។ ដូចនេះគេក៏សម្រេចចិត្តលេងល្បែងជាមួយមិត្តភក្តិ។

**ការសម្តែងតួទី៤ :** ឪពុកមាស៊ីផុងមកលេងផ្ទះស៊ីផុង ហើយបានឱ្យប្រាក់គេ ២៥ ០០០រៀល។ ស៊ីផុង កំពុងគិតថាតើគេត្រូវយកប្រាក់នេះទៅទិញអ្វី។ គេព្យាយាមគិតពិចារណាពីជម្រើស ដែលគេត្រូវចំណាយប្រាក់។

- សិស្សរៀបចំការសម្តែងតួ ដើម្បីបង្ហាញពីការសម្រេចចិត្តទាក់ទងនឹងរបៀបចំណាយប្រាក់។
- គ្រូឱ្យសិស្សតាមក្រុមអានគោលការណ៍ណែនាំរបស់ខ្លួន បន្ទាប់មកបំបែកសិស្សជាពីរក្រុម។ (១) ក្រុមទី១សម្តែងបង្ហាញពីអាកប្បកិរិយាអវិជ្ជមាន (សម្រេចចិត្តធ្វើជាអ្នកចំណាយប្រាក់មិន ឈ្លាសវៃ ឬអ្នកចំណាយប្រាក់មិនត្រឹមត្រូវ) និង (២) ក្រុមទី២ បង្ហាញពីអាកប្បកិរិយាវិជ្ជមាន (អ្នកចំណាយប្រាក់ត្រឹមត្រូវឈ្លាសវៃ)។
- ការសម្តែងមិនឱ្យលើសពី ១០ នាទី

៣. គ្រូសួរសិស្ស

- ក្រោយពីបញ្ចប់ការបង្ហាញពីចំណុចវិជ្ជមាននិងអវិជ្ជមាន សិស្សទាំងអស់ត្រូវកំណត់លក្ខណសម្បត្តិចំណាយប្រាក់ដែលឈ្លាសវៃ និងមិនឈ្លាសវៃ ដោយពន្យល់ពីមូលហេតុ ។

| សកម្មភាពទី ៣ : ការសម្គាល់ពីលក្ខណៈអ្នកចំណាយប្រាក់ដែលល្អ និងមិនល្អ | ⏲: ២០ នាទី |
| --- | --- |

- គ្រូទុកពេល៥នាទីឱ្យសិស្សសរសេរលក្ខណសម្បត្តិបីយ៉ាងរបស់អ្នកចំណាយប្រាក់ដែលល្អ ឬឈ្លាសវៃ និងលក្ខណសម្បត្តិបីយ៉ាងរបស់អ្នកចំណាយប្រាក់ដែលមិនល្អ ឬមិនឈ្លាសវៃ ។
- គ្រូឱ្យសិស្សចែករំលែកគំនិតរបស់ខ្លួន បង្កើតបញ្ជីស្តីពីលក្ខណសម្បត្តិសំខាន់ៗរបស់អ្នកចំណាយប្រាក់ និង អ្នកសន្សំប្រាក់ ។
- គ្រូទុកពេល ៥ នាទី ឱ្យសិស្សពិភាក្សាគ្នាជាដៃគូ ដើម្បីគិតពីស្ថានភាពដែលពួកគេធ្លាប់ចំណាយប្រាក់ដែលឈ្លាសវៃ ឬ ចំណាយប្រាក់ដែលមិនឈ្លាសវៃ ។
- គ្រូឱ្យដៃគូ ២ ឬ៣ ឡើងរាយការណ៍ ។

## មេរៀនទី៥ : ការបង្កើតសៀវភៅកត់ត្រាការចំណាយប្រចាំថ្ងៃ

**រយៈពេលបង្រៀន** ២ ម៉ោង

**ការរៀបចំរបស់គ្រូមុនពេលបង្រៀន**

- អាន និងពិនិត្យមើលមេរៀនដោយហ្មត់ចត់
- ពិនិត្យមើលខ្លឹមសារក្នុងសៀវភៅសិស្ស ដើម្បីដឹងពីព័ត៌មាន និង សំណួរ
- សរសេរតារាងកំណត់ត្រាចំណាយលើផ្ទាំងក្រដាសធំ សម្រាប់សកម្មភាពទី៤
- សរសេរកម្រងសំណួរ និងខ្លឹមសារមេរៀន។

**សម្ភារៈ**

- ឯកសារណែនាំសម្រាប់គ្រូ
- សៀវភៅសិស្ស
- សម្ភារៈបង្រៀនដែលបានរៀបចំខាងលើ
- ផ្ទាំងក្រដាសធំ និងប៊ិចហ្វឺត
- កម្រងសំណួរ និងខ្លឹមសារមេរៀន

**លទ្ធផលសិក្សារំពឹងទុក**

ពេលរៀនមេរៀននេះចប់ សិស្សនឹងអាច :

- ធ្វើសៀវភៅកត់ត្រាចំណាយប្រចាំថ្ងៃ ។

**លំនាំនៃការបង្រៀន**

| សកម្មភាពទី ១: ការបង្ហាញពីការប្រើប្រាស់សៀវភៅកត់ត្រាការចំណាយប្រចាំថ្ងៃ | **: ១៥ នាទី** |
|---|---|

១. គ្រូបង្ហាញពីប្រធានបទមេរៀន

- កាលពីមេរៀនមុន យើងបានពិភាក្សាគ្នាពីទម្លាប់នៃការចំណាយប្រាក់។ យើងក៏បានពិភាក្សាពីប្រភេទនៃអ្នកចំណាយប្រាក់ដែលយើងចង់រៀនសូត្រតាម។ ដូចនេះចូរផ្តល់ ឧទាហរណ៍ពីប្រភេទអ្នកចំណាយប្រាក់ដែលគេចង់រៀនសូត្រតាម?
- តើអ្នកចំណាយប្រាក់ដែលវៃឆ្លាតមានន័យដូចម្តេច?
- ចូរលើកឧទាហរណ៍ពីអ្នកចំណាយប្រាក់ដែលមិនវៃឆ្លាត?

# ឯកសារសម្រាប់គ្រូ

- ដើម្បីធ្វើខ្លួនជាអ្នកចំណាយប្រាក់ដែលវៃឆ្លាត និង ក្លាយខ្លួនជាអ្នកសន្សំប្រាក់ដ៏ល្អ យើងត្រូវតែយកចិត្តទុកដាក់ដោយប្រុងប្រយ័ត្នពីរបៀបចំណាយប្រាក់ និង គិតឱ្យបានល្អិតល្អន់ពីវិធីចំណាយប្រាក់ ដោយយើងត្រូវប្រៀបធៀបការចំណាយប្រាក់សម្រាប់តម្រូវការ សម្រាប់ចំណង់ និង អ្វីជាគោលដៅនៃការចំណាយ ។

| សកម្មភាពទី ២: កំណត់ត្រាចំណាយប្រចាំថ្ងៃ (ជំហានទី ១) | : **២៥ នាទី** |
|---|---|

១. គ្រូបង្ហាញទម្រង់កំណត់ត្រាចំណាយប្រចាំថ្ងៃ ។ សិស្សចម្លងតារាងនេះចូលសៀវភៅ ។ តារាងខាងស្តាំបំពេញនៅពេលក្រោយ ។ (ប្រសិនបើសិស្សមានសៀវភៅគេអាចមើលខ្លឹមសារនៅក្នុងសៀវភៅ) ។

| **កាលបរិច្ឆេទ** | **ប្រភេទទំនិញ** | **តម្លៃ** | | | | |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | **ចំនួនសរុបប្រចាំសប្តាហ៍:** | $ | | | | |

២. គ្រូពន្យល់

- ចូរសង្កេតមើលតារាងនេះ ជួរទី(១) ប្រាប់ពីកាលបរិច្ឆេទ នៃការទិញទំនិញ( ឬ ការចំណាយ )ជួរទី(២) ប្រាប់ពីមុខទំនិញដែលអ្នកបានទិញ (ការទិញទំនិញ ឬ ការប្រើសេវាកម្ម) និង ជួរទី(៣) ប្រាប់ពីតម្លៃទំនិញ ។
- ក្នុងតារាងនេះ ក្រៅពីមុខទំនិញ គួរតែបញ្ចូលថ្លៃសេវាផ្សេងៗផងដែរ ដូចជាថ្លៃម៉ូតូឌុបឬថ្លៃកាត់សក់
- នៅក្នុងកំណត់ត្រាចំណាយប្រចាំថ្ងៃ អ្នកត្រូវកត់ចូលនូវរាល់ការចំណាយនោះ ។

៣. គ្រូពន្យល់សិស្សពីរបៀបបំពេញតារាងកត់ត្រាការចំណាយប្រចាំថ្ងៃ ។

| កាលបរិច្ឆេទ | ប្រភេទទំនិញ | តម្លៃ |
|---|---|---|
| | | |

៤. គ្រូចែកសិស្សជាក្រុមតូច ។ សិស្សតាមក្រុមចាប់ផ្ដើមអនុវត្តកត់ត្រាការចំណាយប្រចាំថ្ងៃរួមគ្នា ដោយឆ្លើយនឹង សំណួរដូចខាងក្រោម ។

- នៅអំឡុង២ ឬ ៣ សប្ដាហ៍ចុងក្រោយនេះ តើក្នុងមួយថ្ងៃៗអ្នកបានទិញ ឬ បានចំណាយអ្វីខ្លះ?
- ចូរអ្នកស្មានថ្ងៃដែលទិញ ឬ ចំណាយប្រាក់នោះ?
- តើទំនិញទាំងនោះតម្លៃប៉ុន្មាន?
- គ្រូពន្យល់ : ជាការប្រសើរណាស់ដែលយើងត្រូវធ្វើការប៉ាន់ស្មានទៅលើព័ត៌មានទាក់ទងនឹងការទិញទំនិញទាំងនេះ ។ការប៉ាន់ស្មាននេះវាមិនអាចត្រូវបាន ១០០% ទេ ។

៥. ក្រុមសិស្សបង្កើតការកត់ត្រាការចំណាយផ្ទាល់ខ្លួន ដែលគេអាចចងចាំបានកាលពី ២ ឬ ៣ សប្ដាហ៍មុន ដោយបំពេញក្នុងតារាង ។

| សកម្មភាពទី ៣: កត់ត្រាការចំណាយប្រចាំថ្ងៃ (ជំហានទី ២) | ⏱: **១៥ នាទី** |
|---|---|

១. គ្រូឱ្យសិស្សដាក់ឈ្មោះក្នុងជួរពីរទៀត "**ចំណង់**" និង "**តម្រូវការ**"

| កាលបរិច្ឆេទ | ប្រភេទទំនិញ | តម្លៃ | ចំណង់ | តម្រូវការ |
|---|---|---|---|---|
| | | | | |

២. បន្ទាប់មក គ្រូឱ្យសិស្សពិនិត្យមើលតារាងរបស់ខ្លួន ហើយកំណត់ការចំណាយនីមួយៗ ថាតើវាជា "**ចំណង់**" ឬ "**តម្រូវការ**" ដោយដាក់សញ្ញាខ្វែង “X” ។

៣. ក្រុមសិស្សកំណត់ការចំណាយព្រមទាំងបញ្ជាក់ហេតុផល ។

**សកម្មភាពទី ៤: កត់ត្រាការចំណាយប្រចាំថ្ងៃ (ជំហានទី ៣)** ⏲: **១៥ នាទី**

១-គ្រូឱ្យសិស្សដាក់ឈ្មោះលើជួរចុងក្រោយដែលមានពាក្យ " **គោលបំណង** " ។

| កាលបរិច្ឆេទ | ប្រភេទទំនិញ | តម្លៃ | ចំណង់ | តម្រូវការ | គោលបំណង |
|---|---|---|---|---|---|
| | | | | | |

២. គ្រូឱ្យសិស្សពិនិត្យមើលទៅលើគោលបំណងរបស់ពួក ដោយបញ្ជាក់ពីជំហាន និង តម្រូវការដែលធ្វើឱ្យសម្រេចគោលបំណងនោះ ។

៣. ឱ្យសិស្សសរសេរនៅក្នុងជួរគោលបំណង

- "**ចាស / បាទ**" ប្រសិនបើការចំណាយនោះវាជួយគាំទ្រដល់ការធ្វើឱ្យសម្រេចគោលដៅដែលបានកំណត់ ។
- " **ទេ** " ប្រសិនបើការចំណាយនោះវាមិនជួយគាំទ្រដល់ការធ្វើឱ្យសម្រេចគោលដៅដែលបានកំណត់ ។

**សកម្មភាពទី ៥: ការពិភាក្សាលើសៀវភៅកត់ត្រាការចំណាយប្រចាំថ្ងៃ** ⏲: **៣០ នាទី**

១. សិស្សពិភាក្សាទម្លាប់នៃការចំណាយ និងធ្វើការសន្និដ្ឋានថា តើទម្លាប់ទាំងនេះទាក់ទងនឹង "ចំណង់" "តម្រូវការ" និង " គោលបំណង " ដូចម្តេចខ្លះ ។

➢ ចម្លើយរំពឹងទុក :

- o ពួកខ្ញុំចំណាយប្រាក់ច្រើនពេកទៅលើអ្វីដែលពួកខ្ញុំចង់បាន ទោះជាដឹងថាចំណាយនេះវាមិនគាំទ្រដល់ គោលបំណងរបស់ពួកខ្ញុំក៏ដោយ ។
- o ពួកខ្ញុំចំណាយប្រាក់ទៅលើអ្វីដែលជាតម្រូវការ ច្រើនជាងអ្វីដែលជាចំណង់ ប៉ុន្តែពុំបានចំណាយប្រាក់ទៅលើរបស់ដែលទាក់ទងទៅនឹងគោលបំណងរបស់ពួកខ្ញុំនោះឡើយ ។
- o ការចំណាយមួយចំនួនស្របគ្នាទៅនឹងគោលបំណងរបស់ពួកខ្ញុំ ព្រោះពួកខ្ញុំគិតថាការចំណាយប្រាក់នេះត្រឹមត្រូវ ។

២. ឱ្យសិស្សពិនិត្យក្នុងសៀវភៅកត់ត្រាការចំណាយប្រចាំថ្ងៃដែលគេបានអនុវត្តខាងលើ (១) តើអ្នកបានចំណាយប្រាក់មានលក្ខណៈកាន់តែឈ្លាសវៃ ឬ (២) អ្នកចំណាយប្រាក់មិនឈ្លាសវៃ ។ សិស្សអាចលើកដៃដើម្បីឆ្លើយសំណួរនេះ ។

៣. គ្រូទុកពេល៥-១០ នាទី ឱ្យសិស្សពិនិត្យមើលសៀវភៅកត់ត្រាការចំណាយប្រចាំថ្ងៃរបស់គេ ដោយ ខ្លួនឯង និង បំពេញកិច្ចការដូចខាងក្រោមៈ

- ដាក់ឈ្មោះតម្លៃទំនិញដែលអ្នកកំណត់ថាជាប្រភេទទំនិញ " ចំណាយថេរ " " ចំណាយប្រែប្រួល " " ចំណាយមិនបានគ្រោងទុក " ឬ " ការចំណាយលើវត្ថុប្រណិត " ។
- ដឹកនាំឱ្យមានការពិភាក្សាផ្លាស់ប្តូរយោបល់ដោយលើកជាឧទាហរណ៍ និង ពន្យល់ពីហេតុផល ។

៤. គ្រូសួរសិស្ស

- ចូរលើកឧទាហរណ៍ពី " ចំណាយថេរ" "ចំណាយប្រែប្រួល" "ចំណាយមិនបានគ្រោងទុក" និង "ចំណាយលើវត្ថុប្រណិត " ដែលមាននៅក្នុងសៀវភៅកត់ត្រាការចំណាយប្រចាំថ្ងៃរបស់អ្នកហើយ ពន្យល់ពីមូលហេតុដែលគេបានសម្រេចចិត្តដាក់ឈ្មោះបែបនេះ ។
- ចូលរួមចែករំលែកគំនិតជាមួយគ្នាពីព័ត៌មានដែលខុសគ្នាទាក់ទងនឹងការចំណាយកាលពីសប្តាហ៍មុន ។

**កិច្ចការផ្ទះ**

- រៀងរាល់ថ្ងៃនៃសប្តាហ៍ក្រោយ ចូរអ្នកធ្វើកំណត់ត្រាចំណាយប្រចាំថ្ងៃ ដោយកត់ត្រារាល់អ្វីដែលអ្នកបានចំណាយ ។
- ចូរអ្នកធ្វើចំណាត់ថ្នាក់បញ្ជាក់ប្រភេទនៃការចំណាយ ( "**តម្រូវការ** " ឬ " **ចំណង់** " ) ។
- ចូរអ្នកកត់ត្រាផងដែរ ពីការចំណាយដែលគាំទ្រដល់គោលដៅដែលគេបានកំណត់ ។

## មេរៀនទី៦ : ថវិកាផ្ទាល់ខ្លួន

**រយៈពេលបង្រៀន** ២ ម៉ោង

☑ **ការរៀបចំរបស់គ្រូមុនពេលបង្រៀន**

- អាន និងពិនិត្យមើលមេរៀនដោយហ្មត់ចត់
- ពិនិត្យមើលខ្លឹមសារក្នុងសៀវភៅសិស្ស ដើម្បីដឹងពីព័ត៌មាន និងសំណួរ
- គូសតារាងលំហូរសាច់ប្រាក់នៅលើក្រដាសផ្ទាំងធំ សម្រាប់សកម្មភាពទី ៣
- សរសេរកម្រងសំណួរ និងខ្លឹមសារមេរៀន។

**សម្ភារៈ**

- ឯកសារណែនាំសម្រាប់គ្រូ
- សៀវភៅសិស្ស
- សម្ភារៈបង្រៀនដែលបានរៀបចំខាងលើ
- ផ្ទាំងក្រដាសធំ និង ប៊ិចហ្វឺត
- កម្រងសំណួរ និងខ្លឹមសារមេរៀន។

☼ **លទ្ធផលសិក្សារំពឹងទុក**

ពេលរៀនមេរៀននេះចប់ សិស្សនឹងអាច :

- វិភាគអាកប្បកិរិយាក្នុងការចំណាយ
- កំណត់ជម្រើសផ្សេងៗក្នុងការចំណាយ
- គ្រោងថវិកាប្រចាំសប្ដាហ៍បែបងាយៗ
- ពិនិត្យតាមដានការចំណាយ
- កំណត់តម្លៃ ឬសារប្រយោជន៍ នៃការគ្រោងថវិកា
- បង្ហាញពីថវិកាដែលអាចមានការប្រែប្រួលនៅពេលខ្លះ។

**លំនាំនៃការបង្រៀន**

| សកម្មភាពទី ១: ការពិនិត្យការកត់ត្រាការចំណាយប្រចាំថ្ងៃ | **: ១៥ នាទី** |
|---|---|

# ឯកសារសម្រាប់គ្រូ

១. គ្រូសួរសិស្ស តើអ្នកណាមានចម្ងល់ ឬ បញ្ហា ឬ បទពិសោធន៍ដែលទាក់ទងនឹងសៀវភៅកំណត់ត្រាការចំណាយប្រចាំថ្ងៃដែលអ្នកបានរៀនពីសប្តាហ៍មុនដែរឬទេ?

២. គ្រូទុកពេល ៥នាទី ឱ្យសិស្ស ពិនិត្យមើលសៀវភៅកំណត់ត្រាការចំណាយប្រចាំថ្ងៃរបស់គេ និង ឆ្លើយសំណួរខាងក្រោម ៖

- តើអ្នកមានបំណងចង់ធ្វើអ្វីដែលប្លែកពីសប្តាហ៍មុនដែលទាក់ទងទៅនឹងការចំណាយប្រាក់ដែរឬទេ?

៣. គ្រូសួរសិស្ស

- ចូរលើកឧទាហរណ៍ពី "ចំណាយថេរ" "ចំណាយប្រែប្រួល" និង "ការចំណាយផ្សេងៗ" ដែលការចំណាយផ្សេងៗនេះស្ថិតក្នុង "ការចំណាយមិនបានគ្រោងទុក" ឬ "ការចំណាយលើវត្ថុប្រណិត" ដែល មានបញ្ជាក់នៅក្នុងសៀវភៅកំណត់ត្រាការចំណាយប្រចាំថ្ងៃរបស់អ្នក ព្រមទាំងប្រាប់ពីមូលហេតុផង (ហេតុអ្វីបានជាអ្នកដាក់ឈ្មោះបែបនេះ)។
  ចូរសរសេរព័ត៌មានទាំងនេះនៅលើក្តារខៀន ហើយរក្សា ទុកសម្រាប់ប្រើនៅសកម្មភាពទី ៣។
- ចែករំលែកដល់សិស្សទាំងអស់នូវអ្វីដែលគេមានបំណងចង់ធ្វើ ហើយប្លែកពីសប្តាហ៍មុនទាក់ទងនឹងការចំណាយប្រាក់។

៤. គ្រូពន្យល់

យើងតែងចំណាយប្រាក់យ៉ាងខ្ជះខ្ជាយដូចអ្វីដែលយើងគិតពេលនេះ ឬសព្វថ្ងៃនេះ។ ប្រសិនបើយើងឈប់ចំណាយប្រាក់ផ្តេសផ្តាស់ ហើយចាប់គិតពិចារណាពីតម្រូវការប្រាក់សម្រាប់ការប្រើប្រាស់យូរអង្វែង នោះយើងនឹងចាប់ផ្តើមពិនិត្យមើលការចំណាយរបស់យើងតាមវិធីផ្សេង ដោយធ្វើការចំណាយឱ្យមានការឈ្លាសវៃ។ ថ្ងៃនេះយើងនឹងរៀនអំពី ការធ្វើផែនការចំណាយរបស់យើង។ ការធ្វើផែនការចំណាយនេះហៅថាការគ្រោងថវិកា។

៥. គ្រូបង្ហាញអំពីវត្ថុបំណងមេរៀនថ្ងៃនេះ។

| សកម្មភាពទី ២ ៖ ហេតុអ្វីបានជាត្រូវបង្កើតឱ្យមានតារាងគ្រោងថវិកាផ្ទាល់ខ្លួន? | ⏲: **១៥ នាទី** |
|---|---|

គ្រូសួរសិស្ស

- ហេតុអ្វីបានជាចាំបាច់ត្រូវបង្កើតតារាងគ្រោងថវិកា?

  [➢ចម្លើយរំពឹងទុក ៖ ដើម្បីធានាថាប្រាក់របស់យើងមានគ្រប់គ្រាន់ល្មម ដើម្បីចំណាយទៅលើវត្ថុដែលយើងត្រូវការ។ ដើម្បីធ្វើផែនការ និងសន្សំប្រាក់សម្រាប់ពេលអនាគត។ ដើម្បីចំណាយប្រាក់

ដោយឈ្លាសវៃ តាមរយៈការពិនិត្យតាមដានពីចំនួនប្រាក់ចំណូល និងចំណាយ ។ ដើម្បីយល់ឱ្យកាន់តែច្បាស់អំពីស្ថានភាពថវិកា ។ ការធ្វើដូចនេះយើងអាចពិនិត្យទៅលើជម្រើសរបស់យើងសម្រាប់ពេលអនាគត ។]

- តើអ្នកណាធ្លាប់រៀបចំតារាងគ្រោងថវិកាដែរឬទេ? ឬ ធ្លាប់ ឃើញតារាងគ្រោងថវិកាដែរ ឬទេ?

- តើតារាងគ្រោងថវិកាមានអ្វីខ្លះ?

  - គ្រូពន្យល់ : តារាងគ្រោងថវិកាមាន៥ផ្នែកសំខាន់ :
    - o បញ្ជីចំណូល
    - o បញ្ជីចំណាយ
    - o តួលេខថវិកា (ប៉ាន់ស្មាន) សម្រាប់ចំណូល និង ចំណាយ
    - o តួលេខជាក់ស្តែងសម្រាប់ចំណូល និង ចំណាយ
    - o ផលដក ឬ សមតុល្យរវាងចំណូល និង ចំណាយ

| សកម្មភាពទី ៣: ការបង្កើតប្រភេទតារាងគ្រោងថវិកាផ្ទាល់ខ្លួន | : ៤០ នាទី |
|---|---|

១. គ្រូបង្ហាញគំរូតារាងគ្រោងថវិកាជាមូលដ្ឋាន។ ការបង្កើតតារាងគ្រោងថវិការផ្ទាល់ខ្លួនរបស់យើង យើងត្រូវបន្ថែមជួរឱ្យបានច្រើន ។

២. គ្រូពន្យល់ៈ នៅក្នុងសៀវភៅកំណត់ត្រាការចំណាយប្រចាំថ្ងៃរបស់យើង យើងបានកត់ត្រាមុខចំណាយជាច្រើន។ ចូរធ្វើចំណាត់ប្រភេទចំណាយទាំងនោះ?

**តារាងគ្រោងថវិកាសម្រាប់ថវិកាផ្ទាល់ខ្លួន**

| ប្រាក់ចំណូល និង ចំណាយ | ថវិកា | ចំនួនជាក់ស្តែង | ភាពខុសគ្នា |
|---|---|---|---|
| **ចំណូលដែលរំពឹងទុក** | | | |
| ប្រាក់ឧបត្ថម្ភ (allowance) | | | |
| ប្រាក់ធ្វើការងារតាមផ្ទះ (Chores) | | | |
| ប្រាក់ខែ (Jobs) | | | |
| | | | |
| **ចំណូលប្រចាំសប្តាហ៍សរុប** | | | |

| | | | |
|---|---|---|---|
| **ចំណាយដែលរំពឹងទុក** | | | |
| ចំណាយថេរ | | | |
| • | | | |
| • | | | |
| ចំណាយប្រែប្រួល | | | |
| • | | | |
| • | | | |
| ចំណាយផ្សេងៗ | | | |
| • | | | |
| • | | | |
| **ចំណាយប្រចាំសប្តាហ៍សរុប** | | | |
| **ប្រាក់សន្សំសរុប (ចំណូលដកចំណាយ)** | | | |

៣. តើប្រភេទមុខចំណាយអ្វីខ្លះដែលអ្នកគិតថាត្រូវប្រើនៅក្នុងតារាងគ្រោងថវិការបស់អ្នក? ឧទាហរណ៍: ការចំណាយប្រាក់ទៅលើថ្លៃជិះម៉ូតូឌុប ថ្លៃចាក់សាំងម៉ូតូ ថ្លៃជិះម៉ូតូកង់បី ថ្លៃទិញសំបកកង់ម៉ូតូរបស់អ្នក ត្រូវដាក់ក្នុងប្រភេទ "ការចំណាយលើមធ្យោបាយដឹកជញ្ជូន" ។

➢ នេះជាឧទាហរណ៍មួយចំនួននៃប្រភេទមុខចំណាយដែលជាក់លាក់ :

- ➢ ចម្លើយរំពឹងទុក :
  - o ជួលផ្ទះ
  - o ថ្លៃប្រើប្រាស់សេវាកម្មសាធារណៈ( ថ្លៃទឹក ភ្លើង ថ្លៃជួសជុលលូ ថ្លៃសំរាម...)
  - o ការសិក្សា( ថ្លៃសាលា សម្ភារៈសិក្សា សៀវភៅសរសេរ ប៊ិច ដែកឈាន. . . )

- o ការធ្វើដំណើរ( សាំង តាក់ស៊ី ម៉ូតូឌុប កៅស៊ូកង់. . .)
- o ម្ហូបអាហារ (តម្រូវការចាំបាច់)
- o សំលៀកបំពាក់ (ប្រភេទសំលៀកបំពាក់ផ្សេងៗ)
- o ការកំសាន្ត (ភាពយន្ត ថាសចម្រៀង បាយពេលល្ងាចជាមួយមិត្តភក្តិ ...)
- o បង់ប្រាក់កម្ចី
- o ការសំអាងខ្លួន (កាត់សក់ សាប៊ូដុសខ្លួន សាប៊ូកក់សក់ ប្រដាប់ដុសខាត់សំអាតក្រចក. . .)
- o ប្រដាប់ប្រដាក្នុងផ្ទះ (តុ ទូ សាឡុង កម្រាលពូក. . .)
- o ចំណាយលើសុខភាព (ថ្នាំពេទ្យ ថ្លៃព្យាបាល. . .)

៤. ទុកពេល១០នាទី ឱ្យសិស្សលើកពីប្រភេទមុខចំណាយទូទៅឱ្យត្រូវតាមជួររបស់វា (ឈ្នួលផ្ទះគឺ ដាក់នៅក្រោមប្រភេទចំណាយរបស់វា)។

៥. ឱ្យសិស្សលើកឧទាហរណ៍ពីប្រភេទចំណាយទូទៅដែលគេបានកំណត់ថាជាប្រភេទចំណាយជាក់លាក់។

➢ ឱ្យសិស្សលើកឧទាហរណ៍ពីប្រភេទចំណាយដែលស៊ីគ្នាទៅនឹងប្រភេទនីមួយៗដូចជា: "**ចំណាយថេរ**" (ដែលគេដឹងជាទៀងរាល់ខែ និង មានចំនួនជាក់លាក់), "**ចំណាយប្រែប្រួល**", (ដែលគេដឹងជាទៀងរាល់ខែ ប៉ុន្តែមិនដឹងពីចំនួនពិតប្រាកដ) ឬ "**ចំណាយផ្សេងៗ**" (ការចំណាយផ្សេងៗដែលមិនមែនជាការចំណាយក្នុងប្រភេទទាំង ២ ដំបូង)។

- o ជួលផ្ទះ➢ ចំណាយថេរ
- o ថ្លៃប្រើប្រាស់សេវាកម្មសាធារណៈ(ថ្លៃទឹក ភ្លើង ថ្លៃជួសជុលលូ ថ្លៃសំរាម)➢ ចំណាយប្រែប្រួល
- o ការសិក្សា(ថ្លៃសាលា សម្ភារៈសិក្សា សៀវភៅសរសេរ ប៊ិច ដែកឈាន ) ➢ ចំណាយផ្សេងៗ
- o ការធ្វើដំណើរ( សាំង តាក់ស៊ី ម៉ូតូឌុប កៅស៊ូកង់) ➢ ចំណាយប្រែប្រួល
- o ម្ហូបអាហារ (តម្រូវការជាចាំបាច់) ➢ ចំណាយប្រែប្រួល
- o សំលៀកបំពាក់ (ប្រភេទសំលៀកបំពាក់ផ្សេង) ➢ ចំណាយផ្សេងៗ
- o ការកំសាន្ត (ភាពយន្ត ថាសចម្រៀង បាយពេលល្ងាចជាមួយមិត្តភក្តិ ..) ➢ ចំណាយផ្សេងៗ
- o បង់ប្រាក់កម្ចី ➢ ចំណាយថេរ
- o ការសំអាងខ្លួន (កាត់សក់ សាប៊ូដុសខ្លួន សាប៊ូកក់សក់ ប្រដាប់ដុសខាត់សំអាតក្រចក)➢ ចំណាយផ្សេងៗ
- o ប្រដាប់ប្រដាក្នុងផ្ទះ (តុ ទូ សាឡុង កម្រាលពូក ។ល។) ➢ ចំណាយផ្សេងៗ
- o ចំណាយលើសុខភាព (ថ្នាំពេទ្យ ថ្លៃព្យាបាល) ➢ ចំណាយផ្សេងៗ

៦. ឱ្យសិស្សមើលទៅលើតារាងគ្រោងថវិកាផ្ទាល់ខ្លួនរបស់គេហើយដាក់ប្រភេទចំណាយដូចឧទាហរណ៍ខាងលើ ក្នុងតារាង "**ចំណាយដែលបានគ្រោងទុក**" ។ ការចំណាយទាំងនេះត្រូវបែងចែកជា "**ចំណាយថេរ**" "**ចំណាយប្រែប្រួល**" និង "**ចំណាយផ្សេងៗ**" ។
ចូរកុំបារម្ភប្រសិនបើអ្នកគ្មានមុខចំណាយសម្រាប់ប្រភេទចំណាយណាមួយនោះ ហើយមិនចាំបាច់ដាក់បញ្ចូលគ្រប់ប្រភេទចំណាយទាំងអស់ទៅក្នុងតារាងគ្រោងថវិការបស់អ្នកឡើយ ។

៧. សិស្សត្រូវអនុវត្តតាមជំហានដូចខាងក្រោម ៖
- ពិនិត្យលើសៀវភៅកំណត់ត្រាចំណាយរបស់ខ្លួន ដែលបានកំណត់ពីប្រភេទចំណាយ ដើម្បីដាក់បញ្ចូលទៅក្នុងតារាងគ្រោងថវិកា ។
- គូសតារាងគ្រោងថវិកា
- បញ្ចូលប្រភេទចំណាយដែលពួកខ្លួនបានគិតថាចាំបាច់ត្រូវចំណាយ ចូលទៅក្នុងតារាងគ្រោងថវិកា ។

៨. ខាងក្រោមនេះគ្រាន់តែជាឧទាហរណ៍ពីការធ្វើគំរូតារាងគ្រោងថវិកា ៖

# ឯកសារសម្រាប់គ្រូ

| ប្រាក់ចំណូល និង ចំណាយ | ថវិកា | ចំនួនជាក់ស្តែង | ភាពខុសគ្នា |
|---|---|---|---|
| **ចំណូលដែលរំពឹងទុក** | | | |
| ប្រាក់ឧបត្ថម្ភ (allowance) | | | |
| ប្រាក់ធ្វើការងារតាមផ្ទះ (Chores) | | | |
| ប្រាក់ខែ (Jobs) | | | |
| **ចំណូលប្រចាំសប្តាហ៍សរុប** | | | |

| | | | |
|---|---|---|---|
| **ចំណាយដែលរំពឹងទុក** | | | |
| **ចំណាយប្រែប្រួល** | | | |
| • ម្ហូបអាហារ | | | |
| • ការធ្វើដំណើរ | | | |
| **ចំណាយផ្សេងៗ** | | | |
| • ការសិក្សា | | | |
| • សំលៀកបំពាក់ | | | |
| • ការសំអាងខ្លួន | | | |
| **ចំណាយប្រចាំសប្តាហ៍សរុប** | | | |
| **ប្រាក់សន្សំសរុប (ចំណូលដកចំណាយ)** | | | |

| សកម្មភាពទី៤ : របៀបគណនារកចំនួនថវិកា | ៣០ នាទី |
|---|---|

ដើម្បីរៀបចំថវិកា ដំបូងយើងត្រូវចាប់ផ្តើមជាមួយនឹងជួរ **"ថវិកា"** ។ ចំណែកព័ត៌មាននៅក្នុងជួរ **"ចំនួនជាក់ស្តែង"** គឺយើងត្រូវបំពេញនៅចុងបញ្ចប់នៃសកម្មភាពគ្រោងថវិការបស់យើង ។ ដើម្បីស្វែងយល់ពីលំនាំនៃការបំពេញតារាងគ្រោងថវិកាផ្ទាល់ខ្លួននេះ យើងត្រូវពិនិត្យមើលចំនួនថវិកា ប្រចាំសប្តាហ៍ជាមុនសិន មានន័យថានៅចុងសប្តាហ៍យើងត្រូវពិនិត្យមើលតារាងគ្រោងថវិកា ហើយបំពេញព័ត៌មាននៅត្រង់ជួរ **"ចំនួនជាក់ស្តែង"** ដែលមនុស្សភាគច្រើនព្យាយាមបំពេញព័ត៌មាននៅក្នុងតារាងគ្រោងថវិកាប្រចាំខែ ឬ ប្រចាំឆ្នាំ ។

សម្រាប់ប្រភេទថវិកានីមួយៗអ្នកត្រូវពិនិត្យមើលឡើងវិញនូវព័ត៌មានក្នុងសៀវភៅកំណត់ត្រាការចំណាយប្រចាំថ្ងៃរបស់ពួកគេ :

១. ដោយផ្អែកលើបទពិសោធន៍កន្លងមក អ្នកត្រូវបំពេញព័ត៌មាននៅក្នុងតារាងគ្រោងថវិការបស់អ្នកនូវចំនួនទឹកប្រាក់ដែលអ្នកគិតថាជាប្រាក់ចំណូលរបស់អ្នកនៅសប្តាហ៍ក្រោយ ។

២. បូកសរុបចំនួនប្រាក់ចំណូលដែលរំពឹងទុកសម្រាប់សប្តាហ៍នីមួយៗ រួចដាក់ចំនួនទឹកប្រាក់សរុបនេះទៅក្នុងប្រអប់ "**ប្រាក់ចំណូលសរុបប្រចាំសប្តាហ៍**" នៅក្រោមជួរ "**ថវិកា**" ។

៣. ពិនិត្យមើលប្រភេទចំណាយផ្សេងៗរបស់អ្នកកាលពីសប្តាហ៍មុន ។

៤. ចូរអ្នកគិតអំពីការចំណាយផ្សេងៗដែលអាចមាននៅសប្តាហ៍នេះ ។

៥. ផ្អែកលើចំនួនទាំងនេះ ចូរអ្នកធ្វើការប៉ាន់ស្មានពីចំនួនប្រាក់ ដែលនឹងត្រូវចំណាយសម្រាប់ប្រភេទនីមួយៗដែលអ្នកបានរាយឈ្មោះនៅក្នុងតារាងគ្រោងថវិកា ។

៦. ចូរសរសេរពីចំនួនទឹកប្រាក់ដែលជាការប៉ាន់ស្មានទាំងនោះនៅក្នុងជួរ "**ថវិកា**" (ការប៉ាន់ស្មានដែលល្អគឺអាស្រ័យទៅលើបទពិសោធន៍កន្លងមករបស់អ្នក) សម្រាប់ចំនួនទឹកប្រាក់ដែលអ្នកត្រូវការតាមប្រភេទនីមួយៗនៅសប្តាហ៍ក្រោយ ។

៧. ចូរគិតឱ្យបានច្បាស់មុននឹងអ្នកសម្រេចចិត្តបន្តទៅមុខទៀតៈ តើអ្នកមានបាត់នូវប្រភេទ ចំណាយណាមួយដែរឬទេ? ប្រសិនបើ "មានបាត់" ចូរដាក់បន្ថែមប្រភេទទាំងនោះ ។ ប្រសិនបើ "ពុំមានបាត់ទេ" សូមបន្តទៅជំហានបន្ទាប់ទៀត ។

៨. បូកសរុបចំនួនថវិកាទាំងអស់របស់អ្នក ហើយសរសេរចំនួនប្រាក់សរុបនេះនៅក្នុងជួរ "**ថវិកា**" ត្រង់ "**ការចំណាយសរុបប្រចាំខែ**" ។

៩. ចំនួនប្រាក់ចំណាយសរុបរបស់អ្នក <u>មិនគួរ</u> មានចំនួនច្រើនជាងប្រាក់ចំណូលសរុបឡើយ ។ ចូរកាត់បន្ថយការចំណាយរបស់អ្នក ប្រសិនបើអ្នកមានការចំណាយច្រើនជាងប្រាក់ចំណូល ។

១០. រក្សាប្រអប់ក្នុងជួរ "**ចំនួនជាក់ស្តែង**" និង "**ភាពខុសគ្នា**" ឱ្យនៅទំនេរ ។ អ្នកត្រូវបំពេញព័ត៌មាននៅក្នុងប្រអប់ទាំងនេះនៅសប្តាហ៍ក្រោយ ។

១១. បំពេញចំនួនទឹកប្រាក់ ដែលអ្នកត្រូវសន្សំនៅក្នុងជួរ "**ប្រាក់សន្សំសរុប**" ដោយធ្វើការគណនាចំនួនប្រាក់ចំណូលសរុបដកជាមួយនឹងប្រាក់ចំណាយសរុប ។ ចំនួនទឹកប្រាក់ដែលគណនានេះមិនអាចចេញជាសញ្ញាអវិជ្ជមាន ហើយក៏មិនមែនជាប្រាក់ដែលនឹងត្រូវសន្សំដែរ ។ អ្នកក៏មិនអាចធ្វើផែនការចំណាយឱ្យច្រើនលើសពីចំនួនប្រាក់ចំណូលដែលអ្នកមាននោះដែរ ។

<u>**កំណត់សម្គាល់:**</u> ប្រភេទថវិកាផ្ទាល់ខ្លួនរបស់អ្នក និង ចំនួនថវិកាដែលមានគឺពិតជាមានលក្ខណៈខុសគ្នាទៅនឹងចំនួនថវិការបស់មិត្តភក្តិរបស់អ្នក ។ អ្នកមិនបាច់គិតពីភាពខុសគ្នានេះទេ ពីព្រោះតារាងគ្រោងថវិការបស់អ្នកខុសពីតារាងគ្រោងថវិការបស់មិត្តភក្តិអ្នក ដូចនេះតារាងទាំងនេះវាមិនត្រូវគ្នាឡើយ ។

**កិច្ចការផ្ទះ**

☞ នៅសប្តាហ៍ក្រោយចូរយកសៀវភៅកំណត់ត្រាការចំណាយប្រចាំថ្ងៃមកផង ។

## មេរៀនទី៧ : ការពិនិត្យថវិកាផ្ទាល់ខ្លួន

**រយៈពេលបង្រៀន** ២ ម៉ោង

**ការរៀបចំរបស់គ្រូមុនពេលបង្រៀន**

- ពិនិត្យមើលមេរៀនឡើងវិញឱ្យបានហ្មត់ចត់
- ពិនិត្យមើលខ្លឹមសារក្នុងសៀវភៅសិស្ស ដើម្បីដឹងពីព័ត៌មាន និង សំណួរ
- សរសេរកម្រងសំណួរ និងខ្លឹមសារមេរៀន។

**សម្ភារៈ**

- ឯកសារណែនាំសម្រាប់គ្រូ
- សៀវភៅសិស្ស
- គូសតារាងគ្រោងថវិកានៅលើក្រដាសផ្ទាំងធំ
- ក្រដាសផ្ទាំងធំ និង ហ្វឺត
- ក្តារខៀន និង ដីស
- សម្ភារៈដែលបានរៀបចំខាងលើ
- កម្រងសំណួរ និងខ្លឹមសារមេរៀន។

**លទ្ធសិក្សារំពឹងទុក**

ពេលរៀនមេរៀននេះចប់ សិស្សនឹងអាច :

- វិភាគលើឥរិយាបថក្នុងការចំណាយ
- កំណត់ជម្រើសផ្សេងដែលអាចមានទំនាក់ទំនងជាមួយការចំណាយ
- ពិនិត្យ និងកែសម្រួលឡើងវិញលើថវិកាចំណាយប្រចាំសប្តាហ៍
- ត្រួតពិនិត្យមើលការចំណាយ
- កំណត់ថវិកាដែលមាន
- បង្កើតថវិកាប្រចាំសប្តាហ៍។

**លំនាំនៃការបង្រៀន**

| | |
|---|---|
| សកម្មភាពទី ១: ការពិនិត្យសៀវភៅកំណត់ត្រាការចំណាយ និង តារាងគ្រោងថវិកា | **២០ នាទី** |

គ្រូសួរសិស្ស

- តើអ្នកជួបការលំបាកនៅក្នុងការកត់ត្រាការចំណាយប្រចាំថ្ងៃដែរឬទេ?
- តើអ្នកមានប្រភពចំណូលថ្មីដែលអ្នកអាចដាក់បញ្ចូលទៅក្នុងតារាងគ្រោងថវិការបស់អ្នកដែរឬទេ?
- តើអ្នកមានប្រភេទចំណាយថ្មីដែលអ្នកអាចដាក់បញ្ចូលទៅក្នុងតារាងគ្រោងថវិការបស់អ្នកដែរឬទេ?
- តើមនុស្សគ្រប់រូបគួរតែមានប្រភេទចំណាយដូចគ្នានៅក្នុងតារាងគ្រោងថវិកាផ្ទាល់ខ្លួនទេឬ? ហេតុអ្វី?
  - [ចម្លើយ : មិនដូចគ្នាទេ, គ្រប់ប្រភេទចំណាយសម្រាប់តារាងគ្រោងថវិកាផ្ទាល់ខ្លួនគឺវាអាស្រ័យទៅលើតម្រូវការ និង ទម្លាប់នៃការចំណាយរបស់បុគ្គលម្នាក់ៗ ។ ឧទាហរណ៍មនុស្សម្នាក់មានផ្ទះ ដូចនេះគេមិនត្រូវបង់ថ្លៃជួលផ្ទះទេ តែគេអាចត្រូវបង់ប្រាក់កម្ចី ។ សិស្សដែលរៀននៅសាលាឯកជនគេនឹងត្រូវបង់ថ្លៃសាលាប៉ុន្តែសិស្សដែលរៀននៅសាលារដ្ឋគេមិនចាំបាច់បង់ថ្លៃសាលាអ្វីឡើយ ។]

| សកម្មភាពទី ២ : ការគណនាចំនួនប្រាក់ចំណាយពិតរបស់អ្នកប្រចាំសប្តាហ៍ | ២០ នាទី |
|---|---|

១. គ្រូសួរ

- តើអ្នកយល់ឃើញដូចម្តេចចំពោះព័ត៌មានដែលសរសេរនៅជួរ "**ចំនួនជាក់ស្តែង**" ក្នុងតារាងគ្រោងថវិកា?
  - [ចម្លើយ : "**ចំនួនជាក់ស្តែង**" ជាជួរសម្រាប់សរសេរព័ត៌មានពីការចំណាយពិតដែលកើតមានក្នុងរយៈពេលចលនាថវិកា ។ ប្រសិនបើថវិកានេះប្រើប្រាស់ក្នុងរយៈពេលមួយសប្តាហ៍ "**ចំនួនជាក់ស្តែង**" ជាចំនួនប្រាក់ដែលយើងបានចំណាយពិតប្រាកដនៅក្នុងសប្តាហ៍នោះ ។]

២. គ្រូឱ្យក្រុមសិស្សដែលមានគ្នា ២-៣ នាក់ បញ្ចូលព័ត៌មានពីសៀវភៅកំណត់ត្រាការចំណាយប្រចាំថ្ងៃចូលទៅក្នុងតារាងគ្រោងថវិកា ។ ដើម្បីធ្វើដូច្នេះបានអ្នកត្រូវ៖

- កំណត់ថាតើប្រភេទចំណាយនីមួយៗត្រូវយកទៅដាក់ត្រង់កន្លែងណាក្នុងតារាងគ្រោងថវិកា
- ធ្វើការបូកសរុបរាល់ការចំណាយសម្រាប់មុខចំណាយនីមួយៗឱ្យត្រូវគ្នានឹងប្រភេទចំណាយ
- សរសេរចំនួនសរុបដែលបានគណនារួចចូលទៅក្នុងជួរ "**ចំនួនជាក់ស្តែង**" ឱ្យបានត្រឹមត្រូវសម្រាប់ប្រភេទចំណាយ ។
- បូកសរុបការចំណាយទាំងអស់បញ្ចូលគ្នា រួចសរសេរចំនួនសរុបនេះនៅក្នុងជួរ "**ចំនួនជាក់ស្តែង**" សម្រាប់ជួរ "**ចំណាយសរុបប្រចាំសប្តាហ៍**" ។
- ដកចំនួនចំណាយសរុបជាក់ស្តែងជាមួយចំនួនប្រាក់ចំណូលសរុបជាក់ស្តែង ដើម្បីឱ្យដឹងថាចំនួនប្រាក់សន្សំពិតប្រាកដនោះមានប៉ុន្មាន ។ វិធីគណនានោះគឺ៖ ប្រាក់ចំណូលសរុបជាក់ស្តែង-ប្រាក់ចំណាយសរុបជាក់ស្តែង=ចំនួនប្រាក់សន្សំសរុបជាក់ស្តែង ។ ជានិច្ចកាលយើងរំពឹងថាលទ្ធផលគណនានេះត្រូវតែវិជ្ជមាន

មិនមែនអវិជ្ជមានទេ ។

☞ **កំណត់សម្គាល់ :** ប្រសិនបើចំនួនប្រាក់ចំណូលជាក់ស្តែងច្រើនជាង ប្រាក់ចំណាយជាក់ស្តែងពេលនោះ គេមានប្រាក់សន្សំជាក់ស្តែង ។

| សកម្មភាពទី ៣ : ភាពខុសគ្នារវាងថវិការបស់អ្នក និង ចំនួនថវិកាជាក់ស្តែង | ⏱ ៣០ នាទី |
|---|---|

១. គ្រូសួរសំណួរ

☞ តើអ្នកយល់ឃើញដូចម្តេចចំពោះព័ត៌មានដែលសរសេរនៅក្រោមជួរ "**ភាពខុសគ្នា**" ក្នុងតារាងគ្រោងថវិកា?

➢ (ចម្លើយ : នៅក្នុងជួរ "**ភាពខុសគ្នា**" ជាប្រអប់សម្រាប់សរសេរចំនួនថវិកាខុសគ្នារវាង "**ថវិកា**" និង "**ចំនួនជាក់ស្តែង**" ។)

២. គ្រូពន្យល់

➢ យើងនឹងពិនិត្យមើលពីភាពខុសគ្នារវាងប្រាក់ចំណូល និង ប្រាក់ចំណាយ ។

➢ យើងចង់ឱ្យប្រាក់ចំណូលជាក់ស្តែងខ្ពស់ជាងចំនួនថវិកាដែលមាន ។

➢ យើងចង់ឱ្យប្រាក់ចំណាយជាក់ស្តែងទាបជាងចំនួនថវិកាដែលមាន ។

➢ តាមរូបមន្តយើងតែងចង់បានប្រាក់ចំណូលមានចំនួនខ្ពស់ជាងប្រាក់ចំណាយ ។

៣. វិធីគណនាមួយចំនួនសម្រាប់ការគណនាភាពខុសគ្នា ។

➢ សម្រាប់ប្រាក់ចំណូលដែលយើងចង់ឱ្យមានចំនួនជាក់ស្តែងខ្ពស់ជាងចំនួនថវិកា នោះយើងត្រូវប្រើវិធីគណនាដូចខាងក្រោម :

ចំនួនប្រាក់ចំណូលជាក់ស្តែង-ចំនួនថវិកាដែលមាន=ចំនួនប្រាក់ខុសគ្នា

➢ ការប្រើប្រាស់វិធីនេះ ប្រសិនបើ ថវិកាជាក់ស្តែងខ្ពស់ជាងថវិកាដែលមាន ដូចនេះការគណនាបាន បង្ហាញច្បាស់ពីលទ្ធផលវិជ្ជមាន ។

➢ សម្រាប់ប្រាក់ចំណាយដែលយើងចង់ឱ្យមានចំនួនចំណាយជាក់ស្តែងទាបជាងចំនួនថវិកា នោះបង្ហាញឱ្យដឹងថាយើងសន្សំប្រាក់បានច្រើន ។ ដូច្នេះយើងអាចប្រើវិធីគណនាដូចខាងងក្រោម:

➢ ចំនួនប្រាក់ចំណាយ-ចំនួនប្រាក់ចំណាយជាក់ស្តែង=ចំនួនប្រាក់ខុសគ្នា

➢ ការគណនាតាមវិធីនេះប្រសិនបើថវិកាចំណាយវាខ្ពស់ជាងចំនួនប្រាក់ចំណាយជាក់ស្តែងនោះ បង្ហាញពីលទ្ធផលវិជ្ជមាន ។

៤. គ្រូឱ្យក្រុមសិស្សដែលមានគ្នា ២-៣ គណនាចំនួនថវិកានៅក្នុងជួរ "**ភាពខុសគ្នា**" ។

- បូកចំនួនប្រាក់ចំណូលអវិជ្ជមាន និង វិជ្ជមានរួមគ្នា ដើម្បីរកប្រាក់ចំណូលដែលខុសគ្នា ។
- បូកចំនួនប្រាក់ចំណាយអវិជ្ជមាន និង វិជ្ជមានរួមគ្នា ដើម្បីរកប្រាក់ចំណាយសរុបដែលខុសគ្នា ។

៥. ចូរពិនិត្យមើលទឹកប្រាក់ខុសគ្នារបស់អ្នក ហើយឆ្លើយនឹងសំណួរខាងក្រោមៈ

- តើអ្នករកបាន "**ប្រាក់ចំណូល**" ច្រើនជាង ឬ តិចជាង ឬ ដូចគ្នាទៅនឹងផែនការដែលអ្នកកំណត់?
- តើអ្នកបាន "**ចំណាយប្រាក់**" ច្រើនជាង ឬ តិចជាង ឬដូចគ្នាទៅនឹងផែនការដែលអ្នកកំណត់?
- ប្រសិនបើត្រូវពិនិត្យមើលឡើងវិញលើថវិការបស់អ្នក ដើម្បីធ្វើផែនការឱ្យបានត្រឹមត្រូវ តើអ្នកត្រូវកែប្រែទៅលើចំណុចអ្វី?

| សកម្មភាពទី ៥ : ការបង្កើតតារាងគ្រោងថវិកាប្រចាំខែផ្ទាល់ខ្លួន | ៣០ នាទី |
|---|---|

១. គ្រូណែនាំឱ្យសិស្សធ្វើការជាបុគ្គល ។ ប្រសិនបើពួកគេធ្វើមិនចប់នោះ ពួកគេអាចយកកិច្ចការនេះទៅធ្វើបន្តនៅផ្ទះ ។

- ដោយផ្អែកលើតួលេខសៀវភៅកំណត់ត្រាប្រចាំថ្ងៃ និង ថវិកាពង្រាងប្រចាំសប្តាហ៍ដែលអ្នកបានធ្វើ ចូរបង្កើតតារាងគ្រោងថវិកាសម្រាប់ប្រាក់ចំណូលប្រចាំខែ និង ប្រាក់ចំណាយ ។
- ផ្អែកលើបទពិសោធន៍គ្រោងថវិកាប្រចាំសប្តាហ៍របស់អ្នក អ្នកអាចធ្វើការកែប្រែប្រភេទចំណាយឱ្យបានសមស្រប ។
- ផ្អែកលើចំនួនប្រាក់ចំណាយដែលបានប៉ាន់ស្មានទុកសម្រាប់ខែក្រោយ ចូរអ្នកបញ្ចូលលេខសម្រាប់ជួរ "**ថវិកា**" របស់អ្នក ។
- រក្សាព័តិមានក្នុងសៀវភៅកំណត់ត្រាប្រចាំថ្ងៃសម្រាប់ប្រើនៅសកម្មភាព ៤ នៅសប្តាហ៍ក្រោយទៀត ដើម្បីយកមកពិនិត្យមើលឡើងវិញ និង បំពេញព័តិមាននៅក្នុងប្រអប់ "**ចំនួនជាក់ស្តែង**" និង "**ភាពខុសគ្នា**" ។

| កិច្ចការផ្ទះ |
|---|

- បំពេញតារាងថវិកាចំណាយផ្ទាល់ខ្លួនរបស់អ្នក ។
- សិស្សត្រូវរក្សាសៀវភៅកំណត់ត្រាប្រចាំថ្ងៃនេះសម្រាប់សកម្មភាពនៅពេលក្រោយ ។

## មេរៀនទី ៨ : ការរៀបចំបញ្ជីគណនេយ្យគោលសម្រាប់ការធ្វើជំនួញ

**រយៈពេលបង្រៀន** ២ ម៉ោង

**ការរៀបចំរបស់គ្រូមុនពេលបង្រៀន**

- ពិនិត្យមើលមេរៀនឡើងវិញឱ្យបានហ្មត់ចត់
- ពិនិត្យមើលខ្លឹមសារក្នុងសៀវភៅសិស្ស ដើម្បីដឹងពីព័ត៌មាន និងសំណួរ
- សរសេរខ្លឹមសារការសម្ដែងតួចំនួន ៣ នៅលើក្រដាសផ្សេងពីគ្នា
- សរសេរកម្រងសំណួរ និងខ្លឹមសារមេរៀន ។

**សម្ភារៈ**

- ឯកសារណែនាំសម្រាប់គ្រូ
- សៀវភៅសិស្ស
- សម្ភារៈបង្រៀនដែលបានរៀបចំខាងលើ ។
- ក្ដារខៀន និង ដីស
- ហ្វឺត
- កម្រងសំណួរ និងខ្លឹមសារមេរៀន ។

**លទ្ធសិក្សារំពឹងទុក**

ពេលរៀនមេរៀននេះចប់ សិស្សនឹងអាច :

- ពន្យល់ពីសារៈសំខាន់នៃការរៀបចំបញ្ជីគណនេយ្យនៅក្នុងកិច្ចការជំនួញ
- លើកឧទាហរណ៍ពីការអនុវត្តល្អ និង មិនល្អក្នុងការចំណាយក្នុងកិច្ចការជំនួញ ព្រមទាំងបញ្ជាក់ពីមូលហេតុ
- លើកឧទាហរណ៍បានយ៉ាងតិច ៥ ពីប្រាក់ចូល និងប្រាក់ចេញនៅក្នុងការងារជំនួញ ។

**លំនាំនៃការបង្រៀន**

| សកម្មភាពទី ១: ការចាប់ផ្ដើម | ១០ នាទី |
|---|---|

១. គ្រូបង្ហាញប្រធានបទ "បញ្ជីគណនេយ្យគោល សម្រាប់ការធ្វើជំនួញ"

២. គ្រូធ្វើការបង្ហាញដោយសង្ខេប ៖

នៅប្រទេសកម្ពុជាមានមនុស្ស ក្រុមគ្រួសារ និង សហគមន៍ជាច្រើនបានចូលរួមក្នុងសកម្មភាពបង្កើតប្រាក់ចំណូលដើម្បីរកចំណូលចូលផ្ទះ។ ការយល់ដឹងពីគោលការណ៍គ្រឹះនៃការគ្រប់គ្រងប្រាក់មានសារៈសំខាន់ណាស់ ដើម្បីរក្សាប្រាក់ចំណូលជាជាងបាត់បង់ប្រាក់ក្នុងគោលបំណងធ្វើឱ្យមាននិរន្តរភាព នៃការរកចំណូលចូលផ្ទះឱ្យបានយូរអង្វែង។

៣. គ្រូអានគោលបំណងនៃការសិក្សាសម្រាប់មេរៀនថ្ងៃនេះ។

| សកម្មភាពទី ២ ៖ ការពិភាក្សាអំពីការធ្វើជំនួញនៅក្នុងសហគមន៍ | ១៥ នាទី |
|---|---|

១. គ្រូនាំសិស្សពិភាក្សាសំណួរខាងក្រោម ៖

- តើជំនួញជាអ្វី?/ដូចម្ដេចហៅថាជំនួញ?
  - [ចម្លើយរំពឹងទុក ៖ ជំនួញគឺជាសកម្មភាពនានាដែលគេធ្វើដើម្បីរកប្រាក់ចំណូលតាមគោលការណ៍ជាក់លាក់មួយ។ ជំនួញអាចជាការផលិត និងការលក់ទំនិញ ការទិញ និងលក់ទំនិញ ព្រមទាំងការផ្ដល់សេវាកម្មផងដែរ។]
- នៅក្នុងសហគមន៍របស់អ្នកមានប្រភេទជំនួញអ្វីខ្លះ?
- តើគេធ្វើដូចម្ដេចទើបចាំបានថាមានប្រាក់ចូលប៉ុន្មាន និង ប្រាក់ចេញប៉ុន្មាន?
  - [ចម្លើយរំពឹងទុក៖ អ្នកធ្វើជំនួញត្រូវពិនិត្យតាមដានពីប្រាក់ចំណូល និង ប្រាក់ចំណាយដែលគេមាន។ ដូចនេះពួកគេត្រូវមានសៀវភៅកត់ត្រាពីចំណូល និង ចំណាយ។]
- តើ "**បញ្ជីគណនេយ្យ**" មានន័យដូចម្ដេច?
  - [ចម្លើយរំពឹងទុក៖ បញ្ជីគណនេយ្យមានន័យថាជាការកត់ត្រារាល់ប្រាក់ចូល និងប្រាក់ចេញនៅក្នុងកិច្ចការជំនួញ ដោយរួមបញ្ចូលទាំងការលក់ជឿផងដែរ។]

២. គ្រូពន្យល់បន្ថែម ៖

ជាទូទៅ នៅក្នុងសហគមន៍របស់យើងប្រជាពលរដ្ឋជាច្រើនមិនមានទម្លាប់កត់ត្រាពីចំនួនប្រាក់ចូល និងប្រាក់ចេញនៃមុខជំនួញនោះទេ។ នេះវាជារឿងធម្មតា ពីព្រោះពួកគេមិនដែលបានទទួលការបង្រៀនពីរបៀបកត់ត្រាប្រាក់ចំណូល និងចំណាយនោះឡើយ។ ហេតុដូចនេះប្រជាពលរដ្ឋពិតជាមិនបានដឹងពីចំនួនប្រាក់ដែលគេរកបាន ហើយគេអាចនឹងមិនចាំថា តើភ្ញៀវណាខ្លះដែលបានទិញជឿ។ ម្យ៉ាងទៀតគេក៏មិនដឹងពិតប្រាកដ

ពីចំនួនទំនិញក្នុងស្តុករបស់គេ ដែលត្រូវបានទិញជឿនោះដែរ ។ ប្រសិនបើយើងធ្វើជំនួញតែមិនមានចំណេះដឹងពីការរៀបចំបញ្ជីគណនេយ្យក្នុងការចំណាយលើកិច្ចការជំនួញ នោះធ្វើឱ្យយើងបាត់បង់ទំនុកចិត្តនិងមានការចោទប្រកាន់កើតឡើងទៀតផង ។

៣. គ្រូសួរសិស្សថា " តើការរៀបចំបញ្ជីគណនេយ្យមានសារៈសំខាន់អ្វីខ្លះ? "

[ចម្លើយរំពឹងទុក :

- យើងដឹងពីចំនួនប្រាក់ដែលទទួលបាន ចំនួនប្រាក់ដែលបានចំណាយ និង មុខសញ្ញានៃការចំណាយប្រាក់ទាំងនោះ ។
- យើងអាចគណនាដឹងថា តើយើងកំពុងតែបង្កើតឱ្យមានប្រាក់ចំណេញ ឬ ខាតបង់ ។
- យើងអាចធ្វើការសម្រេចចិត្តកាន់តែល្អប្រសើរទៅលើអ្វីដែលត្រូវទិញ និង លក់ ។
- យើងអាចកត់ត្រាពីការទិញជឿ ហើយ អាចកាត់បន្ថយបានពីការលួចបន្លំពីអតិថិជន ឬ ក៏អាចកាត់បន្ថយបានពីការភ្លេចភ្លាំងលើចំនួនប្រាក់ដែលខាតបង់ ។
- យើងអាចត្រួតពិនិត្យលើការកត់ត្រា និង កាត់បន្ថយឱ្យនៅតិចលើចំនួនប្រាក់ដែលចំណាយខុស ។]

| សកម្មភាពទី ៣ : ការសម្តែងតួស្តីពីការតាមដានការចំណាយ | ⏱ ៤៥នាទី |
|---|---|

១. គ្រូណែនាំ ពីការសម្តែងតួ ៣ ដែលបានសរសេរនៅលើក្រដាសផ្សេងគ្នា( ឬ ខ្លឹមសារក្នុងសៀវភៅសិស្ស) ដែលបង្ហាញពីកម្រិតខុសគ្នានៃការអនុវត្ត រៀបចំបញ្ជីគណនេយ្យ ។

- **ការសម្តែងតួទី១ :** ស្ត្រីម្នាក់មានមុខជំនួញមួយ( ជ្រើសរើសមុខជំនួញមួយដែលក្រុមធ្លាប់ស្គាល់) ។ គាត់មិនធ្លាប់កត់ត្រាពីចំនួនប្រាក់ចំណូល និងចំណាយទេ ។ ថ្ងៃមួយកូនប្រុសរបស់គាត់ត្រឡប់ពីសាលារៀនដោយមានសំបុត្រមួយច្បាប់ដែលនាយកសាលាផ្ញើមក ។ សាលាបានស្នើសុំឱ្យចូលថវិកាខ្លះ ដើម្បីប្រើការក្នុងដំណើរទស្សនកិច្ចសិក្សារបស់សិស្ស ដែលសាលារៀបចំធ្វើសម្រាប់លើកកម្ពស់ កម្មវិធីសិក្សាបំណិនជីវិត ។ រយៈពេលមួយខែកន្លងមកហើយដែលសាលាបានធ្វើការផ្សព្វផ្សាយ ផែនការទស្សនកិច្ចសិក្សានេះ ហើយសមាគមមាតាបិតាសិស្សបានឯកភាពលើផែនការនេះដែរ ។ ស្ត្រីជាម្តាយមានការព្រួយបារម្ភយ៉ាងខ្លាំងពីរឿងនេះ ។ គាត់គិតថាខ្លួនគាត់គ្មានប្រាក់ទេ ។ គាត់បានព្យាយាមនឹកពីចំនួនប្រាក់ដែលគាត់រកបានកាលពីសប្តាហ៍មុន និងចំនួនប្រាក់ដែលគាត់បានចំណាយ ។

- **ការសម្ដែងតួទី២ :** ជាងឈើម្នាក់បានលក់ទូមួយឱ្យទៅភ្ញៀវម្នាក់តម្លៃ ១៥០ ០០០ រៀល ។ ពេលមកយកទូភ្ញៀវប្រាប់ជាងឈើនោះថា ពេលនេះគាត់មិនបានយកប្រាក់មកជាមួយទេ ប៉ុន្តែគាត់នឹងប្រគល់ប្រាក់ឱ្យនៅចុងខែនេះ ។ នៅចុងខែ ជាងឈើក៏បានទៅទារប្រាក់ពីភ្ញៀវនោះ ។ ភ្ញៀវនោះនិយាយថាគាត់ជំពាក់ប្រាក់ថ្លៃទូតែ ១២០ ០០០ រៀលប៉ុណ្ណោះ គាត់មិនឱ្យប្រាក់ទៅជាងឈើលើសពីចំនួន ១២០ ០០០ រៀលនោះឡើយ ។ ដូចនេះការជជែកដ៏តឹងតែងក៏កើតមានឡើង ។ ប៉ុន្តែជាងឈើ គ្មានភស្តុតាងដែលបញ្ជាក់ថាគាត់បានលក់ទូជឿក្នុងតម្លៃ ១៥០ ០០០ រៀល នោះទេ ហើយជាងឈើក៏បានសម្រេចចិត្តទទួលយកប្រាក់ថ្លៃលក់ទូរតម្លៃ ១២០ ០០០ រៀល ។

- **ការសម្ដែងតួទី ៣ :** ស្ត្រីមួយក្រុមរស់នៅក្នុងសហគមន៍ដែលមានឡធ្វើនំប៉័ងមួយ ។ ពួកគេបានបែងចែក ការងារដូចខាងក្រោម :
  - ស្ត្រីម្នាក់ទទួលខុសត្រូវទិញអុស និង គ្រឿងផ្សំសម្រាប់ធ្វើនំប៉័ង
  - ស្ត្រីម្នាក់ទទួលខុសត្រូវក្នុងការលក់នំប៉័ង
  - ស្ត្រីមួយក្រុមជួយច្របាច់ម្សៅ និង ដុតនំប៉័ង
  - ស្ត្រីម្នាក់ជាហិរញ្ញិកដែលទទួលខុសត្រូវក្នុងការទុកដាក់ប្រាក់ឱ្យមានសុវត្ថិភាព ។

  ស្ត្រីដែលជាអ្នកលក់មិនបានកត់ត្រាចំនួនប្រាក់ចំណូលទេ ។ ពេលនាងលក់បាននាងត្រូវប្រគល់ប្រាក់ទៅឱ្យហិរញ្ញិកដើម្បីរៀបចំទុកដាក់នៅក្នុងហិបប្រាក់ ។ ហិរញ្ញិកជាអ្នកបើកប្រាក់ឱ្យស្ត្រីដែលត្រូវយកទៅទិញអុស និងគ្រឿងផ្សំធ្វើនំប៉័ង ។ ហិរញ្ញិកជាមនុស្សម្នាក់ដែលគួរឱ្យទុកចិត្តណាស់ ប៉ុន្តែនាងមិនចេះអក្សរទេ ។ នៅចុងខែ សមាជិកក្រុមចង់ដឹងពីចំនួនប្រាក់ចំណូលដែលបានមកពីការលក់នំប៉័ង ។ នៅពេលបើកហិបប្រាក់ ពួកគេឃើញ មានប្រាក់តិចជាងការរំពឹងទុក ។ គ្មាននរណាម្នាក់ដឹងថាមានរឿងអ្វីកើតឡើងចំពោះប្រាក់ទាំងនោះឡើយ ។ បន្ទាប់ពីពិភាក្សាគ្នាមកពួកគេបានចោទប្រកាន់ស្ត្រីអ្នកលក់នំប៉័ងថាជាអ្នកលួចប្រាក់នោះ ។

២. គ្រូធ្វើការបែងចែកសិស្សជា ៣ ក្រុម ។ ក្រុមនីមួយៗមានពេល១៥ នាទី ដើម្បីរៀបចំផែនការ និង ២-៥ នាទីសម្រាប់សម្ដែងតួ ( អាស្រ័យទៅលើស្ថានភាព) ។ ក្រុមសិស្សត្រូវជ្រើសរើសតួ និង បង្កើតអត្ថបទសម្ដែង ។

៣. ក្រុមនីមួយៗមានពេល ៥ នាទី ដើម្បីសម្ដែងតួ និង ៥ នាទីទៀតសម្រាប់ការពិភាក្សាទៅលើសំណួរដែលមានក្រោមអត្ថបទសម្ដែងតួនីមួយៗ ។

៤. ក្រោយការសម្តែងតួនីមួយៗ គ្រូដឹកនាំសិស្សធ្វើការពិភាក្សា។

- **ការសម្តែងទី១ :** (១) តើស្ត្រីនោះមានបញ្ហាអ្វី? (២) តើគាត់គួរធ្វើដូចម្តេច ដើម្បីជៀសវាងបញ្ហានោះ?
  - [**ចម្លើយ : (១)** គាត់បានចំណាយប្រាក់ ដោយមិនបានគិតពីការបង់វិភាគទានទៅឱ្យសាលារបស់កូន។ គាត់ថែមទាំងមិនចាំថាតើគាត់បានចំណាយប្រាក់ទៅលើអ្វីនោះទេ។ **(២)** គាត់គួរតែបានកត់ត្រានូវប្រាក់ចំណូល និង ចំណាយរបស់គាត់ឱ្យបានត្រឹមត្រូវ និងធ្វើផែនការសម្រាប់បង់វិភាគទានទៅឱ្យសាលា។]
- **ការសម្តែងទី២ :** (១) តើហេតុអ្វីបានជាភ្ញៀវបន្លំថ្លៃលក់ទូរបស់ជាងឈើបាន? (២) តើជាងឈើគួរធ្វើដូចម្តេចដើម្បីជៀសវាងបញ្ហានេះ?
  - [**ចម្លើយ : (១)** ពីព្រោះគាត់គ្មានឯកសារអ្វីជាភស្តុតាងបញ្ជាក់ពីការយល់ព្រមលើតម្លៃ ឬ ចំនួនប្រាក់ដែលភ្ញៀវជំពាក់នោះឡើយ។ **(២)** ជាងឈើគួរតែធ្វើលិខិតស្នាមដោយមានចុះហត្ថលេខា ឬ ផ្តិតមេដៃភ្ញៀវដែលទិញទូ។]
- **ការសម្តែងតួទី ៣ :** (១) តើហេតុអ្វីបានជាសមាជិកក្រុមស្ត្រីនៅឡធ្វើនំប៉័ងខឹង? (២) តើពួកគេគួរធ្វើដូចម្តេចដើម្បីជៀសវាងបញ្ហាបែបនេះ?
  - [**ចម្លើយ : (១)** សមាជិកក្រុមស្ត្រីទាំងនោះខឹង ពីព្រោះគ្មាននរណាបានដឹងពីបញ្ហាប្រាក់លក់នំប៉័ងដែលបាត់នោះឡើយ។ **(២)** ប្រសិនបើពួកគេមានការកត់ត្រាត្រឹមត្រូវ ពួកគេនឹងបានដឹងពីចំនួនប្រាក់ចំណូល និង ចំណាយក្នុងការធ្វើជំនួញរបស់គេ។ ម្យ៉ាងទៀតការកត់ត្រាពីចំនួនប្រាក់ចំណូល និងចំណាយនេះវាក៏ជួយធ្វើឱ្យពួកគេបានដឹងផងដែរ ថាតើការធ្វើជំនួញ នេះចំណេញ ឬ ខាត។ ]

| សកម្មភាពទី៤ : ការបង្កើតប្រាក់ចំណូល និង ប្រាក់ចំណាយនៅក្នុងការធ្វើជំនួញ | ១៥ នាទី |
|---|---|

គ្រូឱ្យសិស្សលើកឧទាហរណ៍ពីមុខចំណូល និង ចំណាយ និង សេវាកម្មផ្សេងៗ សម្រាប់ការធ្វើជំនួញ។ បន្ទាប់មកគ្រូធ្វើតារាងកត់ត្រានៅលើក្តារខៀន :

| - (ចំណាយ) | +(ចំណូល) |
|---|---|
| | |
| (➢ចម្លើយរំពឹងទុក : ផលិតផលដែលខូច ឬ បាត់បង់ ការលក់ជឿ មធ្យោបាយដឹកជញ្ជូន ឬ សេវាកម្មអ្នកលើកដាក់ ។ល។) | (➢ចម្លើយរំពឹងទុក : ការលក់ផលិតផល ការសងប្រាក់ថ្លៃទំនិញដែលគេទិញជឿ ការសងថ្លៃការប្រាក់ ។ល។) |

| សកម្មភាពទី៥ : ការបញ្ចប់ការពិភាក្សាមេរៀននៅថ្ងៃនេះ | ១៥ នាទី |
|---|---|

គ្រូដឹកនាំសិស្សពិភាក្សាលើខ្លឹមសារសង្ខេបបញ្ចប់មេរៀន

- តើការនិយាយ និងការកត់ត្រាដោយសរសេរ មួយណាល្អជាង? ហេតុអ្វី? ចូរពន្យល់។
- តើថ្ងៃនេះអ្នកបានរៀនអ្វី?
    - (ចម្លើយរំពឹងទុក : (១) ការរៀបចំបញ្ជីគណនេយ្យជាអ្វី? ។ (២) ហេតុបានជាការរៀបចំបញ្ជីគណនេយ្យមានសារៈសំខាន់? ។ (៣) សារៈសំខាន់នៃការរៀបចំបញ្ជីគណនេយ្យ ។ (៤) .... ។ល។

| កិច្ចការផ្ទះ |
|---|

- គ្រូត្រូវរំលឹកសិស្សឱ្យបន្តសកម្មភាពលើសៀវភៅកំណត់ត្រាប្រចាំថ្ងៃរបស់ពួកគេ។

## មេរៀនទី៩ : តារាងលំហូរសាច់ប្រាក់សម្រាប់ការធ្វើជំនួញ

**រយៈពេលបង្រៀន** ២ ម៉ោង

### ☑ ការរៀបចំរបស់គ្រូមុនពេលបង្រៀន

- ពិនិត្យមើលមេរៀនឡើងវិញឱ្យបានហ្មត់ចត់
- ពិនិត្យមើលខ្លឹមសារក្នុងសៀវភៅសិស្ស ដើម្បីដឹងពីព័ត៌មាន និង សំណួរ
- គូសតារាងលំហូរសាច់ប្រាក់នៅលើក្រដាសផ្ទាំងធំ ២ សម្រាប់ប្រើក្នុងសកម្មភាពករណីសិក្សា។
- សរសេរខ្លឹមសារករណីសិក្សាទាំង ២ សម្រាប់សកម្មភាពទី ៤ ឬ ឱ្យសិស្សអានព័ត៌មានទាំងនេះនៅក្នុងសៀវភៅ
- សរសេរកម្រងសំណួរ និងខ្លឹមសារមេរៀន។

### សម្ភារៈ

- ឯកសារណែនាំសម្រាប់គ្រូ
- សៀវភៅសិស្ស
- សម្ភារៈបង្រៀនដែលបានរៀបចំខាងលើ
- ក្តារខៀន និង ដីស
- ហ្វឺត
- កម្រងសំណួរ និងខ្លឹមសារមេរៀន។

### ☼ លទ្ធផលសិក្សារំពឹងទុក

ពេលរៀនមេរៀននេះចប់ សិស្សនឹងអាច :

- បំពេញតារាងលំហូរសាច់ប្រាក់
- ពិនិត្យមើលកំហុសដែលមាននៅក្នុងតារាងលំហូរសាច់ប្រាក់។

### លំនាំនៃការបង្រៀន

| សកម្មភាពទី១ : ការពិនិត្យឡើងវិញលើខ្លឹមសារសំខាន់ក្នុងមេរៀនមុន | ១០ នាទី |
| --- | --- |

# ឯកសារសម្រាប់គ្រូ

**ការពិភាក្សា**

- តើការនិយាយដោយមាត់ និងការកត់ត្រាដោយសរសេរ មួយណាល្អជាង? ហេតុអ្វី? ចូរពន្យល់
- តើការរៀបចំបញ្ជីគណនេយ្យជាអ្វី?
- តើការរៀបចំបញ្ជីគណនេយ្យមានសារប្រយោជន៍ដូចម្តេចខ្លះ?

| សកម្មភាពទី ២: ការយល់ដឹងពីរបៀបប្រើប្រាស់តារាងលំហូរសាច់ប្រាក់ | ១០ នាទី |
|---|---|

១. គ្រូបិទតារាងសម្រាប់កត់ត្រាការលំហូរសាច់ប្រាក់។

| កាលបរិច្ឆេទ | ការទិញលក់ទំនិញ | មុខទំនិញ/សេវាកម្ម | | | ប្រាក់ចំណាយ (–) | ប្រាក់ចំណូល (+) | សមតុល្យ |
|---|---|---|---|---|---|---|---|
| | | មុខទំនិញ | បរិមាណ | តម្លៃលក់រាយ | | | |
| | | | | | | សមតុល្យដំបូង | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

២. គ្រូពិភាក្សាពីចំណងជើងនីមួយៗ ក្នុងតារាងលំហូរសាច់ប្រាក់ជាមួយសិស្ស។

- នៅក្នុងតារាងលំហូរសាច់ប្រាក់ តើជួរនីមួយៗ មានចំណងជើងអ្វីខ្លះ?
- តើអ្នកគិតថា ត្រូវដាក់ខ្លឹមសារអ្វីខ្លះនៅក្រោមចំណងជើងទាំងនោះ?

**ចម្លើយ**

- កាលបរិច្ឆេទ : ថ្ងៃទិញលក់ទំនិញ។
- ការទិញលក់ទំនិញ : ប្រភេទសកម្មភាពហិរញ្ញវត្ថុ( ការទិញ ការលក់ ការទិញជឿ និង ការសងប្រាក់។
- មុខទំនិញ/សេវាកម្ម : ប្រភេទទំនិញ ឬ សេវាកម្មដែលប្រើ។
- បរិមាណ : ចំនួនផលិតផល ឬ សេវាកម្មដែលបានទិញ និង លក់។
- តម្លៃលក់រាយ : ថ្លៃលក់សម្រាប់ផលិតផល ១ ឬ ការផ្តល់សេវាកម្ម ១។
- ប្រាក់ចំណាយ : ប្រាក់ដែលត្រូវចំណាយទៅលើការលក់ទំនិញ ឬ ការផ្តល់សេវាកម្ម។
- ប្រាក់ចំណូល : ប្រាក់ដែលបានទទួលពីការលក់ទំនិញ ឬ ការផ្តល់សេវាកម្ម។

- សមតុល្យៈ ចំនួនប្រាក់ដែលបានទូទាត់( បូក ឬ ដក) សម្រាប់ខ្ទង់ចំណូល ឬ ចំណាយនីមួយៗក្នុងការទិញលក់ទំនិញមួយលើកៗ។]

| សកម្មភាពទី៣ : ករណីសិក្សារបស់ "ស្រស់" | ៣០ នាទី |
|---|---|

១. គ្រូបិទករណីសិក្សារបស់ "**ស្រស់**" នៅលើជញ្ជាំង ឬឱ្យសិស្សមើលករណីសិក្សានេះនៅក្នុងសៀវភៅសិស្ស។ គ្រូឱ្យ សិស្សបំពេញតារាងលំហូរសាច់ប្រាក់ដោយផ្អែកលើករណីសិក្សា "ស្រស់" ។

**ករណីសិក្សារបស់ "ស្រស់"** ស្រស់មានបំណងធ្វើជំនួញផ្ទាល់ខ្លួននៅផ្សារ។ នាងមានប្រាក់មួយចំនួនតូចប៉ុណ្ណោះ។ ដូច្នេះ នាងធ្វើជំនួញតូចមួយ ហើយនាងសង្ឃឹមថាមុខជំនួញរបស់នាងនឹងរីកចម្រើន។

- ស្រស់ចាប់ផ្ដើមមុខជំនួញជាមួយនឹងទឹកប្រាក់ចំនួន ៥០ ០០០ រៀល។
- នៅព្រឹកថ្ងៃទី ២ ខែធ្នូ នាងបានទៅផ្សារ និងបានទិញទំនិញដូចខាងក្រោម :
    - ប៉េងប៉ោះ ៦គីឡូក្រាម ក្នុង១គីឡូក្រាមថ្លៃ ៣ ០០០ រៀល (៦×៣,០០០=១៨ ០០០)
    - ការ៉ុត ៤ គីឡូក្រាម ក្នុង ១ គីឡូក្រាមថ្លៃ ៣ ២០០ រៀល(៤×៣ ២០០=១២ ៨០០)
    - ត្រកួន ៨ បាច់ ក្នុង ១ បាច់ថ្លៃ ១ ០០០ រៀល(៨×១ ០០០= ៨ ០០០)
    - ខ្ទឹមបារាំង៣ គីឡូក្រាម ក្នុង១គីឡូក្រាមថ្លៃ ៣ ១០០រៀល (៣×៣ ១០០=៩ ៣០០)
    - ម្ទេសហឺរ ៥០ ផ្លែ ថ្លៃ ៧៥០ រៀល
- នៅថ្ងៃនោះនាងបានលក់មុខទំនិញខាងលើក្នុងតម្លៃដូចខាងក្រោម :
    - ប៉េងប៉ោះ ២,៥ គីឡូក្រាម ក្នុង ១ គីឡូក្រាមថ្លៃ ៣ ៥០០ រៀល
    - ការ៉ុត៣គីឡូក្រាម ក្នុង ១ គីឡូក្រាមថ្លៃ ៣ ៥០០ រៀល
    - ត្រកួន ៥បាច់ ក្នុង ១បាច់ថ្លៃ ១ ២៥០ រៀល
    - ខ្ទឹមបារាំង៣គីឡូក្រាម ក្នុង ១ គីឡូក្រាមថ្លៃ ៣ ៥០០ រៀល
    - ម្ទេសហឺរ ៣០ ផ្លែ ក្នុង៥ផ្លែ ថ្លៃ ១០០ រៀល
- នៅរសៀលថ្ងៃទី ២ ខែធ្នូ ដដែល ស្រស់បានចំណាយប្រាក់ ៥ ០០០ រៀល ទិញម្ហូបសម្រាប់គ្រួសាររបស់នាង។

- នៅថ្ងៃទី ៣ ខែធ្នូ ២០០៨ ស្រស់លក់ទំនិញដែលនៅសល់បន្តទៀត ។ ដោយសារមុខទំនិញដែលនៅសល់មិនសូវស្រស់ល្អ នាងលក់ក្នុងតម្លៃថោកជាងមុនបន្តិច ។
  - o ប៉េងប៉ោះ ២,៥ គីឡូក្រាម ក្នុង១គីឡូក្រាមថ្លៃ ៣ ៤០០ រៀល
  - o ការ៉ុត ១ គីឡូក្រាម ក្នុង១គីឡូក្រាមថ្លៃ ៣ ៥០០ រៀល
  - o ត្រកួន ៣ បាច់ ក្នុង១ បាច់តម្លៃ ១ ១០០ រៀល
  - o ម្ទេសហឺរ ១០ផ្លែ ក្នុង៥ផ្លែ ថ្លៃ ៧៥ រៀល

២. គ្រូដើរត្រួតពិនិត្យមើលការបំពេញតារាងគម្រោងលំហូរសាច់ប្រាក់ ។

- គ្រូអានព័ត៌មានស្ដីពីការទិញលក់ទំនិញរបស់ស្រស់ឱ្យសិស្សស្ដាប់ ។
- គ្រូឱ្យសិស្សម្នាក់អានព័ត៌មានទី១ ស្ដីពីការទិញទំនិញ រួចសួរសិស្សថា " តើព័ត៌មាននេះត្រូវដាក់នៅកន្លែងណា? " ➢ [ចម្លើយ : នៅក្បែរសមតុល្យលើកដំបូង ។]
- គ្រូសរសេរព័ត៌មាននេះចូលក្នុងតារាង ។
- គ្រូឱ្យសិស្សម្នាក់អានព័ត៌មានទី ២ ស្ដីពីការលក់ទំនិញ រួចឱ្យសិស្សម្នាក់ប្រាប់ពីកន្លែងដែលត្រូវកត់បញ្ចូលក្នុងតារាង ។
- នៅពេលសិស្សទាំងអស់ឯកភាព គ្រូឱ្យសិស្សបំពេញព័ត៌មានចូលក្នុងតារាង ។
- គ្រូហៅសិស្សផ្សេងទៀតឱ្យបំពេញជួរផ្សេងតាមគំរូខាងលើ ។
  - o សិស្សអានចម្លើយរបស់គេ ។
  - o សិស្សទាំងអស់ចូលរួមបញ្ជាក់ពីការយល់ស្រប ។
  - o បន្ទាប់មកសិស្សសរសេរចម្លើយរបស់គេចូលក្នុងតារាង ។
- នៅពេលសិស្សបំពេញចប់ គ្រូសួរទៅសិស្សថាតើប្អូនមានសំណួរអ្វីដែរឬទេ ។

**៣. ការពិភាក្សា**

- តើស្រស់បញ្ចប់ការលក់ដូរដោយទទួលបានប្រាក់ចំណេញ ឬ ខាត?[➢ចម្លើយ : ទទួលបានប្រាក់ចំណេញតិច]
- តើប្រាក់ចំណេញនៅពេលធ្វើសមតុល្យចុងក្រោយមានចំនួនប៉ុន្មាន?[➢ចម្លើយ : ១៣០០ រៀល]
- តើមុខទំនិញអ្វីដែលនាងបានដាក់បញ្ចូលទៅក្នុងតារាងលំហូរសាច់ប្រាក់ ដែលមិនមែនជាប្រាក់ចំណាយធ្វើជំនួញ?[ ➢ចម្លើយ : ប្រាក់ចំណាយលើម្ហូបអាហារសម្រាប់គ្រួសារ ។ ការចំណាយប្រភេទនេះមិនត្រូវដាក់បញ្ចូលទៅក្នុងប្រភេទចំណាយធ្វើជំនួញនោះទេ ។ប្រាក់ចំណាយនេះត្រូវដាក់ក្នុងតារាងប្រាក់ចំណូល និង ចំណាយផ្ទាល់ខ្លួន ។]

- តើប្រាក់ចំណេញពិតប្រាកដដែលលក់ក្នុងថ្ងៃដំបូងបានចំនួនប៉ុន្មាន?[ ➢ចម្លើយ : ៦ ៣០០ រៀល ពីព្រោះនាងបានចំណាយ ៥ ០០០ រៀលទិញម្ហូបសម្រាប់គ្រួសារ]
- តើមានមុខទំនិញអ្វីខ្លះដែលនាងត្រូវលក់បន្ត?[ ➢ចម្លើយ : ប៉េងប៉ោះ ១ គីឡូ និង ម្ទេស ១០ ផ្លែ]
- តើស្រស់ទទួលបានប្រាក់ចំណេញសម្រាប់ទ្រទ្រង់មុខជំនួញរបស់នាងរួចដែរឬទេ?[ ➢ចម្លើយ : ទេ នាងត្រូវបង្កើនមុខទំនិញបន្ថែមទៀតទើបអាចរកប្រាក់ចំណេញបានគ្រប់គ្រាន់សម្រាប់ការចំណាយរបស់នាង និង គ្រួសារ ។]
- តើនាងត្រូវធ្វើដូចម្តេច ដើម្បីបង្កើនប្រាក់ចំណេញបន្ថែមទៀត?[ ➢ចម្លើយរំពឹងទុក : ចម្លើយអាចមានច្រើនដូចជា ត្រូវលក់ទំនិញឱ្យបានច្រើនមុខបន្ថែមទៀត បង្កើនតម្លៃលក់ ឱ្យសមស្រប ។ នាងត្រូវតែអភិវឌ្ឍយុទ្ធសាស្ត្រទីផ្សារឱ្យមានប្រសិទ្ធភាព និង វិធីទាក់ទាញអតិថិជនឱ្យបានច្រើន ។]

| សកម្មភាពទី ៤ : ករណីសិក្សារបស់ "សុភ័ក្រ" | : ៣៥ នាទី |
|---|---|

១. គ្រូឱ្យករណីសិក្សារបស់សុភ័ក្រទៅសិស្សអាន ដើម្បីប្រើក្នុងការបំពេញតារាងលំហូរសាច់ប្រាក់ឬ ឱ្យសិស្សមើលសៀវភៅរបស់គេដោយផ្ទាល់ ។

- ឱ្យសិស្សចម្លងតារាងលំហូរសាច់ប្រាក់ចូលទៅក្នុងសៀវភៅកត់ត្រា ប្រសិនបើគេគ្មានសៀវភៅសិស្ស ។
- សិស្សបញ្ចូលទិន្នន័យដែលបានពីករណីសិក្សាទៅក្នុងតារាងគម្រោងលំហូរសាច់ប្រាក់ ។

**ករណីសិក្សារបស់ "សុភ័ក្រ"**

**សុភ័ក្រ** មានបំណងប្រកបមុខរបរផ្ទាល់ខ្លួនលក់ផ្លែឈើ ។ នាងបានខ្ចីប្រាក់ពីពូនាងចំនួន ៣០០ ០០០ រ ។ ឪពុកនាងបានឱ្យនាងខ្ចីរទេះដាក់ផ្លែឈើលក់ ។

- **សុភ័ក្រ** ចាប់ផ្តើមប្រកបមុខរបរលក់ផ្លែឈើជាមួយនឹងប្រាក់ ៣០០ ០០០ រៀល ។
- នៅព្រឹកថ្ងៃទី ១ ខែធ្នូ នាងបានទៅមើលតម្លៃផ្លែឈើនៅផ្សារ ។ នៅពេលរសៀល នាងបានសម្រេចចិត្តទិញប្រភេទផ្លែមួយចំនួនដូចខាងក្រោម ។
    - o ផ្លែស្វាយ ៥ គីឡូក្រាម ក្នុង ១ គីឡូក្រាមថ្លៃ ៥ ០០០រៀល (៥×៥០០០=២៥ ០០០)
    - o ផ្លែសាវម៉ាវ ៥គីឡូក្រាម ក្នុង១ គីឡូក្រាមថ្លៃ ៥ ៥០០ រៀល (៥×៥៥០០=២៧៥០០)
    - o ក្រូចថ្លុងតូចៗ១៥គីឡូក្រាម ក្នុង១គីឡូក្រាមថ្លៃ ៥ ៥០០ រៀល (១៥×៥៥០០=៨២ ៥០០)
    - o ផ្លែព័រអាស៊ី ៥គីឡូ ក្នុង១គីឡូក្រាម ថ្លៃ ៥ ៦០០ រៀល (៥×៥ ៦០០=២៨ ០០០)

- o ផ្លែប៉ោមល្អ ៦ គីឡូក្រាម ក្នុង១គីឡូក្រាមថ្លៃ ១០ ០០០ រៀល
  (៦×១០ ០០០=៦០ ០០០)

- នៅថ្ងៃទី ១ ខែធ្នូ នាងបានទិញកញ្ច្រែង ចំនួន ៥ ដើម្បីដាក់ផ្លែឈើលក់ ។ កញ្ច្រែង ១ ថ្លៃ ១៥ ០០០ រៀល ។
- នៅល្ងាចថ្ងៃទី ១ ខែធ្នូ **សុភ័ក្រ** និង ប្អូនស្រីរបស់នាងបានរុញរទេះផ្លែឈើទៅលក់នៅឯសួនឧទ្យាន ដែលមានមនុស្ស និង ក្រុមគ្រួសារជាច្រើនមកដើរលេងកំសាន្ត ។
  ប្រភេទផ្លែឈើដែលនាងលក់មាន ដូចខាងក្រោម :
  - o ផ្លែស្វាយ ២ គីឡូក្រាម ក្នុង ១ គីឡូក្រាមថ្លៃ ៥ ៥០០ រៀល
  - o ផ្លែសារម៉ាវ ៤ គីឡូក្រាម ក្នុង ១ គីឡូក្រាមថ្លៃ ៦ ៣០០ រៀល
  - o ក្រូចផ្អែមតូចៗ ១១ គីឡូក្រាម ក្នុង ១ គីឡូក្រាមថ្លៃ ៦ ២០០ រៀល
  - o ផ្លែព័រអាស៊ី ៣ គីឡូ ១ គីឡូ តម្លៃ ៦ ៣០០ រៀល
  - o ផ្លែប៉ោមល្អ ៤ គីឡូក្រាម ក្នុង ១ គីឡូក្រាមថ្លៃ ១៥ ០០០ រៀល
- នៅល្ងាចថ្ងៃទី ១ ខែធ្នូ **សុភ័ក្រ**បានឱ្យប្រាក់ទៅប្អូនស្រីរបស់នាងចំនួន ៤ ០០០ រៀល សម្រាប់ការជួយរុញរទេះ ។
- នៅថ្ងៃទី ២ ខែធ្នូ **សុភ័ក្រ**បានបន្តលក់ផ្លែឈើដែលនៅសល់តែម្នាក់ឯងនៅតាមដងផ្លូវ ។ ប៉ុន្តែដោយសារផ្លែឈើដែលនៅសល់មិនសូវស្រស់ នាងលក់តម្លៃថោកជាងមុនបន្តិច ។
  - o ស្វាយ ថ្លៃ ៥ ២០០ រៀល ក្នុង១ គីឡូក្រាម
  - o សារម៉ាវ ថ្លៃ ៥ ៤០០ រៀល ក្នុង១ គីឡូក្រាម
  - o ក្រូចផ្អែមតូចៗ ថ្លៃ ៥ ៣០០ រៀល ក្នុង១ គីឡូក្រាម
  - o ផ្លែព័រអាស៊ី ថ្លៃ ៦ ០០០ រៀល ក្នុង១ គីឡូក្រាម
  - o ផ្លែប៉ោមល្អ លក់ក្នុងតម្លៃដដែល ។

២. គ្រូទុកពេល២០ នាទី ឱ្យសិស្សបំពេញតារាងលំហូរសាច់ប្រាក់ជាបុគ្គលនៅក្នុងសៀវភៅកត់ត្រារបស់គេ ។

៣.គ្រូឱ្យសិស្សឡើងបំពេញតារាងលំហូរសាច់ប្រាក់ដែលមាននៅលើក្រដាសផ្ទាំងធំ ជាជំហានៗ ដោយប្រើព័ត៌មានក្នុងករណីសិក្សារបស់ "សុភ័ក្រ" ។

៤. ការពិភាក្សាពីករណីសិក្សារបស់ "សុភ័ក្រ" ។

- តើការធ្វើជំនួញរបស់សុភ័ក្រទទួលបានប្រាក់ចំណេញឬទេ?[➢ចម្លើយ : ទេ នាងខាតប្រាក់ ចំនួន ៣៤ ៥០០ រៀល ពេលចាប់ផ្ដើមជំនួញដំបូង ។]
- ហេតុអ្វីបានជានាងលក់ផ្លែឈើខាតនៅថ្ងៃនេះ?[➢ចម្លើយ : សុភ័ក្របានចំណាយប្រាក់ទិញកញ្ច្រែងអស់មួយចំនួន ។ កញ្ច្រែងនេះមិនមែនសម្រាប់លក់ទេ ។ នាងត្រូវទិញទំនិញណាដែលមានតម្លៃថោក ហើយនាងអាចលក់បានតម្លៃច្រើនជាងនេះស្របតាមតម្លៃទីផ្សារ ។]
- បើមិនគិតបញ្ចូលថ្លៃទិញកញ្ច្រែង តើសុភ័ក្រនឹងបានប្រាក់ចំណូលប៉ុន្មានពីការលក់?[➢ចម្លើយ : ៤០ ០០០ រៀល]
- ប្រសិនបើសុភ័ក្រមានប្រាក់ចំណូល និងចំណាយដដែលតើនាងត្រូវលក់ដូរប៉ុន្មានដងទើបរួចថ្លៃទិញកញ្ច្រែង?[ ➢ចម្លើយ : នាងត្រូវលក់ទំនិញមួយលើកទៀតទើបអាចរួចថ្លៃទិញកញ្ច្រែង ។]
- តើអ្នកមានយោបល់អ្វីសម្រាប់ជួយធ្វើឱ្យមុខជំនួញរបស់សុភ័ក្ររីកចម្រើន?[ ➢ចម្លើយ : អាស្រ័យលើចម្លើយរបស់សិស្ស ។]
- តើអ្នកគិតថាមុខជំនួញរបស់ស្រស់ ឬ សុភ័ក្រ អាចរីកចម្រើននៅពេលអនាគតដែរឬទេ? ហេតុអ្វី? [➢ចម្លើយ : ឥឡូវនេះមុខជំនួញរបស់សុភ័ក្រមានលក្ខណៈល្អប្រសើរជាង ។]

**សកម្មភាពទី៥ : ការរៀបចំសម្រាប់ធ្វើសម្ភាសជាមួយអ្នកធ្វើជំនួញ** **: ១៥ នាទី**

១. គ្រូពន្យល់

មេរៀនលើកក្រោយប្អូនត្រូវសម្ភាសអ្នកធ្វើជំនួញម្នាក់ ដែលអញ្ជើញមកពីសហគមន៍ ដើម្បីបង្ហាញពីបទពិសោធន៍នៃការកត់ត្រាប្រាក់ចំណូល និងចំណាយ ។

២. នេះជាសំណួរសំខាន់ៗមួយចំនួន ដែលយើងត្រូវប្រើដើម្បីសួរទៅអ្នកធ្វើជំនួញមកពីសហគមន៍ ។ ចូរសរសេរសំណួរទាំងនេះនៅក្នុងសៀវភៅកត់ត្រា ។

- ➢ តើប្រព័ន្ធនៃការរៀបចំបញ្ជីគណនេយ្យដែលបង/ពូ/មីង/អ៊ំប្រើមានអ្វីខ្លះ?
- ➢ តើបញ្ហាប្រឈមអ្វីខ្លះដែលបង/ពូ/មីង/អ៊ំជួបប្រទះក្នុងការរៀបចំបញ្ជីគណនេយ្យ?
- ➢ តើប្រភេទប្រាក់ចំណូល និង ចំណាយ( ការលក់ទំនិញ ប្រាក់កម្ចី ការទិញជឿ ការចំណាយលើកិច្ចការសេវាកម្ម) អ្វីខ្លះដែលគេត្រូវតាមដាន?

➢ តើបង/ពូ/មីង/អ៊ំអាចប្រាប់ពីបទពិសោធន៍មិនល្អៗដែលធ្លាប់ជួបប្រទះពេលរៀបចំបញ្ជីគណនេយ្យបានដែរឬទេ?

➢ តើបង/ពូ/មីង/អ៊ំអាចប្រាប់ពីបទពិសោធន៍ល្អៗដែលបង/ពូ/មីង/អ៊ំធ្លាប់ជួបប្រទះពេលរៀបចំបញ្ជីគណនេយ្យបានដែរឬទេ?

៣. ប្អូនអាចជ្រើសរើសសំណួរមួយចំនួនក្នុងចំណោមសំណួរផ្ទាល់ខ្លួនរបស់ប្អូន ដែលបានបង្កើតនៅពេលចាប់ផ្តើមមេរៀនដំបូង ដើម្បីដាក់បន្ថែមទៅក្នុងបញ្ជីសំណួរសម្ភាស។

៤. ប្អូនៗអាចសួរសំណួរសម្ភាសទៅអ្នកធ្វើជំនួញមកពីសហគមន៍។

៥. គ្រូណែនាំសិស្សឱ្យសរសេរសំណួរបន្ថែមទៀតមុនពេលពួកគាត់ត្រឡប់ទៅវិញ។

| កិច្ចការផ្ទះ |
|---|

- គ្រូឱ្យសិស្សបង្កើតសំណួរយ៉ាងតិច២ដើម្បីត្រៀមសួរទៅអ្នកជំនួញម្នាក់នៅក្នុងសហគមន៍ពីការរៀបចំបញ្ជីគណនេយ្យ។
- ចូរប្អូនៗបន្តការកត់ត្រាសៀវភៅកំណត់ត្រាចំណាយប្រចាំថ្ងៃរបស់អ្នក។

➲ កិច្ចការសម្រាប់គ្រូ : នៅពេលបង្រៀនលើកក្រោយ គ្រូត្រូវអញ្ជើញមនុស្ស ១ ឬ ២ នាក់មកថ្នាក់រៀន ដើម្បីផ្តល់បទពិសោធន៍ពីការរៀបចំបញ្ជីគណនេយ្យ។ អ្នកធ្វើជំនួញនោះអាចជាអ្នកទិញ អ្នកលក់ ឬអ្នកផ្តល់សេវាកម្មអ្វីមួយ។ អ្នកធ្វើជំនួញនោះអាចជាអ្នកលក់ដូរនៅក្នុងសាលា អ្នកលក់ដូរនៅតាមផ្ទះ នៅតាមផ្សារ នៅតាមភោជនីយដ្ឋាន ឬ ជាងឈើ ។ល។

| ចម្លើយករណីសិក្សារបស់ "ស្រស់" | | | | | | | |
|---|---|---|---|---|---|---|---|
| កាលបរិច្ឆេទ | ការទិញលក់ទំនិញ | មុខទំនិញ/សេវាកម្ម | | | ប្រាក់ចំណាយ (–) | ប្រាក់ចំណូល (+) | សមតុល្យ |
| | | មុខទំនិញ | បរិមាណ | តម្លៃលក់រាយ | | | |
| | | | | | | សមតុល្យដំបូង | ៥០ ០០០ |
| ២/១២/០៨ | ការទិញទំនិញ | ប៉េងប៉ោះ | ៦គីឡូក្រាម | ៣ ០០០ | ១៨ ០០០ | | ៣២ ០០០ |
| | | ការ៉ុត | ៤គីឡូក្រាម | ៣ ២០០ | ១២ ៨០០ | | ១៩ ០០០ |
| | | ត្រកួន | ៨បាច់ | ១ ០០០ | ៨ ០០០ | | ១១ ២០០ |
| | | ខ្ទឹមបារាំង | ៣គីឡូក្រាម | ៣ ១០០ | ៩ ៣០០ | | ១ ៩០០ |
| | | ម្ទេស | ៥០ផ្លែ | ៧៥០ | ៧៥០ | | ១ ១៥០ |
| ២/១២/០៨ | ការលក់ទំនិញ | ប៉េងប៉ោះ | ២.៥ | ៣ ៥០០ | | ៨ ៧៥០ | ៩ ៩០០ |
| | | ការ៉ុត | ៣ | ៣ ៥០០ | | ១៣ ៥០០ | ២៣ ៤០០ |
| | | ត្រកួន | ៥ | ១ ២៥០ | | ៦ ២៥០ | ២៩ ៦៥០ |
| | | ខ្ទឹមបារាំង | ៣ | ៣ ៥០០ | | ១០ ៥០០ | ៤០ ១៥០ |
| | | ម្ទេស | ៣០ | ១០០ក្នុង៥ ផ្លែ | | ៦០០ | ៤០ ៧៥០ |
| ២/១២/០៨ | របស់របរផ្គត់ផ្គង់ក្នុងគ្រួសារ | ម្ហូប | | | ៥ ០០០ | | ៣៥ ៧៥០ |
| ៣/១២/០៨ | ការលក់ទំនិញ | ប៉េងប៉ោះ | ២.៥ | ៣ ៤០០ | | ៨ ៥០០ | ៤៤ ២៥០ |
| | | ការ៉ុត | ១ | ៣ ៥០០ | | ៣ ៥០០ | ៤៧ ៧៥០ |
| | | ត្រកួន | ៣ | ១ ១០០ | | ៣ ៣០០ | ៥១ ០៥០ |
| | | ម្ទេស | ១០ | ៧៥ក្នុង៥ផ្លែ | | ២៥០ | ៥១ ៣០០ |

ចម្លើយករណីសិក្សារបស់ "សុភ័ក្រ"

| កាលបរិច្ឆេទ | ការទិញលក់ទំនិញ | មុខទំនិញ/សេវាកម្ម | | | ប្រាក់ចំណាយ (-) | ប្រាក់ចំណូល (+) | សមតុល្យ |
|---|---|---|---|---|---|---|---|
| | | មុខទំនិញ | បរិមាណ | តម្លៃលក់រាយ | | | |
| | | | | | | សមតុល្យដំបូង | ៣០០ ០០០ |
| ១/១២/០៨ | ការទិញទំនិញ | ផ្លែស្វាយ | ៥ គីឡូក្រាម | ៥ ០០០ | ២៥ ០០០ | | ២៧៥ ០០០ |
| | | ផ្លែសាវម៉ាវ | ៥ គីឡូក្រាម | ៥ ៥០០ | ២៧ ៥០០ | | ២៤៧ ៥០០ |
| | | ផ្លែក្រូច | ១៥ គីឡូក្រាម | ៥ ៥០០ | ៨២ ៥០០ | | ១៦៥ ០០០ |
| | | ផ្លែប៉័រ | ៥ គីឡូក្រាម | ៥ ៦០០ | ២៨ ០០០ | | ១៣៧ ០០០ |
| | | ផ្លែប៉ោម | ៦ គីឡូក្រាម | ១០ ០០០ | ៦០ ០០០ | | ៧៧ ០០០ |
| ១/១២/០៨ | ការទិញសម្ភារៈ | កញ្ច្រែង | ៥ | ១៥ ០០០ | ៧៥ ០០០ | | ២ ០០០ |
| ១/១២/០៨ | ការលក់ទំនិញ | ផ្លែស្វាយ | ២ | ៥ ៥០០ | | ១១ ០០០ | ១៣ ០០០ |
| | | ផ្លែសាវម៉ាវ | ៤ | ៦ ៣០០ | | ២៥ ២០០ | ៣៨ ២០០ |
| | | ផ្លែក្រូច | ១១ | ៦ ២០០ | | ៦៨ ២០០ | ១០៦ ៤០០ |
| | | ផ្លែប៉័រ | ៣ | ៦ ៣០០ | | ១៨ ៩០០ | ១២៥ ៣០០ |
| | | ផ្លែប៉ោម | ៤ | ១៥ ០០០ | | ៦០ ០០០ | ១៨៥ ៣០០ |
| ១/១២/០៨ | បង់ថ្លៃឈ្នួលរុញរទេះ | ថ្លៃឈ្នួលរុញរទេះ | ១ | ៤ ០០០ | ៤ ០០០ | | ១៨១ ៣០០ |
| ២/១២/០៨ | ការលក់ទំនិញ | ផ្លែស្វាយ | ៣ | ៥ ២០០ | | ១៥ ៦០០ | ១៩៦ ៩០០ |
| | | ផ្លែសាវម៉ាវ | ១ | ៥ ៤០០ | | ៥ ៤០០ | ២០២ ៣០០ |
| | | ផ្លែក្រូច | ៤ | ៥ ៣០០ | | ២១ ២០០ | ២២៣ ៥០០ |
| | | ផ្លែប៉័រ | ២ | ៦ ០០០ | | ១២ ០០០ | ២៣៥ ៥០០ |
| | | ផ្លែប៉ោម | ២ | ១៥ ០០០ | | ៣០ ០០០ | ២៦៥ ៥០០ |

# មេរៀនទី១០ ៖ ការស្វែងយល់ពីការអនុវត្តរៀបចំបញ្ជីគណនេយ្យ

🕑 **រយៈពេលបង្រៀន** ២ ម៉ោង

☑ **ការរៀបចំរបស់គ្រូមុនពេលបង្រៀន**

- ពិនិត្យមើលមេរៀនឡើងវិញឱ្យបានហ្មត់ចត់
- ពិនិត្យមើលខ្លឹមសារក្នុងសៀវភៅសិស្ស ដើម្បីដឹងពីព័ត៌មាន និងសំណួរ
- រៀបចំអញ្ជើញអ្នកជំនួញ ១ ឬ ២ នាក់នៅក្នុងសហគមន៍មកផ្ដល់បទពិសោធន៍
- សរសេរសំណួរសម្ភាសនៅលើក្រដាសផ្ទាំងធំ
- សរសេរការណែនាំស្ដីពីការប្រកាន់តំរិយាបថល្អនៅពេលធ្វើសម្ភាសដាក់លើក្រដាសផ្ទាំងធំសម្រាប់ប្រើនៅសកម្មភាពទី ៣
- សរសេរកម្រងសំណួរ និងខ្លឹមសារមេរៀន ។

📖 **សម្ភារៈ**

- ឯកសារណែនាំសម្រាប់គ្រូ
- សៀវភៅសិស្ស
- សម្ភារៈបង្រៀនដែលបានរៀបចំដូចបានរៀបរាប់ខាងលើ
- ក្រដាសផ្ទាំងធំ ហ្វឺត និង ក្ដារខៀនសម្រាប់ព្យួរក្រដាសផ្ទាំងធំ ដែលប្រើនៅក្នុងសកម្មភាពទី ២
- ក្ដារខៀន និង ដីស
- កម្រងសំណួរ និងខ្លឹមសារមេរៀន ។

☼ **លទ្ធផលសិក្សារំពឹងទុក**

ពេលរៀនមេរៀននេះចប់ សិស្សនឹងអាច ៖

- ធ្វើតារាងបង្ហាញពីតំរិយាបថសមស្របសម្រាប់ប្រើក្នុងការធ្វើសម្ភាស
- ធ្វើសម្ភាសជាមួយអ្នកជំនួញនៅក្នុងសហគមន៍
- កំណត់ព័ត៌មានសំខាន់ៗក្នុងការធ្វើសម្ភាសដែលអាចផ្ដល់ជាមធ្យោបាយសម្រាប់ឱ្យយកទៅអនុវត្តក្នុងការរៀបចំបញ្ជីគណនេយ្យឱ្យបានល្អប្រសើរ ។

# ឯកសារសម្រាប់គ្រូ

## លំនាំនៃការបង្រៀន

| សកម្មភាពទី ១ : ការរំលឹកមេរៀន | ⏲: ១០ នាទី |
|---|---|

**ការពិភាក្សា**

- ☝ ក្នុងមេរៀនមុន តើអ្នកបានរៀនអ្វីខ្លះ?[ ➢ចម្លើយ : ការបំពេញតារាងលំហូរសាច់ប្រាក់។]
- ☝ តើការប្រើប្រាស់តារាងលំហូរសាច់ប្រាក់មានប្រយោជន៍អ្វីខ្លះ?[ ➢ចម្លើយ : ធ្វើឱ្យមានការកត់ត្រាពីចំនួនប្រាក់ចំណូល និងចំណាយបានត្រឹមត្រូវនៅក្នុងកិច្ចការជំនួញ។]

| សកម្មភាពទី ២: ការបង្កើតសំណួរសម្ភាស | ⏲: ៣៥ នាទី |
|---|---|

១. គ្រូប្រាប់សិស្សថាគាត់បានអញ្ជើញអ្នកធ្វើជំនួញនៅក្នុងសហគមន៍ ដើម្បីមកធ្វើសម្ភាស។

២. គ្រូពន្យល់ទៅសិស្សថា :

នៅថ្ងៃនេះយើងត្រូវសម្ភាសអ្នកជំនួញ (១ ឬ ២ នាក់)មកពីសហគមន៍ ដើម្បីស្វែងយល់ពីរបៀបរៀបចំបញ្ជីគណនេយ្យសម្រាប់កិច្ចការជំនួញ។ ពេលទៅផ្ទះវិញយើងត្រូវបង្កើតសំណួរ ២ ដើម្បីសួរអ្នកជំនួញទាំងនោះ។ យើងមិនមានពេលគ្រប់គ្រាន់សម្រាប់សួរសំណួរទាំងអស់ទៅពួកគាត់នោះទេ ដូចនេះយើងត្រូវជ្រើសរើសសំណួរសំខាន់ៗមួយចំនួនប៉ុណ្ណោះសម្រាប់សួរ។

៣. គ្រូបិទតារាងសំណួរនៅលើក្តារខៀនឱ្យសិស្សពិនិត្យ និង ប្រៀបធៀប

- ➢ តើប្រព័ន្ធនៃការរៀបចំបញ្ជីគណនេយ្យដែល បង/ពូ/មីង/អ៊ំ ប្រើមានអ្វីខ្លះ?
- ➢ តើបញ្ហាប្រឈមអ្វីខ្លះ ដែលបង/ពូ/មីង/អ៊ំធ្លាប់ជួបប្រទះក្នុងការរៀបចំបញ្ជីគណនេយ្យ?
- ➢ តើប្រភេទប្រាក់ចំណូល និង ចំណាយ( ការលក់ទំនិញ ការខ្ចីប្រាក់ ការទិញជើ្ង ការចំណាយលើកិច្ចការសេវាកម្ម) អ្វីខ្លះដែលគេត្រូវតាមដាន?
- ➢ តើបង/ពូ/មីង/អ៊ំអាចប្រាប់ពីបទពិសោធន៍មិនល្អដែលបង/ពូ/មីង/អ៊ំ ជួបប្រទះពេលរៀបចំបញ្ជីគណនេយ្យបាន ដែរឬទេ?
- ➢ តើបង/ពូ/មីង/អ៊ំអាចប្រាប់ពីបទពិសោធន៍ល្អៗដែលបង/ពូ/មីង/អ៊ំធ្លាប់ជួបប្រទះពេលរៀបចំបញ្ជីគណនេយ្យបានដែរឬទេ?

៤. គ្រូបែងចែកសិស្សជាក្រុមដែលមានគ្នាពី៥-៦ នាក់ ដើម្បីពិនិត្យសំណួររបស់គេឡើងវិញ។

- ☝ ក្នុងមួយក្រុមៗត្រូវជ្រើសរើសសំណួរ ២ ដែលសំខាន់សម្រាប់សួរ។
- ☝ សិស្សត្រូវសរសេរសំណួរទាំងពីរនៅលើក្រដាសតូច។

- គ្រូឱ្យសិស្សក្នុងក្រុមនីមួយៗអានសំណួរជ្រើសរើសទាំង២។
- គ្រូឱ្យសិស្សជ្រើសរើសសំណួរដែលពួកគេត្រូវសួរអ្នកជំនួញមកពីសហគមន៍។

៥. សិស្សត្រូវចាំថាពួកគេមិនអាចសួរសំណួរឱ្យលើសពី ៨ បានទេ។

៦. ឱ្យសិស្សស្ម័គ្រចិត្តម្នាក់សួរសំណួរសម្ភាសទៅអ្នកជំនួញមកពីសហគមន៍។ បន្ទាប់មកសិស្សផ្សេងទៀត អាចចូលរួមក្នុងការសម្ភាសនេះ។ គ្រូត្រូវកំណត់ថាតើសិស្សណាត្រូវសួរសំណួរណា។

| សកម្មភាពទី ៣: ការប្រកាន់ឥរិយាបថសមរម្យពេលធ្វើសម្ភាស | ⏲: ១០ នាទី |
|---|---|

១. ពិភាក្សាពីរបៀបប្រកាន់ឥរិយាបថល្អនៅពេលធ្វើសម្ភាស :

- សុភាពរាបសា និងចេះគួរសម
- ត្រូវធ្វើការណែនាំខ្លួន
- ប្រាប់ពីគោលបំណងនៃការធ្វើសម្ភាស
- សុំការអនុញ្ញាតពីអ្នកធ្វើជំនួញ ២ ឬ ៣ នាទី ដើម្បីធ្វើសម្ភាស
- ត្រូវថ្លែងអំណរគុណពេលធ្វើសម្ភាសចប់។

២. គ្រូឱ្យសិស្សបង្ហាញពីឥរិយាបថល្អៗមួយចំនួនទៀត។

៣. គ្រូឱ្យសិស្សស្ម័គ្រចិត្ត ២ នាក់ សម្តែងជាឧទាហរណ៍ពីការប្រកាន់ឥរិយាបថល្អ និង អាក្រក់ក្នុងពេល ធ្វើសម្ភាស ដោយគ្រូដើរតួធ្វើជាភ្ញៀវ។

៤. សិស្សផ្សេងទៀតរៀបចំកន្លែងទទួលភ្ញៀវ និង ធ្វើការកត់ត្រាក្នុងពេលធ្វើសម្ភាស។

| សកម្មភាពទី ៤: ការធ្វើសម្ភាសជាមួយអ្នកជំនួញមកពីសហគមន៍ | ⏲៤៥ នាទី |
|---|---|

១. ភ្ញៀវបានអញ្ជើញមកដល់។

២. គ្រូទទួលស្វាគមន៍ភ្ញៀវឱ្យចូលថ្នាក់ ។ ភ្ញៀវធ្វើការណែនាំដល់សិស្សដោយប្រាប់ពី :

- ឈ្មោះ
- ប្រភេទមុខជំនួញ
- ទីកន្លែងធ្វើជំនួញ

៣. គ្រូឱ្យសិស្សធ្វើសម្ភាសតាមសកម្មភាពខាងក្រោម ៖

- សិស្សត្រូវសួរសំណួរម្នាក់ម្តងទៅកាន់ភ្ញៀវ ។
- សិស្សសម្ភាសភ្ញៀវទាំង ២ នាក់ រួមគ្នាក្នុងពេលតែមួយ ។
- គ្រូបែងចែកសិស្សជា ២ ក្រុម ហើយរៀបចំទីកន្លែង ២ ដាច់ដោយឡែកពីគ្នាសម្រាប់ការសម្ភាសភ្ញៀវម្នាក់ៗ ។ (ប្រសិនមានពេលគួរឱ្យសិស្សធ្វើការសង្ខេបពីលទ្ធផលសម្ភាសនៅក្នុងក្រុមនីមួយៗ និង ពិភាក្សាលំអិតពីចម្លើយនៃសំណួរនីមួយៗ និង ចំណុចសំខាន់ៗ) ។

៤. នៅពេលចប់ការធ្វើសម្ភាស គ្រូត្រូវថ្លែងអំណរគុណភ្ញៀវ និងសួរទៅភ្ញៀវក្រែងពួកគាត់មានពាក្យ ឬ ដំបូន្មានអ្វីដល់សិស្ស ។

៥. ពេលភ្ញៀវចេញទៅ ប្រសិនបើនៅសល់ម៉ោង សិស្សអាចធ្វើការពិភាក្សាពីអ្វីដែលគេបានឮ ក្នុងកំឡុងពេលធ្វើសម្ភាស ហើយពិនិត្យឡើងវិញលើចម្លើយដែលគេបានកត់ត្រា ។

**កិច្ចការផ្ទះ**

☞ ចូរប្អូនបំពេញសៀវភៅកំណត់ត្រាចំណាយប្រចាំថ្ងៃ ។

# មេរៀនទី១១ : ការកំណត់តម្លៃទំនិញ

**រយៈពេលបង្រៀន** ២ ម៉ោង

**ការរៀបចំរបស់គ្រូមុនពេលបង្រៀន**

- ពិនិត្យមើលមេរៀនឡើងវិញឱ្យបានហ្មត់ចត់
- ពិនិត្យមើលខ្លឹមសារក្នុងសៀវភៅសិស្ស ដើម្បីដឹងពីព័ត៌មាន និងសំណួរ
- សរសេរនិយមន័យនៃប្រាក់ចំណេញ ប្រាក់ចំណូល និងការខាត សម្រាប់សកម្មភាពទី ២
- សរសេរសំណួរនៅលើក្រដាសផ្ទាំងធំ
- កាត់ក្រដាសជាចំរៀកតូចៗសម្រាប់សកម្មភាពទី ៣
- សរសេរកម្រងសំណួរ និងខ្លឹមសារមេរៀន។

**សម្ភារៈ**

- ឯកសារណែនាំសម្រាប់គ្រូ
- សៀវភៅសិស្ស
- រៀបចំសម្ភារៈបង្រៀនដូចដែលបានកំណត់ខាងលើ
- ក្រដាសផ្ទាំងធំស្តីពីការប្រកាន់ឥរិយាបថល្អពេលធ្វើសម្ភាសសម្រាប់មេរៀនមុន
- ក្រដាសផ្ទាំងធំ ហ្វឺត និង ក្តារខៀនសម្រាប់ព្យួរក្រដាសផ្ទាំងធំ។
- ក្តារខៀន និង ដីស
- ឡាំងតូច ប្រអប់ មួកសម្រាប់ដាក់ចម្រៀកក្រដាសតូចៗ
- កម្រងសំណួរ និងខ្លឹមសារមេរៀន។

**លទ្ធផលសិក្សារំពឹងទុក**

ពេលរៀនមេរៀននេះចប់ សិស្សនឹងអាច :

- កំណត់និយមន័យប្រាក់ចំណូល ប្រាក់ចំណេញ និង ប្រាក់ខាតបង់ នៅក្នុងការរៀបចំបញ្ជីគណនេយ្យ
- បំពេញតារាងលំហូរសាច់ប្រាក់ជាមូលដ្ឋានសម្រាប់ការធ្វើជំនួញ
- ប៉ាន់ស្មានតម្លៃលក់ តាមរយៈតារាងលំហូរសាច់ប្រាក់។

**លំនាំនៃការបង្រៀន**

| សកម្មភាពទី ១: ពិនិត្យឡើងវិញលើលទ្ធផលដែលបានពីការសិក្សានៅមេរៀនមុន | ⌚: **១០ នាទី** |
|---|---|

គ្រូនាំសិស្សពិភាក្សាសំណួរខាងក្រោម

- តើប្អូនៗបានរកឃើញសារៈសំខាន់អ្វីខ្លះទាក់ទងនឹងការធ្វើសម្ភាស?
- ពេលធ្វើសម្ភាស តើប្អូនៗបានរៀនអ្វីខ្លះ អំពីការរៀបចំបញ្ជីគណនេយ្យល្អ ឬ ការអនុវត្តមុខជំនួញសម្រាប់ ការប្រកបមុខរបរប្អូននៅពេលអនាគត?
- នៅពេលធ្វើសម្ភាស តើចំណុចអ្វីខ្លះដែលប្អូនគិតថាមិនសំខាន់ ឬមិនមានប្រយោជន៍សម្រាប់ការអនុវត្ត?
- តើអ្នកនៅមានសំណួរអ្វីខ្លះដែលអ្នកមិនបានសួរ ហើយអ្នកនៅតែចង់ដឹង?

| សកម្មភាពទី ២: ការស្វែងយល់ពីប្រាក់ចំណូល ប្រាក់ចំណេញ និង ប្រាក់ខាតបង់ | ⌚: **២០ នាទី** |
|---|---|

១. គ្រូសួរទៅសិស្ស "តើពាក្យថាប្រាក់ចំណូល ប្រាក់ចំណេញ និង ការខាតបង់ប្រាក់មានន័យដូចម្ដេច ?

[➢**ចម្លើយរំពឹងទុក**

- ➢ **ប្រាក់ចំណូល :** ជាប្រាក់ដែលបានមកពីការលក់ទំនិញ ឬ ការផ្ដល់សេវាកម្ម ។
- ➢ **ប្រាក់ចំណេញ :** ជាប្រាក់ដែលនៅសល់ពីការទូទាត់រវាងប្រាក់ដែលបានមកពីការលក់ទំនិញ ឬ ការផ្ដល់សេវាកម្ម ជាមួយប្រាក់ដែលបានចំណាយទៅលើការទិញទំនិញ ឬការផ្ដល់សេវាកម្ម ក្នុងការធ្វើជំនួញ ។ ប្រាក់ចំណេញខុសពីប្រាក់ចំណូល ។
- ➢ **ប្រាក់ខាតបង់ :** ជាប្រាក់ដែលបានមកពីការលក់ទំនិញ ឬ ការផ្ដល់សេវាកម្មដែលមានចំនួនតិចជាងប្រាក់ដែលបានចំណាយទៅលើការទិញទំនិញ ឬការផ្ដល់សេវាកម្មក្នុងការធ្វើជំនួញ ។ ក្នុងករណីនេះអ្នកនៅតែមានប្រាក់ចំណូល ប៉ុន្តែវាជាប្រាក់ចំណូលដែលតិចជាងប្រាក់ចំណាយ ។]

២. បន្ទាប់មកគ្រូបិទនិយមន័យនៃពាក្យទាំងនេះនៅលើក្ដារខៀន និង ពន្យល់បញ្ជាក់បន្ថែម រួចឱ្យសិស្សកត់ចូលក្នុងសៀវភៅរបស់គេ ។

៣. តើប្រាក់ចំណូល និង ប្រាក់ចំណេញខុសគ្នាដូចម្ដេច?

[ ➢ចម្លើយ : ប្រាក់ចំណូលជាចំនួនប្រាក់សរុបទាំងអស់ដែលបានមកពីការធ្វើជំនួញ ។ ប្រាក់ចំណេញ ជាប្រាក់ដែលនៅសល់ក្រោយពីការទូទាត់រួចរាល់លើការចំណាយទាំងអស់ ។]

៤. គ្រូពន្យល់ខ្លឹមសារមេរៀន ៖

ការសិក្សាមេរៀនទាំងនេះ គឺជាការស្វែងយល់ពីភាពខុសគ្នារវាងប្រាក់ចំណូល និងការបង្ហាញប្រាប់ឱ្យយើងដឹងថាតើយើងកំពុងធ្វើជំនួញបានចំណេញ ឬខាត។ ប្រសិនបើមុខជំនួញរបស់យើងកំពុងតែទទួលបានប្រាក់ចំណេញ យើងមានឱកាសក្នុងការពង្រីកមុខជំនួញរបស់យើង ហើយយើងមានប្រាក់សម្រាប់ចំណាយផ្ទាល់ខ្លួនទៀតផង។ ប្រសិនបើយើងខាត នោះយើងមិនអាចទ្រទ្រង់ជីវភាព មិនអាចសងបំណុលគេ ហើយប្រាក់ផ្ទាល់ខ្លួនក៏ត្រូវកាត់បន្ថយ មិនអាចមានលទ្ធភាពបន្តមុខជំនួញបាន។

៥. គ្រូបញ្ជាក់ពីគោលបំណងនៃមេរៀននេះ។

**សកម្មភាពទី៣ ៖ ការកំណត់តម្លៃ** ⏲: **៤០ នាទី**

១. ក្រុមសិស្សពិភាក្សាដើម្បីបង្កើតតារាងស្តីពីប្រភេទមុខជំនួញសំខាន់ៗនៅតាមទីផ្សារក្នុងមូលដ្ឋាន។ គ្រូសរសេរឈ្មោះមុខជំនួញទាំងនេះនៅលើក្រដាសតូចដាច់ដោយឡែកពីគ្នា។ប្រសិនបើមុខជំនួញណាមិនចាំបាច់គ្រូមិនបាច់បញ្ចូលក្នុងតារាងទេ។ (ចម្លើយរំពឹងទុក៖ ការលក់ផ្លែឈើ ការលក់បន្លែ រត់ម៉ូតូឌុប ការលក់គុយទាវ លក់គ្រឿងតុ ទូ។ល។) ត្រូវរកឧទាហរណ៍ឱ្យបានពី ៦-១០។

២. គ្រូមូរក្រដាសទាំងនេះ រួចដាក់ចូលទៅក្នុងឡាំងតូច (កំប៉ុង ឬ មួក ឬ ប្រអប់)។

៣. គ្រូបែងចែកសិស្សជាក្រុមតូចមានគ្នា ៤-៥ នាក់ និង ពន្យល់៖

- សម្រាប់តារាងមុខជំនួញដែលប្អូនយកចេញពីប្រអប់ ប្អូនត្រូវបំពេញសញ្ញា “ + ” សម្រាប់ប្រាក់ ចំណូល និង សញ្ញា “ - ” សម្រាប់ប្រាក់ចំណាយ។ ប្អូនៗត្រូវចាំថាកិច្ចការជំនួញគឺមានការប្រែប្រួលជានិច្ច។ គ្រូត្រូវចងចាំពីទម្រង់នៃការប្រើតារាងនេះ។

| **-(ប្រាក់ចំណាយ)** | **+(ប្រាក់ចំណូល)** |
|---|---|
| | |

- ពិនិត្យចំនួនប្រាក់ដែលចំណាយទៅលើមុខទំនិញ ឬ ការផ្តល់សេវាកម្ម យើងអាចសាកល្បងទាយពីតម្លៃដែលយើងត្រូវលក់ផលិតផលខាងលើ។
- ទាក់ទងនឹងវិធីកំណត់តម្លៃទំនិញ ៖ មុនពេលយើងធ្វើការកំណត់តម្លៃមុខទំនិញនីមួយៗ ដែលត្រូវលក់ជាដំបូងយើងត្រូវសាកល្បងប៉ាន់តម្លៃលក់ដុំនៅទីផ្សារជាមុនសិន។

- យើងត្រូវប្រើព័ត៌មានទាំងនេះ ដើម្បីកំណត់តម្លៃមុខទំនិញ ឬ សេវាកម្មដែលសមស្របចំពោះមុខទំនិញនៅក្នុងសហគមន៍ដែលគ្រូបានកំណត់ឱ្យ ។

៤. ក្រុមនីមួយៗត្រូវដកយកក្រដាសមុខជំនួញចេញពីប្រអប់មកពិនិត្យ ហើយចាប់ផ្តើមពិភាក្សាការងារក្រុមរបស់គេ គ្រូដើរពិនិត្យមើលក្រុមសិស្សធ្វើការ ។

| សកម្មភាពទី៤ : ការប្រមូលព័ត៌មានពីតម្លៃទំនិញ | ៣០ នាទី |
|---|---|

១. គ្រូប្រាប់សិស្សឱ្យនៅតាមក្រុមតូចរបស់គេដដែល ។

២. គ្រូប្រាប់ក្រុមសិស្សឱ្យទៅសម្ភាសអ្នកលក់ដូរ ២ នាក់នៅផ្សារចំពោះមុខទំនិញ ឬសេវាកម្មដែលគេបានជ្រើសរើស ។

៣. ប្អូនត្រូវធ្វើសម្ភាសអ្នកលក់ដូរនៅផ្សារឱ្យបាន២នាក់យ៉ាងតិច ដើម្បីប្រមូលព័ត៌មានអំពីតម្លៃលក់ទំនិញ ។ គ្រូផ្តល់សំណួរសម្ភាសមួយចំនួនឱ្យសិស្ស ហើយសិស្សត្រូវបង្កើតសំណួរបន្ថែមទៀតនៅក្នុងក្រុម តូច ។

៤. ខាងក្រោមនេះជាសំណួរមួយចំនួនដែលប្អូនៗប្រើសម្រាប់ធ្វើសម្ភាស ។ ចូរសរសេរសំណួរទាំងនេះនៅក្នុងសៀវភៅកត់ត្រារបស់ប្អូន ឬមើលនៅក្នុងសៀវភៅសិស្ស :
   - តើទំនិញដែលបង/ពូ/មីង/អ៊ំលក់គេឱ្យថ្លៃប៉ុន្មាន?
   - ជាធម្មតាតើបង/ពូ/មីង/អ៊ំលក់ថ្លៃប៉ុន្មាន?
   - តើបង/ពូ/មីង/អ៊ំកំណត់តម្លៃលក់ដោយរបៀបណា?
   - ក្នុងមួយឆ្នាំៗ តើតម្លៃលក់មានការប្រែប្រួលដែរឬទេ? ហេតុអ្វី?
   - តើមានការលំបាកអ្វីខ្លះដែលបង/ពូ/មីង/អ៊ំធ្លាប់ជួបប្រទះក្នុងការកំណត់តម្លៃ?
   - ជានិច្ចកាល តើបង/ពូ/មីង/អ៊ំតែងទទួលបានប្រាក់ចំណេញក្នុងការលក់ដែរឬទេ? បើមិនចំណេញ តើមកពីមូលហេតុអ្វីខ្លះ?
   - តើបង/ពូ/មីង/អ៊ំធ្វើដូចម្តេច ដើម្បីទាក់ទាញ ឬ រក្សាភ្ញៀវឱ្យមកទិញទំនិញរបស់អ្នក?

៥. ទុកពេលឱ្យក្រុមសិស្សពិនិត្យមើលសំណួរឡើងវិញ និង បង្កើតសំណួរ ១ ឬ ២ ផ្សេងទៀតដែលពួកគេចង់សួរ ។

៦. គ្រូប្រាប់ក្រុមសិស្សទាំងអស់ឱ្យមករួមគ្នាវិញក្នុងក្រុមធំ ដើម្បីពិភាក្សាពីសំណួរ ដែលក្រុមតូចបានបង្កើត ។

៧. គ្រូរំលឹកសិស្សក្រុមតូចទាំងអស់ថាត្រូវប្រកាន់ឥរិយាបថសុភាពរាបសាក្នុងពេលធ្វើសម្ភាស ។

| កិច្ចការផ្ទះ |
|---|

# ឯកសារសម្រាប់គ្រូ

១. ធ្វើសម្ភាស ២ និង ធ្វើការកត់ត្រាពេលធ្វើសម្ភាស ។

២. រៀបចំការកត់ត្រាចម្លើយដែលបានមកពីការធ្វើសម្ភាសសម្រាប់ឱ្យគ្រូពិនិត្យ ។

៣. រៀបចំធ្វើការជាក្រុម ដើម្បីធ្វើការបង្ហាញដោយសង្ខេបពីខ្លឹមសារនៃការសម្ភាស (រយៈពេល ៥ នាទី) ។

៤. ប្រើសៀវភៅកំណត់ត្រាចំណាយប្រចាំថ្ងៃរបស់អ្នកកាលពី ៤ សប្តាហ៍មុន ហើយបំពេញព័ត៌មាននៅជួរ "ចំនួនជាក់ស្តែង" និង ជួរ "ភាពខុសគ្នា" នៅក្នុងជួរតារាងថវិកាប្រចាំខែរបស់អ្នកដែលត្រូវពិនិត្យមើលឡើងវិញនៅសប្តាហ៍ក្រោយ ។

## មេរៀនទី១២ ៖ ការស្វែងយល់ពីបញ្ហាកំណត់តម្លៃ

**រយៈពេលបង្រៀន** ២ ម៉ោង

### ☑ ការរៀបចំរបស់គ្រូមុនពេលបង្រៀន

- ពិនិត្យមើលមេរៀនឡើងវិញឱ្យបានហ្មត់ចត់
- ពិនិត្យមើលខ្លឹមសារក្នុងសៀវភៅសិស្ស ដើម្បីដឹងពីព័ត៌មាន និងសំណួរ
- សរសេរសំណួរនៅលើក្រដាសផ្ទាំងធំសម្រាប់ផ្នែកទី២ នៅសកម្មភាពទី ១
- សរសេរកម្រងសំណួរ និងខ្លឹមសារមេរៀន។

### សម្ភារៈ

- ឯកសារណែនាំសម្រាប់គ្រូ
- សៀវភៅសិស្ស
- រៀបចំសម្ភារៈបង្រៀនដូចដែលមានរៀបរាប់ខាងលើ
- ក្រដាសផ្ទាំងធំស្តីពីការប្រកាន់ឥរិយាបថល្អពេលធ្វើសម្ភាស
- ក្រដាសផ្ទាំងធំ, ហ្វឺត និង ក្តារខៀនសម្រាប់ព្យួរក្រដាសផ្ទាំងធំ
- ក្តារខៀន និង ដីស
- ឡាំងតូច ប្រអប់ មួកសម្រាប់ដាក់ចម្រៀកក្រដាសតូចៗ
- កម្រងសំណួរ និងខ្លឹមសារមេរៀន។

### ☼ លទ្ធផលសិក្សារំពឹងទុក

ពេលរៀនមេរៀននេះចប់ សិស្សនឹងអាច ៖

- សម្ភាសជាមួយអ្នកលក់ដូរនៅផ្សារក្នុងមូលដ្ឋាន
- បង្ហាញពីលទ្ធផលនៃការសម្ភាសដល់សិស្សទាំងអស់នៅក្នុងថ្នាក់
- ប្រើបទពិសោធន៍នៃការសម្ភាសតាមផ្សារ ដើម្បីគណនាពីតម្លៃលើកមុន
- ពន្យល់ពីគុណសម្បត្តិ និង គុណវិបត្តិមុខជំនួញតាមផ្សារ
- បង្ហាញពីវិធី ដែលអ្នកលក់ប្រើដើម្បីទាក់ទាញ ឬ រក្សាភ្ញៀវរបស់គេ។

**លំនាំនៃការបង្រៀន**

| សកម្មភាពទី ១: បង្ហាញលទ្ធផលការសម្ភាសស្ដីពីការកំណត់តម្លៃ | ⌚: ៥៥ នាទី |
|---|---|

១. គ្រូណែនាំសិស្សចូលក្រុមតូច ហើយទុកពេល ២០ នាទីដើម្បីរៀបចំការបង្ហាញរបស់ពួកគេ។ ចែកក្រដាសផ្ទាំងធំឱ្យក្រុមនីមួយៗប្រើសម្រាប់រៀបចំការបង្ហាញ។

២. ក្រុមសិស្សធ្វើការបង្ហាញពីលទ្ធផលនៃការធ្វើសម្ភាសរបស់ពួកគេដោយសង្ខេប :

- តើប្អូនៗបានទៅសម្ភាសអ្នកណា?
- តើទំនិញ ឬសេវាកម្មរបស់ពួកគេមានអ្វីខ្លះ?
- ចូរសង្ខេបចម្លើយដែលប្អូនៗបានសួរនៅពេលធ្វើសម្ភាស។
- តាមរយៈការធ្វើសម្ភាស តើប្អូនៗជឿថាតម្លៃទំនិញរបស់គាត់ត្រឹមត្រូវ និង សមហេតុផលដែរឬទេ ប្រសិនបើប្អូនៗជាអ្នកលក់ទំនិញនៅផ្សារ? ចូរពន្យល់?
- តើការទិញលក់ទំនិញរបស់មនុស្សដែលអ្នកបានធ្វើសម្ភាសមានកំណត់តម្លៃបែបណាមួយ ដែលក្រុមរបស់ប្អូនមិនបានធ្វើដែរឬទេ?
- តើមានបច្ចេកទេសអ្វីខ្លះដែលពួកគេប្រើដើម្បីទាក់ទាញ ឬ រក្សាភ្ញៀវរបស់គេ?

| សកម្មភាពទី ២: ការវាយតម្លៃឡើងវិញលើតម្លៃទំនិញរបស់យើង | ⌚ ២៥ នាទី |
|---|---|

គ្រូទុកពេលឱ្យក្រុមសិស្សពិភាក្សា ដើម្បីធ្វើការវាយតម្លៃឡើងវិញលើការសម្រេចចិត្តកាលពីលើកមុនពីការបំពេញសញ្ញា “+” និង “-” នៅក្នុងតារាង ស្ដីពីប្រាក់ចំណូល ប្រាក់ចំណាយ និងការកំណត់តម្លៃ។

- តើតម្លៃលក់របស់ប្អូនស្ថិតនៅក្រោម ឬ នៅលើអត្រាតម្លៃលក់នៅទីផ្សារ?
- ផ្អែកលើការធ្វើសម្ភាស តើប្អូនគួរកែប្រែព័ត៌មាននៅក្នុងតារាងប្រាក់ចំណូល និង ប្រាក់ចំណាយរបស់ប្អូនដែរឬទេ?
- តើក្រុមរបស់ប្អូនគួរតែគណនាឡើងវិញពីតម្លៃលក់ទំនិញ ឬ សេវាកម្មរបស់ ប្អូន ដើម្បីធ្វើឱ្យមានប្រាក់ចំណេញ និង មានលក្ខណៈប្រកួតប្រជែងតម្លៃដែរឬទេ?
- ប្រសិនបើត្រូវគណនាតម្លៃទំនិញឡើងវិញ ចូរធ្វើកិច្ចការនោះ។
- តើមានគុណសម្បត្តិ និង គុណវិបត្តិអ្វីខ្លះចំពោះមុខជំនួញនៅតាមទីផ្សាររបស់អ្នក?
  [➢ចម្លើយរំពឹងទុក : កើតមានតាមរដូវកាល ទទួលបានប្រាក់ចំណេញតិចតួច មានការប្រែប្រួលតម្លៃក្នុងទីផ្សារ មិនមានតម្រូវការគ្រប់គ្រាន់...]

# ឯកសារសម្រាប់គ្រូ

| សកម្មភាពទី៣ : ការពិភាក្សាការវាយតម្លៃឡើងវិញលើតម្លៃទំនិញរបស់យើង | ២០ នាទី |
|---|---|

គ្រូឱ្យសិស្សពិភាក្សាលើចំណុចខាងក្រោម :

- តើក្រុមណាខ្លះ ដែលការកំណត់តម្លៃលក់ស្ថិតនៅក្រោមតម្លៃលក់នៅទីផ្សារ? ចូរពន្យល់ ។
- តើក្រុមណាខ្លះ ដែលការកំណត់តម្លៃលក់ស្ថិតនៅលើតម្លៃលក់នៅទីផ្សារ? ចូរពន្យល់ ។
- តើក្រុមណាខ្លះ ដែលបានសម្រេចចិត្តកែប្រែការកំណត់តម្លៃលក់? ចូរពន្យល់ពីមូលហេតុ ។
- តើប្អូនគិតថាមុខជំនួញនៅទីផ្សាររបស់ប្អូនកំពុងតែបង្កើនប្រាក់ចំណូល ប៉ុន្តែនៅតែមានលក្ខណៈប្រកួតប្រជែង?
- ចូរលើកពីគុណសម្បត្តិ និង គុណវិបត្តិមួយចំនួននៃការប្រកបមុខជំនួញនៅទីផ្សារ ។
- តើមានវិធីសាស្ត្រអ្វីខ្លះដែលអ្នកចង់ប្រើដើម្បីទាក់ទាញ និង រក្សាអតិថិជនរបស់អ្នក?

| កិច្ចការផ្ទះ |
|---|

- នៅសប្តាហ៍ក្រោយយើងនឹងពិនិត្យឡើងវិញនូវតារាងគ្រោងថវិកាប្រចាំខែផ្ទាល់ខ្លួនរបស់យើង ។ ដូចនេះប្អូនៗត្រូវបំពេញចំនួនថវិកាទាំងនេះនៅជួរ " **ចំនួនជាក់ស្តែង** " និង ជួរ "**ភាពខុសគ្នា**" ។ ប្រសិនបើប្អូនៗធ្វើមិនចប់ប្អូនៗអាចយកទៅធ្វើបន្ថែមនៅផ្ទះ ។

## មេរៀនទី១៣ : ការធ្វើជំនួញ និង ថវិកាផ្ទាល់ខ្លួន

**រយៈពេលបង្រៀន** ២ ម៉ោង

**ការរៀបចំរបស់គ្រូមុនពេលបង្រៀន**

- ពិនិត្យមើលមេរៀនឡើងវិញឱ្យបានហ្មត់ចត់
- ពិនិត្យមើលខ្លឹមសារក្នុងសៀវភៅសិស្ស ដើម្បីដឹងពីព័ត៌មាន និងសំណួរ
- សរសេរករណីសិក្សានីមួយៗនៅលើក្រដាសផ្សេងគ្នា។
- សរសេរកម្រងសំណួរខ្លឹមសារមេរៀននៅលើក្រដាសផ្ទាំងធំ ។

**សម្ភារៈ**

- ឯកសារណែនាំសម្រាប់គ្រូ
- សៀវភៅសិស្ស
- រៀបចំសម្ភារៈបង្រៀនដូចដែលមានរៀបរាប់ខាងលើ
- ក្ដារខៀន និង ដីស
- សៀវភៅកត់ត្រា
- ឡាំងតូច, ប្រអប់, មួកសម្រាប់ដាក់ចម្រៀកក្រដាសតូចៗ
- ក្រដាសផ្ទាំងធំ និង ហ្វឺត
- កម្រងសំណួរ និងខ្លឹមសារមេរៀន។

**លទ្ធផលសិក្សារំពឹងទុក**

ពេលរៀនមេរៀននេះចប់ សិស្សនឹងអាច :

- បំពេញតារាងគ្រោងថវិកាចំណាយផ្ទាល់ខ្លួនប្រចាំខែ
- បែងចែកឱ្យច្បាស់រវាងប្រាក់ចំណាយលើកិច្ចការជំនួញ និង ប្រាក់ចំណាយផ្ទាល់ខ្លួន
- បញ្ជាក់ពីមូលហេតុស្ដីពីសារៈសំខាន់នៃការទុកដាក់ថវិកាទាំងនេះនៅដាច់ដោយឡែកពីគ្នា
- កំណត់វិធីទុកដាក់ថវិកាទាំងនេះឱ្យនៅដាច់ដោយឡែកពីគ្នា។

**លំនាំនៃការបង្រៀន**

| សកម្មភាពទី១: ការពិនិត្យឡើងវិញនូវតារាងគ្រោងថវិកាប្រចាំខែផ្ទាល់ខ្លួន | ⏲: ៣០ នាទី |
|---|---|

១. គ្រូឱ្យសិស្សពិនិត្យមើលសៀវភៅកំណត់ត្រាចំណាយប្រចាំថ្ងៃ និង ថវិកាប្រចាំខែផ្ទាល់ខ្លួនឡើងវិញ។ ថវិកាប្រចាំខែត្រូវយកទៅបំពេញនៅផ្ទះ។

២. គ្រូពិនិត្យមើលថវិកាប្រចាំខែជាមួយសិស្ស

- គ្រូសួរសិស្សបញ្ជាក់ក្រែងពួកគេបានជួបប្រទះបញ្ហាប្រឈមក្នុងការបង្កើតថវិកាប្រចាំខែ។
- គ្រូឱ្យសិស្សលើកដៃ ប្រសិនបើសមតុល្យរវាងប្រាក់ចំណូល និង ប្រាក់ចំណាយរបស់គេមានលក្ខណៈដូចខាងក្រោម:
  - វិជ្ជមាន? (ប្រាក់ចំណូលមានចំនួនច្រើនជាងប្រាក់ចំណាយ)
  - អវិជ្ជមាន? (ប្រាក់ចំណូល មានចំនួនតិចជាង ប្រាក់ចំណាយ)
- ឱ្យសិស្សពិភាក្សាពីចម្លើយរបស់គេ និងមូលហេតុដែលបញ្ជាក់ពីលទ្ធផលវិជ្ជមាន និងអវិជ្ជមាន។
  - (ចម្លើយរំពឹងទុកសម្រាប់ចំនួនប្រាក់ខុសគ្នាដែលអវិជ្ជមាន :
    - ប្រាក់ចំណូលរបស់គេទទួលបានតិចជាងចំនួនដែលគេបានរំពឹងទុក។
    - ពួកគេភ្លេចដាក់បញ្ចូលប្រភេទការចំណាយមួយចំនួននៅក្នុងថវិការបស់គេ។
    - ពួកគេបានចំណាយច្រើនជាងប្រភេទចំណាយពិតដែលគេបានធ្វើផែនការ។
    - ពួកគេមានតម្រូវការបន្ទាន់ក្នុងការចំណាយដែលគ្មាននៅក្នុងគម្រោង។
    - ពួកគេគណនាចំនួនប្រាក់សរុបរបស់គេខុសនៅក្នុងតារាងគ្រោងថវិកា។
    - តម្លៃមុខទំនិញឡើងថ្លៃដោយសារអតិផរណា ឬ តម្រូវការច្រើន។
  - (ចម្លើយរំពឹងទុកសម្រាប់ចំនួនប្រាក់ខុសគ្នាដែលវិជ្ជមាន :
    - ប្រាក់ចំណូលរបស់គេទទួលបានច្រើនជាងចំនួនដែលគេបានរំពឹងទុក។
    - ពួកគេបានដាក់បញ្ចូលប្រភេទការចំណាយមួយចំនួននៅក្នុងថវិការបស់គេ។
    - ពួកគេបានចំណាយតិចជាងប្រភេទចំណាយពិតដែលគេបានធ្វើផែនការ។
    - ពួកគេបានសម្រេចចិត្តចំណាយតិច ដោយសារពួកគេត្រូវការសន្សំប្រាក់ឱ្យបានច្រើន។
    - មុខទំនិញមួយចំនួនដែលគេត្រូវទិញអស់ថវិកាតិចជាងចំនួនថវិកាដែលគេបានគ្រោង)
- តើប្អូនៗ ត្រូវធ្វើអ្វីផ្សេងទៀតក្នុងការង្កើតថវិកាប្រចាំខែថ្មីដែរឬទេ?
  - [ចម្លើយរំពឹងទុក :

- តាមការគិតឃើញរបស់សិស្ស
- កែលំអប្រភេទចំណូលចំណាយឱ្យទាន់ស្ថានភាព
- ពិនិត្យមើលទៅលើតម្លៃទំនិញបច្ចុប្បន្ន
- ធ្វើផែនការសន្សំប្រាក់នៅក្នុងគំរោងថវិកា
- ។ល។]

៣- ការពិភាក្សា ការបង្កើតគម្រោង

☞ រំលឹកឡើងវិញ ថាតើអ្វីជាសារៈសំខាន់នៃការបង្កើតគំរោងថវិកា?

➢ [ចម្លើយរំពឹងទុកៈដើម្បីធ្វើឱ្យប្រាកដនោះគឺថា ប្រាក់របស់អ្នកនឹងត្រូវមានចំនួនគ្រប់គ្រាន់សម្រាប់ទូទាត់លើការចំណាយចាំបាច់នានា។ ត្រូវធ្វើផែនការ និងសន្សំប្រាក់មួយចំនួនសម្រាប់អនាគត។ ត្រូវចំណាយប្រាក់ឱ្យមានប្រសិទ្ធភាពដោយធ្វើការត្រួតពិនិត្យលើប្រាក់ចំណូល និងប្រាក់ចំណាយ។ ត្រូវស្វែងយល់ឱ្យបានស៊ីជំរៅពីស្ថានភាពហិរញ្ញវត្ថុ ដើម្បីធ្វើឱ្យអ្នកអាចមានលទ្ធភាពត្រួតពិនិត្យរៀបចំថវិការបស់អ្នកសម្រាប់អនាគត។]

☞ តើអ្នកឃើញមានការប្រែប្រួលនៅក្នុងទម្លាប់ចំណាយប្រាក់របស់អ្នក ក្រោយពីបានរៀនធ្វើផែនការកត់ត្រាចំណាយប្រចាំថ្ងៃ និងការធ្វើផែនការថវិកាដែរឬទេ?

➢ [ចម្លើយរំពឹងទុក : តាមការគិតឃើញរបស់សិស្ស]

☞ តើអ្នកគិតថាការបង្កើតផែនការថវិកាអាចធ្វើឱ្យមានការប្រែប្រួលដល់ទម្លាប់នៃការចំណាយដូចម្តេច?

➢ [ចម្លើយរំពឹងទុកអាចមានដូចខាងក្រោម តែមិនមានកំណត់នោះឡើយៈ

- ការបង្កើតផែនការថវិកាអាចធ្វើឱ្យមនុស្សយល់បានកាន់តែច្បាស់ពីរបៀបធ្វើឱ្យមានសមតុល្យដល់ប្រាក់ចំណូល និងចំណាយរបស់គេ។
- ការបង្កើតផែនការថវិកាអាចធ្វើឱ្យមនុស្សគិតទុកជាមុនពីអ្វីដែលគេសង្ឃឹមថាទទួលបាន និងអ្វីដែលគេត្រូវធ្វើផែនការចំណាយ។
- ការបង្កើតផែនការថវិកាអាចធ្វើឱ្យមនុស្សកាត់បន្ថយបានពីការចំណាយដោយឥតព្រាងទុក និងការចំណាយលើរបស់ប្រណិតដែលមិនបានធ្វើផែនការចំណាយ។]

☞ តើអ្នកគិតថាការកត់ត្រាចំណាយប្រចាំថ្ងៃអាចធ្វើឱ្យប្រែប្រួលដល់ទម្លាប់នៃការចំណាយយ៉ាងដូចម្តេច?

➢ [ចម្លើយរំពឹងទុកអាចមានដូចខាងក្រោម

- ការកត់ត្រាចំណាយប្រចាំថ្ងៃធ្វើឱ្យគេអាចរៀបចំឯកសារចំណាយគ្រប់ប្រភេទរបស់គេបាន។

- តាមរយៈការរៀបចំឯកសារចំណាយទាំងនោះ ធ្វើឱ្យគេចងចាំបានពីអ្វីដែលត្រូវចំណាយ ។
- ការកត់ត្រាការចំណាយជួយធ្វើឱ្យគេវិភាគបានយ៉ាងងាយស្រួលលើការចំណាយនានាដែលពួកគេពេញចិត្តចង់ចំណាយ និង មិនចង់ចំណាយ ។
- ការកត់ត្រាការចំណាយបានត្រឹមត្រូវធ្វើឱ្យយើងចេះគិតយ៉ាងប្រុងប្រយ័ត្នពីចំនួនប្រាក់ដែលត្រូវចំណាយ និងអ្វីៗដែលត្រូវចំណាយ. . .។]

| សកម្មភាពទី ២: សេចក្ដីផ្ដើម | ១៥ នាទី |
|---|---|

១. គ្រូពន្យល់សិស្ស

បញ្ហាដែលសំខាន់ទាក់ទងនឹងការប្រកបមុខរបរខ្នាតតូចនៅក្នុងសហគមន៍របស់យើងនោះគឺកង្វះខាតការយល់ដឹងរវាងប្រាក់ធ្វើជំនួញ និងប្រាក់ប្រើប្រាស់ផ្ទាល់ខ្លួនឱ្យបានច្បាស់លាស់ព្រោះពួកគេច្រើនដាក់បញ្ចូលគ្នា។ អ្នកធ្វើជំនួញជាច្រើនក៏ភ្លេចផងដែរក្នុងការធ្វើកំណត់សម្គាល់ពីភាពខុសគ្នារវាងប្រាក់ចំណូល និងប្រាក់ចំណេញ ។ ពួកគេតែងជួបប្រទះកង្វះខាតថវិកាដើម្បីរក្សា ឬធ្វើឱ្យកិច្ចការជំនួញមានការរីកចម្រើន ។ ពួកគេតែងទុកកិច្ចការផ្ទាល់ខ្លួនជាប់ទាក់ទងនឹងការអនុវត្តកិច្ចការជំនួញ ។ មេរៀននេះនឹងបង្ហាញឱ្យឃើញពីសារៈសំខាន់នៃការ កត់សម្គាល់ពីភាពខុសគ្នារវាងប្រាក់ធ្វើជំនួញនិងប្រាក់ផ្ទាល់ខ្លួន ។

២. គ្រូបង្ហាញសិស្សពីគោលបំណងនៃមេរៀននៅថ្ងៃនេះ ។

៣. គ្រូឱ្យសិស្សប្រាប់ឈ្មោះប្រភេទមុខជំនួញមួយចំនួនដែលកំពុងតែដំណើរការនៅតាមមូលដ្ឋាន ។

៤. គ្រូឱ្យសិស្សជ្រើសរើសមុខជំនួញមួយក្នុងចំណោមមុខជំនួញដែលបានលើកឡើងសម្រាប់ធ្វើការពិភាក្សា ។

៥. គ្រូនាំសិស្សពិភាក្សាលើចំណុចដូចតទៅ: នៅក្នុងមេរៀននេះយើងនឹងពិភាក្សាពីប្រភេទផ្សេងៗនៃការចំណាយ ។

- ចូរកំណត់ការចំណាយជាក់លាក់ក្នុងការធ្វើជំនួញ ដើម្បីធ្វើឱ្យកិច្ចការជំនួញមានស្ថេរភាព ។
  - ចម្លើយរំពឹងទុក :
    - សម្ភារៈ
    - កម្លាំងពលកម្ម
    - ឧបករណ៍ប្រើប្រាស់
    - ថ្លៃអគ្គិសនី
    - ថ្លៃជួលផ្ទះ
    - ថ្លៃទឹក ។ល ។
- ចូរកំណត់ការចំណាយជាក់លាក់របស់អ្នកធ្វើជំនួញម្នាក់ក្នុងការផ្គត់ផ្គង់ការចំណាយនៅក្នុងក្រុមគ្រួសាររបស់គេ ។
  - ចម្លើយរំពឹងទុក :

- o អាហារ
- o កន្លែងស្នាក់នៅ
- o សំលៀកបំពាក់
- o ការព្យាបាលជំងឺ
- o ថ្លៃសាលា
- o . . . . . . . . . .

☞ ចូរកំណត់តម្រូវការប្រាក់មួយចំនួនដែលមិនបានរំពឹងទុកទាក់ទងនឹងការធ្វើជំនួញ។

➢ចម្លើយរំពឹងទុករួមមាន :

- o ផលិតផលដែលបាត់បង់ ឬ ផលិតផលដែលខូចខាត
- o ការប្រែប្រួលតម្លៃទីផ្សារ
- o ការប្រែប្រួលថ្លៃដឹកជញ្ជូន

☞ ចូរកំណត់តម្រូវការប្រាក់ដែលមិនបានរំពឹងទុកសម្រាប់គ្រួសារ :

➢ចម្លើយរំពឹងទុក :

- o ការព្យាបាលជំងឺជាបន្ទាន់
- o ការបាត់បង់ទ្រព្យសម្បត្តិដោយប្រការផ្សេងៗ
- o ខូចខាតផលដំណាំ

| សកម្មភាពទី៣ : ការបង្ហាញករណីសិក្សាពីតម្រូវការប្រាក់ក្នុងស្ថានភាពចាំបាច់ | ⏱ ៥៥ នាទី |
|---|---|

១. គ្រូបែងចែកសិស្សជា ១០ ក្រុមតូច ២ក្រុមមានករណីសិក្សាដូចគ្នា (ករណីសិក្សាតែមួយ)

២. គ្រូចែករណីសិក្សា ១ ក្នុងចំណោមករណីសិក្សាទាំង ៥ (ប្រសិនបើសិស្សមានសៀវភៅឯកសារគេអាចមើលខ្លឹមសារករណីសិក្សានេះនៅក្នុងសៀវភៅ)។

៣. ក្រុមនីមួយៗត្រូវសរសេរចម្លើយចំពោះសំណួរដែលមានរាយនៅខាងក្រោមករណីសិក្សានីមួយៗ។

### រឿងរបស់ វ៉ាន់ដា

វ៉ាន់ដា មានហាងតូចមួយនៅផ្ទះល្វែងផ្ទាល់ដី ។ នាងបើកលក់គ្រឿងទេសដូចជា ស៊ុត ហ្គាស ស្ករត្នោត អំបិល ឈើគូស ទៀន អំពូលភ្លើង ។ល ។ ប្រសិនបើគាត់ត្រូវការស្ករ អំបិល ឬរបស់របរផ្សេងទៀត សម្រាប់ចំអិនអាហារ គាត់តែងតែយករបស់ដែលមាននៅក្នុងហាងមកប្រើប្រាស់ ។

ពេលខ្លះគាត់បាត់បង់ភ្ញៀវ ពីព្រោះហាងរបស់គាត់គ្មានទំនិញគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់តម្រូវការភ្ញៀវ ។ គាត់គ្មានប្រាក់គ្រប់គ្រាន់សម្រាប់ទិញទំនិញបន្ថែមមកដាក់លក់នៅក្នុងហាងទេ ។ ជាញឹកញាប់គាត់ក៏គ្មានប្រាក់គ្រប់គ្រាន់សម្រាប់ទិញម្ហូបអាហារផ្គត់ផ្គង់គ្រួសារផងដែរ ។ គាត់ឆ្ងល់ណាស់ហេតុអ្វីបានជាមុខរបររបស់គាត់រកប្រាក់មិនបាន ។ គាត់ត្រូវសុំប្រាក់ពីប្ដីរបស់គាត់បន្ថែមទៀតសម្រាប់បន្តមុខរបរនេះ ។

### រឿងរបស់ សារី

សារី ជាអ្នកប្រកបមុខរបរធ្វើនំ ។ ជារៀងរាល់ព្រឹកនាងក្រោកពីព្រលឹម ដើម្បីធ្វើនំ ។ ពេលធ្វើរួចគាត់តែងទុកនំ ២ សម្រាប់គ្រួសារគាត់ ហើយក្រៅពីនេះគាត់យកទៅលក់ឱ្យហាងនំ ។ ម្ចាស់ហាងបង់ប្រាក់ថ្លៃលក់នំឱ្យគាត់ជារៀងរាល់ថ្ងៃ ហើយថែមទាំងបញ្ជាទិញទុកសម្រាប់លក់នៅថ្ងៃបន្ទាប់ទៀត ។ គាត់មិនដែលទិញអ្វីផ្ដេសផ្ដាសនោះទេ ។ នៅពេលត្រឡប់មកដល់ផ្ទះវិញ គាត់បានដាក់ប្រាក់ចូលទៅក្នុងហិបពិសេសរបស់គាត់ដែលលាក់ទុកក្នុងផ្ទះ ។

សារី តែងធ្វើផែនការពីការចំណាយប្រាក់ជានិច្ច ។ ក្នុងមួយសប្ដាហ៍គាត់រាប់ប្រាក់ម្ដង ដើម្បីចង់ដឹងថាតើគាត់រកបានប្រាក់ប៉ុន្មាន ។ គាត់ពិនិត្យមើលរបស់របរសម្រាប់ផ្គត់ផ្គង់មុខជំនួញរបស់គាត់ ហើយធ្វើការសម្រេចចិត្តថា តើត្រូវការប្រាក់ប៉ុន្មានសម្រាប់ទិញនៅសប្ដាហ៍ក្រោយ ។ គាត់តែងពិនិត្យមើលក្រែងមានឧបករណ៍ណាមួយត្រូវផ្លាស់ ។ បន្ទាប់មក សារី ពិនិត្យមើលរបស់របរហូបចុកសម្រាប់គ្រួសារដែលត្រូវការបន្ថែម ។ គាត់បានដាក់ប្រាក់មួយផ្នែកចូលទៅក្នុងហោប៉ៅខាងឆ្វេងសម្រាប់ទិញរបស់របរធ្វើនំ ហើយគាត់ដាក់ប្រាក់មួយផ្នែកទៀតទៅក្នុងហោប៉ៅខាងស្ដាំសម្រាប់ទិញម្ហូបអាហារ ។ គាត់ក៏ដាក់ប្រាក់មួយចំនួនតូចចូលទៅក្នុងហិបវិញសម្រាប់ប្រើប្រាស់ពេលត្រូវការចាំបាច់ ។ បន្ទាប់មកសារីក៏ទៅផ្សារដើម្បីទិញរបស់របរធ្វើនំ និងម្ហូបអាហារ ។  នាងមានប្រាក់គ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់គ្រួសារ ។

**រឿងរបស់ មីងមួយ**

ក្នុងការខ្ចីប្រាក់កាលពីលើកមុន មីងមួយ បានខិតខំធ្វើការយ៉ាងខ្លាំងដើម្បីរកប្រាក់សងគេ ។ គាត់បានទិញបន្លែនៅផ្សារនៅទីក្រុងមកលក់នៅតាមផ្ទះក្នុងសហគមន៍ ។ គាត់រកប្រាក់ចំណេញបានច្រើនណាស់ពីការខ្ចីប្រាក់លើកមុនមកប្រកបមុខរបរ ។

មីងមួយ ឥឡូវខ្ចីប្រាក់ថ្មីបន្តទៀត ។ ប្រាក់ដែលគាត់ខ្ចីលើកនេះ មួយផ្នែកគាត់បានយកទៅទិញបន្លែលក់ ។ ប្រាក់ដែលនៅសល់គាត់យកទៅទិញអង្ករ និងគ្រឿងធ្វើម្ហូបផងដែរ ។ គាត់បានសម្រេចចិត្តទិញរទេះរុញល្អជាងមុនមួយសម្រាប់ដាក់លក់ទំនិញរបស់គាត់ ។

មិត្តរបស់មីងមួយដែលខ្ចីប្រាក់គេដែរនោះបានមកលេងគាត់ ។ មិត្តរបស់ មីងមួយម្នាក់នេះមិនបានបង់ប្រាក់ដែលខ្ចីគេជាយូរមកហើយ ព្រោះកូនរបស់គាត់មានជំងឺជាទម្ងន់កាលពីឆ្នាំកន្លងទៅនេះ ។ គាត់បានចំណាយប្រាក់ជាច្រើនទៅលើថ្លៃព្យាបាលកូន ។ គាត់ក៏សុំខ្ចីប្រាក់ខ្លះពីមីងមួយ ។

មីងមួយក៏បានពន្យល់ប្រាប់មិត្តគាត់ថា គាត់ត្រូវការប្រើប្រាក់កម្ចីនេះសម្រាប់មុខជំនួញរបស់គាត់ ។ម្យ៉ាងទៀតគាត់មិនទាន់មានប្រាក់សងគេនៅឡើយទេ ។ ប៉ុន្តែមីងមួយបាននិយាយថាខ្ញុំមានប្រាក់មួយចំនួនតូចដែលបានសន្សំទុកសម្រាប់ពេលត្រូវការជាបន្ទាន់ ប៉ុន្តែឯងអាចខ្ចីប្រាក់នេះបានប្រសិនបើមានស្ថានភាពធ្ងន់ធ្ងរបែបនេះ ។ មិត្តរបស់មីងមួយបានអរគុណគាត់ជាខ្លាំងដែលបានជួយ ហើយសន្យាថានឹងសងមីងមួយវិញក្នុងពេលមួយសមស្រប ។

ឥឡូវមីងមួយមានទំនិញច្រើនសម្រាប់លក់ ហើយរទេះដែលដាក់ទំនិញរបស់គាត់ក៏ស្អាតទៀត ។ មីងមួយកំពុងតែរកបានប្រាក់ចំណេញច្រើន ហើយគាត់អាចមានលទ្ធភាពសងប្រាក់គេបានយ៉ាងងាយស្រួល ។ គាត់បានសម្រេចចិត្តដាក់សន្សំបន្ថែមទៀតជំនួសឱ្យប្រាក់ដែលគាត់បានឱ្យមិត្តភក្តិខ្ចី ។

**រឿងរបស់ រក្សា**

រក្សាជាជាងកាត់ដេរ ។ គាត់កាត់ដេរសម្លៀកបំពាក់នៅឯហាងមួយ ។ ពេលថ្មីៗនេះ គាត់បានបើកមុខជំនួញកាត់ដេរផ្ទាល់ខ្លួន ។ រក្សាបានខ្ចីប្រាក់គេច្រើនជាង២ដងនៃចំនួនប្រាក់ដែលគាត់បានគ្រោងសម្រាប់ធ្វើដើមទុនប្រកបមុខរបររបស់គាត់ ។

រក្សាក៏មានបំណងរៀបចំពិធីជប់លៀង ដើម្បីអបអរសាទរការចាប់ផ្តើមមុខជំនួញរបស់គាត់ ។ រក្សាបានយកប្រាក់ដែលខ្ចីលើសមកធ្វើពិធីជប់លៀង ។

សកម្មភាពធ្វើជំនួញថ្មីរបស់រក្សាបានដំណើរការល្អប្រសើរ ប៉ុន្តែគាត់មិនមានប្រាក់គ្រប់គ្រាន់សងគេឱ្យបានទៀតទាត់នោះទេ ។ រក្សាបានប្រើប្រាក់ដែលខ្ចីលើស ដើម្បីសងបំណុលគេ ។

ដល់កំណត់ថ្ងៃបង់ប្រាក់ រក្សាមិនមានប្រាក់គ្រប់គ្រាន់ ដើម្បីបង់ថ្លៃសងបំណុលសរុបនោះឡើយ ។ គាត់បានប្រមូលប្រាក់ធ្វើជំនួញរបស់គាត់ទាំងអស់យកទៅសងបំណុលគេ ។ គាត់បាត់បង់ម៉ាស៊ីនកាត់ដេររបស់គាត់ និងគ្មានធនធានសម្រាប់បន្តមុខជំនួញរបស់គាត់ទៀតឡើយ ។

**រឿងរបស់ វណ្ណា**

វណ្ណា បានទៅខ្ចីប្រាក់គេ ។ នាងមានផែនការប្រើប្រាក់កម្ចីទាំងអស់ ដើម្បីទិញអង្ករសម្រាប់លក់ ។ នៅពេលគាត់មកដល់ផ្សារ គាត់មិនបានទិញអង្ករទេ តែគាត់បានឃើញសំលៀកបំពាក់ស្អាតៗ ។ គាត់មិនបានទិញសំលៀកបំពាក់ជាយូរមកហើយ ។ គាត់ក៏សម្រេចចិត្តទិញសំលៀកបំពាក់នោះ ។

កូនស្រីរបស់វណ្ណាក៏សុំសម្លៀកបំពាក់ថ្មីដែរ ។ គាត់ក៏បានទិញឱ្យកូនមួយសម្រាប់ដែរ ។ គាត់នៅសល់ប្រាក់កម្ចីតែពាក់កណ្តាលប៉ុណ្ណោះ ។ គាត់ក៏ទៅទិញអង្ករសម្រាប់ធ្វើមុខជំនួញរបស់គាត់ ។ គាត់ក៏វិលត្រឡប់ទៅសហគមន៍របស់គាត់វិញ ដើម្បីលក់អង្ករ ។ គាត់រកប្រាក់ចំណូលបានតិចតួចជាងអ្វីដែលគាត់បានគិត ។ គាត់ស្ទើរតែគ្មានប្រាក់ចាត់ចែងសងបំណុលរបស់គេ ។

៤. គ្រូពន្យល់

- ប្អូនត្រូវធ្វើការតាមក្រុមតូច ដើម្បីធ្វើបង្ហាញពីករណីសិក្សា ព្រមទាំងឆ្លើយនឹងសំណួរទាក់ទងនឹងការប្រើប្រាក់សម្រាប់ធ្វើជំនួញ និង ប្រាក់ផ្ទាល់ខ្លួន ។
  - o តើនៅក្នុងករណីសិក្សាមានបញ្ហាអ្វីកើតឡើង?
  - o តើអាចមានជម្រើសអ្វីខ្លះសម្រាប់បុគ្គល ឬ ក្រុមដែលប្រឈមនឹងបញ្ហាទាំងនេះនៅក្នុងករណីសិក្សារបស់អ្នក?
  - o តើជម្រើសអ្វីខ្លះដែលពួកគេបានធ្វើនៅក្នុងករណីសិក្សារបស់អ្នក?
  - o តើពួកគេអាចមានជម្រើសផ្សេងអ្វីខ្លះ?
- គ្រូពិនិត្យមើលករណីសិក្សាទាំងនោះម្តងមួយៗ ។
  - o គ្រូឱ្យសិស្សនៅក្នុងក្រុមម្នាក់អានករណីសិក្សា ។

- គ្រូឱ្យសិស្សមកពីក្រុមទាំង ២ដែលធ្វើការពិភាក្សាលើករណីសិក្សានោះ ចូលរួមឆ្លើយនឹងសំណួរ ទាំង ៤ ខាងលើ ។ សិស្សផ្សេងទៀតអាចសួរសំណួរ និង ចូលរួមបន្ថែមយោបល់ចំពោះការបង្ហាញរបស់ក្រុមនីមួយៗ ។

៥. បន្ទាប់ពីការបង្ហាញករណីសិក្សាទាំងនោះចប់ គ្រូសួរ ៈ

- ហេតុអ្វីបានជាចាំបាច់ត្រូវរក្សាទុកដាក់ប្រាក់សម្រាប់ធ្វើជំនួញ និង ប្រាក់ផ្ទាល់ខ្លួនឱ្យនៅដាច់ដោយឡែកពីគ្នា?
- ចូរបញ្ជាក់ពីសារៈសំខាន់ក្នុងការប្រើប្រាស់ប្រាក់ធ្វើជំនួញសម្រាប់សកម្មភាពជំនួញផ្សេងទៀតដែលចាំបាច់ ។
- កំណត់យុទ្ធវិធី ដែលធ្វើឱ្យយើងអាចប្រើប្រាស់ និង ចាត់ចែងប្រាក់ធ្វើជំនួញប្រកបដោយ ប្រសិទ្ធភាព និង ទុកដាក់ប្រាក់ធ្វើជំនួញ និង ប្រាក់ផ្ទាល់ខ្លួននៅដាច់ដោយឡែកពីគ្នា ។

## ខ្លឹមសារសង្ខេបឯកសារណែនាំសម្រាប់គ្រូ

គ្រូឱ្យសិស្សបំពេញសំណួរ ដើម្បីសង្ខេបឡើងវិញលើខ្លឹមសារមេរៀន។ ប្រសិនបើសិស្សមានសៀវភៅឯកសារ គេអាចមើលនៅក្នុងសៀវភៅរបស់គេ។

- សិស្សធ្វើកិច្ចការដោយខ្លួនគេ ឆ្លើយនឹងសំណួរដែលមានបិទលើក្រដាសផ្ទាំងធំ។
- សិស្សអាចប្រើព័ត៌មាននៅក្នុងសៀវភៅកត់ត្រារបស់គេបាន។

***សំណួរសង្ខេបមេរៀនឡើងវិញ :***

១. ចូរលើកឧទាហរណ៍ពី " **តម្រូវការ** " មួយ ហើយពន្យល់ថាហេតុអ្វីក៏វាជាតម្រូវការចាំបាច់។

២. ចូរលើកឧទាហរណ៍ពី " **ចំណង់** " មួយ ហើយពន្យល់ថាហេតុអ្វីក៏វាជាចំណង់។

៣. តើការចំណាយណាមួយដែលងាយស្រួល និង សំខាន់បំផុត?(ចូរគូសរង្វង់ជុំវិញឃ្លានោះ)

**ចំណាយថេរ    ចំណាយប្រែប្រួល    ចំណាយដែលមិនបានគ្រោងទុក    ចំណាយលើវត្ថុប្រណិត**

៤. តើ "**ទម្លាប់ចំណាយប្រាក់**" បែបណាដែលអ្នកចាត់ទុកថាល្អ ឬសមរម្យ?

៥. តើអ្នកគិតថានឹងកែលំអ " **ទម្លាប់ចំណាយប្រាក់** " តាមវិធីណាខ្លះ?

៦. តើអ្វីដែលជាគោលបំណងសំខាន់សម្រាប់អ្នក?

៧. តើអ្នកមានសកម្មភាពអ្វីខ្លះ ដែលអ្នកត្រូវធ្វើ ដើម្បីឱ្យសម្រេចគោលបំណងនេះ?

៨. តើអ្នកត្រូវតែផ្លាស់ប្តូរ " **ទម្លាប់ចំណាយប្រាក់** " ដើម្បីធ្វើឱ្យមានប្រាក់សម្រេចគោលបំណងធ្វើជំនួញរបស់អ្នកឬទេ? ចូរពន្យល់។

៩. តើអ្វីដែលជាសារៈសំខាន់នៃការប្រើប្រាស់សៀវភៅកំណត់ត្រាចំណាយ?

១០. តើសារប្រយោជន៍នៃការបង្កើតថវិកាមានអ្វីខ្លះ?

១១. តើហេតុអ្វីបានជាថវិកាអាចនឹងមានការប្រែប្រួលគ្រប់ពេល?

១២. ចូរពន្យល់ពីសារៈសំខាន់នៃការរៀបចំបញ្ជីគណនេយ្យ ។

១៣. តើអ្វីដែលជាចំណុចសំខាន់ត្រូវពិចារណា ពេលអ្នកធ្វើការកំណត់តម្លៃទំនិញសម្រាប់លក់?

១៤. ចូរលើកហេតុផល ៣ យ៉ាង ដើម្បីបញ្ជាក់សារៈសំខាន់ក្នុងការរក្សាទុកប្រាក់ធ្វើជំនួញ និងប្រាក់ផ្ទាល់ខ្លួននៅដាច់ពីគ្នា ។

## ឧបសម្ព័ន្ធ ១.១ : [illegible] (សម្រាប់គ្រូ)

### ប័ណ្ណវាយតម្លៃការសិក្សារបស់សិស្សម្នាក់ៗ

ឈ្មោះសិស្ស __________ សាលា__________ ឃុំ______ ស្រុក________ ថ្នាក់ទី ____ [illegible]______

| ចំណុចត្រូវដាក់ពិន្ទុ | | ពិន្ទុ (១-១៥) | និទ្ទេស |
|---|---|---|---|
| វិញ្ញាសាទី ១: [illegible] ([illegible]) | | | |
| [illegible] ១៥ ពិន្ទុ (ពីពិន្ទុ ០ ដល់ ៧-ខ្សោយ/ ពី ៨ ដល់ ១០-មធ្យម / ពី ១១ ដល់ ១៥-ល្អ) | | | |
| សង្កេតឥរិយាបថសិស្ស | | ពិន្ទុ (១-៥) | និទ្ទេស |
| ១ | [illegible] : [illegible] ។ [illegible] ។ | | |
| ២ | [illegible] : [illegible] ។ | | |
| ៣ | [illegible] : [illegible] ។ | | |
| ៤ | [illegible] : [illegible] | | |
| ៥ | [illegible] : [illegible] ។ | | |
| ៦ | [illegible] : [illegible] ។ | | |
| ៧ | [illegible] : [illegible] ។ | | |
| | សរុបសង្កេតឥរិយាបថសិស្ស | | |
| សង្កេតឥរិយាបថសិស្សទទួលបានពិន្ទុសរុប ៣៥ ពិន្ទុ (ពីពិន្ទុ ០ ដល់ ១៧-ខ្សោយ/ ពី ១៨ ដល់ ២៥-មធ្យម / ពី ២៦ ដល់ ៣៥-ល្អ) | | | |
| ពិន្ទុសរុបសំណួរសរសេរ និងសង្កេតឥរិយាបថសិស្ស (ពីពិន្ទុ ០ ដល់ ២៤-ខ្សោយ/ ពី ២៥ ដល់ ៣៣-មធ្យម / ពី ៣៤ ដល់ ៥០-ល្អ) | | | |

ថ្ងៃទី ______ ខែ ______ ឆ្នាំ _____

ហត្ថលេខា និងឈ្មោះគ្រូ

## ឧបសម្ព័ន្ធ ១.២ : តារាងបូកសរុបរបាយតម្លៃការសិក្សារបស់សិស្សប្រចាំថ្នាក់

ខេត្ត ......................... ស្រុក .........................សាលា ............................... ថ្នាក់ទី .......... ប្រធានបទ ....................

| ល.រ | ឈ្មោះសិស្ស | សំណួរសរសេរ | | ឥរិយាបថ | | សរុប | |
|---|---|---|---|---|---|---|---|
| | | ពិន្ទុ | និទ្ទេស | ពិន្ទុ | និទ្ទេស | ពិន្ទុ | និទ្ទេស |
| ១ | | | | | | | |
| ២ | | | | | | | |
| ៣ | | | | | | | |
| ៤ | | | | | | | |
| ៥ | | | | | | | |
| ៦ | | | | | | | |
| ៧ | | | | | | | |
| ៨ | | | | | | | |
| ៩ | | | | | | | |
| ១០ | | | | | | | |
| ១១ | | | | | | | |
| ១២ | | | | | | | |
| ១៣ | | | | | | | |
| ១៤ | | | | | | | |
| ១៥ | | | | | | | |
| ១៦ | | | | | | | |
| ១៧ | | | | | | | |
| ១៨ | | | | | | | |
| ១៩ | | | | | | | |
| ២០ | | | | | | | |
| ២១ | | | | | | | |
| ២២ | | | | | | | |
| ២៣ | | | | | | | |
| ២៤ | | | | | | | |
| ២៥ | | | | | | | |
| ២៦ | | | | | | | |

បានឃើញ និងឯកភាព

ថ្ងៃទី .......... ខែ ............ ឆ្នាំ ..........

នាយកសាលា

ហត្ថលេខា និងឈ្មោះគ្រូបង្រៀន

| ការអង្កេតថ្នាក់រៀន | | | | | ការវាយតម្លៃគ្រប់ណិនជីវិត |
|---|---|---|---|---|---|
| សាលា | | | | គ្រូ | អ្នកសង្កេត |
| | | | | | |
| កាលបរិច្ឆេទ | ការចាប់ផ្តើមមេរៀន | ការបញ្ចប់មេរៀន | ថ្នាក់ | ចំនួនសិស្សដែលបានចុះឈ្មោះ/មានវត្តមាន | ប្រធានបទបំណិនជីវិត: |
| | | | | | |
| តើមេរៀនបង្ហាញពីអ្វី? | | | | | |
| | | | | | |

| លក្ខណៈវិនិច្ឆ័យ – ការរៀបចំ – តើបន្ទប់រៀន.. | ពិន្ទុ | កំណត់សម្គាល់យោងតាមភស្តុតាង |
|---|---|---|
| មានសណ្តាប់ធ្នាប់ ហើយសម្ភារត្រៀមជាស្រេចសម្រាប់ប្រើប្រាស់ក្នុងមេរៀននេះ? | 1-2-3-4-5 | |
| បង្ហាញសិស្សនូវសម្ភារៈដែលបានធ្វើកាលពីមេរៀនមុន? | 1-2-3-4-5 | |
| **លក្ខណៈវិនិច្ឆ័យ - ការសិក្សា - តើសិស្ស...** | **ពិន្ទុ** | **កំណត់សម្គាល់យោងតាមភស្តុតាង** |
| **មានចំណាប់អារម្មណ៍ និងចូលរួមក្នុងការងាររបស់ពួកគេ** | **1-2-3-4-5** | |
| **ធ្វើការក្នុងក្រុមខុសៗគ្នាក្នុងកំឡុងពេលបង្រៀន ដោយមានតួនាទីក្រុមច្បាស់លាស់** | **1-2-3-4-5** | |
| **ពិភាក្សាជាមួយមេរៀនដែលគ្រូបង្រៀន** | **1-2-3-4-5** | |
| **បង្ហាញចំណេះដឹង ឬបំណិនពីមេរៀនមុន** | **1-2-3-4-5** | |
| **លក្ខណៈវិនិច្ឆ័យ – ការបង្រៀន – តើគ្រូ..** | **ពិន្ទុ** | **កំណត់សម្គាល់យោងតាមភស្តុតាង** |
| **អនុវត្តតាមកិច្ចតែងការដែលមាន?** | **1-2-3-4-5** | ***សូមបញ្ជាក់ពីគុណភាពមួយដែលត្រូវបានប្រើ*** |
| **ប្រើប្រាស់ធនធានសហគមន៍ក្នុងការបង្រៀនមេរៀននេះ ឬប្រើប្រាស់សហគមន៍ផងស្រុង?** | **1-2-3-4-5** | |

| | | |
|---|---|---|
| ប្រើប្រាស់វិធីសាស្ត្របង្រៀនបែបអន្តរកម្ម ឧ.ផែនទី គំនិត, ការណីសិក្សា, ការសម្តែងតួ,ល្បែងកំសាន្ត... | 1-2-3-4-5 | |
| ប្រើប្រាស់ប្រភេទសំណួរផ្សេងៗ | 1-2-3-4-5 | |
| ប្រើប្រាស់ធនធានបង្កើតឡើងដោយខ្លួនឯង ឬរក សាបន្ថែមដើម្បីពន្យល់មេរៀន | 1-2-3-4-5 | |
| ចាប់ផ្តើមតាមពេលកំណត់ និងប្រើប្រាស់ពេល វេលាយ៉ាងមានប្រសិទ្ធភាព | 1-2-3-4-5 | |
| ផ្តល់មតិយោបល់វិជ្ជមានដើម្បីជំរុញការសិក្សា និង បង្កើនទំនុកចិត្តរបស់សិស្ស | 1-2-3-4-5 | |
| ជួយសិស្សជាលក្ខណៈបុគ្គលចំពោះសិស្សណាដែល មានការលំបាក | 1-2-3-4-5 | |
| កត់ត្រាការវិវត្តនៃអត្តចរិតសិស្សក្នុងតារាងវាយ តម្លៃការសិក្សារបស់សិស្ស? | 1-2-3-4-5 | |

បន្ទាប់ពីផ្នែកនេះ ចូរប្រើប្រាស់កំណត់ត្រារបស់អ្នកដើម្បីពិភាក្សាជាមួយគ្រូ សុំឱ្យគ្រូកំណត់ចំណុចល្អរបស់មេរៀន ហើយធ្វើការស្នើសុំការផ្លាស់ប្តូរ ឬការកែលម្អ ធ្វើការជាមួយគ្រូដើម្បីកំណត់ភាពខ្លាំងៗ ធ្វើការផ្តល់គំនិតចំពោះការកែលម្អ ការសង្កេតត្រូវបានបញ្ចប់ ដោយធ្វើការសម្ភាសន៍។

| ចំណុចខ្លាំង | គំនិតសម្រាប់កែលម្អ |
|---|---|
| | |

ហត្ថលេខានិងឈ្មោះរបស់អ្នកវាយតម្លៃ ....................

ហត្ថលេខានិងឈ្មោះរបស់គ្រូ ................................

X

# ចំណង់ ឬ តម្រូវការ

✓


មិត្តភ័ក្ត

ការងារ


វត្តអារាម ឬ វិហារអ៊ីស្លាម



សាលារៀន


លុយជាច្រើន

ទូរទស្សន៍



កុំព្យូទ័រផ្ទាល់ខ្លួន

ម៉ូតូថ្មី



ស្ករគ្រាប់ និង នំស្រួយ

សម្រាកពេញមួយថ្ងៃ



គ្រឿងអលង្ការ

ការថែរក្សាជម្ងឺពីគ្រូពេទ្យ


ឡានឡិចស៊ីស


ការការពារពី ការរំលោភបំពាន ឬ ការប្រមាទ



បន្ទប់គេងផ្ទាល់ខ្លួន


អាហារភ្លាមៗ


សិទ្ធសម្រាប់ការពារពីការរើសអើង



អាហាររូបត្ថម្ភ


ទឹកស្អាត

សំលៀកបំពាក់ និង ម៉ូដនិយមថ្មី



សេរីភាពដើម្បីប្រតិបត្តិវប្បធម៌របស់ខ្លួនផ្ទាល់

កន្លែងកំសាន្ត និងការកំសាន្តសប្បាយ


ទូរស័ព្ទថ្មី


ការបញ្ចេញមតិយោបល់


# រូបិយវត្ថុកម្ពុជា



ប្រភេទក្រដាសប្រាក់: ៥០រៀល
ទំហំ: ១៣០មម x ៦០មម
ឆ្នាំបោះពុម្ភ: ២០០២
ពណ៌ផ្ទៃ: លឿងទុំ
ពណ៌នា: ផ្នែកកណ្តាលនៃក្រដាសប្រាក់រំលេចឡើងនូវរូបក្លោងទ្វារប្រាសាទបន្ទាយស្រី។ ផ្នែកខាងស្តាំមានរូបនរៈសិង្ហ និងផ្នែកខាងឆ្វេងមានរូបចម្លាក់ក្បាលនាគ។



ប្រភេទក្រដាសប្រាក់: ១០០រៀល
ទំហំ: ១៣០មម x ៦០មម
ឆ្នាំបោះពុម្ភ: ២០០១
ពណ៌ផ្ទៃ: ស្វាយ និងបៃតង
ពណ៌នា: រំលេចឡើងនូវទិដ្ឋភាពនៃសាលារៀនមួយខ្នង និងសិស្សានុសិស្សកំពុងដើរសំដៅទៅកាន់ថ្នាក់រៀនរបស់ខ្លួន។



ប្រភេទក្រដាសប្រាក់: ៥០០រៀល
ទំហំ: ១៣៨មម x ៦៤មម
ឆ្នាំបោះពុម្ភ: ២០០៣
ពណ៌ផ្ទៃ: ក្រហម
ពណ៌នា: រូបភាពស្ពានគីស្សិណា "កម្ពុជា-ជប៉ុនដែលឆ្លងកាត់ទន្លេមេគង្គ ស្ថិតក្នុងទីរួមខេត្តកំពុងចាម។



ប្រភេទក្រដាសប្រាក់: ១០០០រៀល
ទំហំ: ១៣៨មម x ៦៤មម
ឆ្នាំបោះពុម្ភ: ២០០៦
ពណ៌ផ្ទៃ: ឈាមជ្រូក និងខៀវ
ពណ៌នា: រូបភាពកំពង់ផែខេត្តព្រះសីហនុ ដែលកំពុងមានសកម្មភាពមមាញឹកក្នុងការលើកដាក់ទំនិញ។



ប្រភេទក្រដាសប្រាក់: ២០០០រៀល
ទំហំ: ១៤៦មម x ៦៨មម
ឆ្នាំបោះពុម្ភ: ២០០៨
ពណ៌ផ្ទៃ: បៃតងក្រមៅ និងលឿង
ពណ៌នា: រូបទ្វារប្រាសាទព្រះវិហារ និងអក្សរ "ពីរពាន់រៀល" នៅពីខាងក្រោម។



ប្រភេទក្រដាសប្រាក់: ៥០០០រៀល
ទំហំ: ១៤៦មម x ៦៨មម
ឆ្នាំបោះពុម្ភ: ២០០១
ពណ៌ផ្ទៃ: ប្រផេះ និងបៃតង
ពណ៌នា: រូបស្ពានបុរាណនៅកំពង់ក្តី ខេត្តសៀមរាប។



ប្រភេទក្រដាសប្រាក់: ១០០០០រៀល
ទំហំ: ១៤៦មម x ៦៨មម
ឆ្នាំបោះពុម្ភ: ២០០១
ពណ៌ផ្ទៃ: ពណ៌ស្វាយ ពណ៌ត្នោត និងខៀវ
ពណ៌នា: រូបភាពពិធីបុណ្យអុំទូកនៅមុខព្រះបរមរាជវាំង។



ប្រភេទក្រដាសប្រាក់: ២០០០០រៀល
ទំហំ: ១៥០មម x ៧០មម
ឆ្នាំបោះពុម្ភ: ២០០៨
ពណ៌ផ្ទៃ: ស៊ីជម្ពូ និងពណ៌ខៀវ
ពណ៌នា: រូបភាពប្រាសាទអង្គរធំទាំងមូលមើលបញ្ឈិតពីលើ និងរូបចម្លាក់ព្រហ្មមុខបួននៃប្រាសាទបាយ័ន។



ប្រភេទក្រដាសប្រាក់: ៥០០០០រៀល
ទំហំ: ១៥០មម x ៧០មម
ឆ្នាំបោះពុម្ភ: ២០០១
ពណ៌ផ្ទៃ: លឿង ឈាមជ្រូក និងត្នោត
ពណ៌នា: រូបភាពប្រាសាទអង្គរវត្ត មើលបញ្ឈិតពីលើ។

MINISTERIO
DE ASUNTOS EXTERIORES
Y DE COOPERACION

aecid

DEUTSCHE ZUSAMMENARBEIT

giz